គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee for Cambodia
Comité de Coopération Pour le Cambodge

# ការវាយតម្លៃបរិយាកាសអំណោយផលសម្រាប់សង្គមស៊ីវិល




## របាយការណ៍ប្រចាំប្រទេស កម្ពុជា

ទទួលបន្ទុកដោយ :

**គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា**

ខែធ្នូ ឆ្នាំ២០១៣

**Promoting NGO Solidarity and Cooperation Since 1990**

Accountability
Symbol of Trust

របាយការណ៍នេះត្រូវបានធ្វើឡើងសម្រាប់គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ដោយ Ms. Louise Coventry Ms. Menh Navy and Ms. Alison Hillis។

ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់រៀបចំរបាយការណ៍ បានផ្តល់តាមរយៈ កម្មវិធីគំនិតផ្តួចផ្តើមលំហាពលរដ្ឋ (Civic Space Initiative program) ដែលមានកិច្ចសហការជាមួយ មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ច្បាប់ស្តីពីការមិនយកចំណេញ (ICNL) - មាត្រា ១៩ (ARTICLE19) អង្គការ CIVICUS: សម្ព័ន្ធភាពពិភពលោក សម្រាប់ ការចូលរួមរបស់ប្រជាពលរដ្ឋ និង ចលនាពិភពលោក ដើម្បីប្រជាធិបតេយ្យ (World Movement for Democracy)។

របាយការណ៍នេះបានទទួលជំនួយឧបត្ថម្ភមួយផ្នែក ពីទីភ្នាក់ងារអភិវឌ្ឍអន្តរជាតិស៊ុយអែដ (Sida)។ Sida មិនបានបញ្ចេញមតិយោបល់ក្នុងរបាយការណ៍នេះឡើយ ដូច្នេះរាល់គំនិតទាំងឡាយជាការទទួលខុសត្រូវ ទាំងស្រុងរបស់អ្នកនិពន្ធ។

**រក្សាសិទ្ធិ:**

© រាល់យោបល់ទាំងនេះជារបស់អ្នកនិពន្ធ និងទទួលបានពីអ្នកផ្តល់ចម្លើយផ្សេងៗ ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈ និងគំនិតរបស់ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ឡើយ។ សូមលើកទឹកចិត្ត ក្នុងការបោះពុម្ព ឬ ការផលិតឡើងវិញ ដែលមានការទទួលស្គាល់ស្នាដៃ របស់អ្នកនិពន្ធ និងអង្គការ CCC។

# មុខកថា

## ជម្រាបជូនមិត្តអ្នកអាន

សូមទទួលឯកសារ *ការវាយតម្លៃបរិយាកាសអំណោយផលសម្រាប់សង្គមស៊ីវិល* នៅកម្ពុជា ឆ្នាំ២០១៣។

ការសិក្សាស្រាវជ្រាវនេះទទួលបន្ទុកដោយ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ដែលមានកិច្ចសហការរវាង អង្គការ CIVICUS: សម្ព័ន្ធភាពពិភពលោកសម្រាប់ ការចូលរួមរបស់ប្រជាពលរដ្ឋ ព្រមទាំងជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីកម្មវិធីគំនិតផ្តួចផ្តើមលំហាពលរដ្ឋ (Civic Space Initiative program) - មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ច្បាប់ស្តីពីការមិនយកចំណេញ (ICNL) មាត្រា ១៩ (ARTICLE19) និងចលនាពិភពលោកដើម្បីប្រជាធិបតេយ្យ (World Movement for Democracy)។ របាយការណ៍នេះបានទទួលជំនួយឧបត្ថម្ភមួយផ្នែកពីទីភ្នាក់ងារអភិវឌ្ឍអន្តរជាតិស៊ុយអែដ (Sida)។

បរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិលមានសារៈសំខាន់ណាស់ សម្រាប់ការចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេស ដែលតម្រូវអោយមានការគោរព និងអនុវត្តនូវសិទ្ធិជាមូលដ្ឋាន ហើយអាចអោយភាគីពាក់ព័ន្ធអាចរៀបចំ និងចូលរួមក្នុងកិច្ចអភិវឌ្ឍនេះ។

របាយការណ៍នេះធ្វើការវាយតម្លៃពីស្ថានភាព នៃបរិយាកាសអំណោយផលនៅកម្ពុជា ទាក់ទងនឹងក្របខណ្ឌគតិយុត្តិ បទបញ្ញត្តិ និង បរិយាកាសគោលនយោបាយ ដែលជះឥទ្ធិពលដល់ការរៀបចំ និងដំណើរការរបស់អង្គការសង្គមស៊ីវិលនៅកម្ពុជា។ បញ្ហាប្រឈមនានា ចំនួនប្រាំពីរ រួមមាន ៖ ការបង្កើត កិច្ចប្រតិបត្តិការ លទ្ធភាពទទួលធនធាន ការបញ្ចេញមតិ ការជួបប្រជុំដោយសន្តិវិធី កិច្ចសហប្រតិបត្តិការនិងសម្ព័ន្ធភាពរវាងអង្គការសង្គមស៊ីវិល និងជាមួយរាជរដ្ឋាភិបាល ត្រូវបានយកមកធ្វើការសិក្សា។ ក្នុងរបាយការណ៍នេះ ក៏បានលើកឡើងផងដែរនូវបញ្ហាប្រឈមសំខាន់ៗ និងឱកាសសម្រាប់អង្គការសង្គមស៊ីវិល និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីលើកកម្ពស់បរិយាកាសអំណោយផល។

សូមអរគុណ Louise Coventry, Menh Navy and Alison Hillis ដែលជាក្រុមការងាររៀបចំរបាយការណ៍នេះ។ សូមអរគុណផងដែរដល់ ក្រុមប្រឹក្សាផ្តល់យោបល់ស្រាវជ្រាវ (RAB) ដែលជួយប្រឹក្សាយោបល់ផ្សេងៗ ហើយជាពិសេស សូមអរគុណដល់ សម្ព័ន្ធអង្គការជាតិ ក្រុមក្រៅប្រព័ន្ធ/សកម្មជន អង្គការសង្គមស៊ីវិល និងម្ចាស់ជំនួយ និង បណ្តាញសម្របសម្រួលអង្គការតាមខេត្ត អ្នកនយោបាយ និងមន្ត្រី ដែលធ្វើការងារពាក់ព័ន្ធលើគោលនយោបាយ និងច្បាប់ផ្សេងៗដែលប៉ះពាល់

ដល់សង្គមស៊ីវិល ព្រមទាំង បណ្ដាញសារព័ត៌មាន/អ្នកកាសែតផ្នែកសង្គមស៊ីវិល អ្នកស្រាវជ្រាវផ្នែកបណ្ឌិតសភា ដែលបានចំណាយពេលដ៏មានតម្លៃសម្រាប់ផ្ដល់បទសម្ភាសន៍ជាលក្ខណៈបុគ្គល និងចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់។

CCC ជឿជាក់ថា របាយការណ៍ស្រាវជ្រាវនេះ នឹងអាចជាមូលដ្ឋានក្នុងការពិគ្រោះយោបល់ក្នុងចំណោម រាជរដ្ឋាភិបាល ភ្នាក់ងារអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ដើម្បីធ្វើការងាររួមគ្នា លើកកម្ពស់បរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិល ព្រមទាំងពង្រឹងទំនាក់ទំនងរវាងអង្គការសង្គមស៊ីវិល-រាជរដ្ឋាភិបាល និងលើកកម្ពស់ប្រសិទ្ធភាពអង្គការសង្គមស៊ីវិលក្នុងការចូលរួមចំណែកអភិវឌ្ឍកម្ពុជាប្រកបដោយសមធម៌ និងនិរន្តរភាព។

សូមអរគុណ

**សឿង សារឿន**

នាយកប្រតិបត្តិ

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា

# មាតិកា


**បុព្វកថា** .......... 1

**សេចក្តីសង្ខេបរួម** .......... 5

**ផ្នែកទី១: សេចក្តីផ្តើម** .......... 10

គោលបំណងនៃការស្រាវជ្រាវ .......... 11

និយមន័យ .......... 12

វេចនាសម្ព័ន្ធនៃរបាយការណ៍ .......... 15

**ផ្នែកទី ២: វិធីសាស្ត្រ** .......... 16

**ផ្នែកទី ៣: ការបង្កើតអង្គការសង្គមស៊ីវិល** .......... 20

ទស្សនៈរួម .......... 20

របកគំហើញ .......... 20

វិធីសាស្ត្រ .......... 26

សេចក្តីសង្ខេបបញ្ហាប្រឈមសំខាន់ៗ .......... 27

**ផ្នែកទី ៤: កិច្ចប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិល** .......... 28

ទស្សនៈរួម .......... 28

របកគំហើញ .......... 29

វិធីសាស្ត្រ .......... 35

សេចក្តីសង្ខេបអំពីបញ្ហាប្រឈមសំខាន់ៗ .......... 35

**ផ្នែកទី ៥: លទ្ធភាពទទួលធនធាន** .......... 36

ទស្សនៈរួម .......... 36

របកគំហើញ .......... 36

វិធីសាស្ត្រ .......... 41

សេចក្តីសង្ខេបអំពីបញ្ហាប្រឈមសំខាន់ៗ .......... 42

**ផ្នែកទី ៦: ការបញ្ចេញមតិ** .......... **43**
ទស្សនៈរួម .......... 43
របកគំហើញ .......... 43
វិធីសាស្ត្រ .......... 48
សេចក្តីសង្ខេបអំពីបញ្ហាប្រឈមសំខាន់ៗ .......... 49
**ផ្នែកទី ៧: ការជួបប្រជុំដោយសន្តិវិធី** .......... **50**
ទស្សនៈរួម .......... 50
របកគំហើញ .......... 50
វិធីសាស្ត្រ .......... 54
សេចក្តីសង្ខេបអំពីបញ្ហាប្រឈមសំខាន់ៗ .......... 55
**ផ្នែកទី ៨: ទំនាក់ទំនងរវាង រាជរដ្ឋាភិបាល និង សង្គមស៊ីវិល** .......... **56**
ទស្សនៈរួម .......... 56
របកគំហើញ .......... 56
វិធីសាស្ត្រ .......... 62
សេចក្តីសង្ខេបអំពីបញ្ហាប្រឈមសំខាន់ៗ .......... 62
**ផ្នែកទី ៩: កិច្ចសហប្រតិបត្តិការ និង សម្ព័ន្ធភាពសង្គមស៊ីវិល** .......... **63**
ទស្សនៈរួម .......... 63
របកគំហើញ .......... 63
វិធីសាស្ត្រ .......... 66
សេចក្តីសង្ខេបអំពីបញ្ហាប្រឈមសំខាន់ៗ .......... 66
**សេចក្តីសន្និដ្ឋាន** .......... **67**
**ឧបសម្ព័ន្ធ ១: កាលវិភាគបទសម្ភាសន៍** .......... **69**
**ឧបសម្ព័ន្ធ ២: អ្នកផ្តល់ព័ត៌មានសំខាន់ៗ** .......... **80**
**ឧបសម្ព័ន្ធ ៣: សន្ធានុក្រមនៃអង្គការសង្គមស៊ីវិលនៅកម្ពុជា** .......... **81**
**ឯកសារយោង** .......... **84**

# សេចក្តីសង្ខេបរួម

សង្គមស៊ីវិល មិនត្រឹមតែទទួលឥទ្ធិពលពីក្របខ័ណ្ឌគតិយុត្តិ និងបទបញ្ញត្តិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបរិយាកាសសម្រាប់ការប្រតិបត្តិ ផ្នែកសេដ្ឋកិច្ច នយោបាយ វប្បធម៌ សាសនា និងសង្គម។ ការវាយតម្លៃពេញលេញមួយលើបរិយាកាស សម្រាប់ការប្រតិបត្តិរបស់សង្គមស៊ីវិល នឹងពិនិត្យមើលទិដ្ឋភាពពាក់ព័ន្ធលើ សេដ្ឋកិច្ច នយោបាយ វប្បធម៌ សាសនា និងសង្គម - ក្នុងកិច្ចប្រឹងប្រែងមួយដើម្បីជំរុញការយល់ដឹងពីសក្តានុពល និងជោគជ័យនៃសង្គមស៊ីវិល។ របាយការណ៍នេះ ផ្តោតលើក្របខ័ណ្ឌបរិយាកាសផ្នែក គតិយុត្តិ បទបញ្ញត្តិ និង គោលនយោបាយ ដែលនៅក្នុងនោះ អង្គការសង្គមស៊ីវិលធ្វើប្រតិបត្តិការ ដោយសារប្រការនេះគឺជាគន្លឹះចំពោះលទ្ធភាពក្នុងការ ចុះបញ្ជី ធ្វើប្រតិបត្តិការ ទទួលបានធនធាន និងចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងការតស៊ូមតិ ដែលចំណុចទាំងអស់នេះ ជាលទ្ធផលរួមចំណែកដល់លទ្ធភាពរបស់សង្គមស៊ីវិលក្នុងការរីកលូតលាស់ និងទទួលបានជោគជ័យ។

សម្រាប់គោលបំណងនៃប្រទេសកម្ពុជា ទិដ្ឋភាពចំនួនប្រាំពីរនៃទិដ្ឋភាពអាចសិក្សាបានចំនួនដប់ សម្រាប់ក្របខ័ណ្ឌគតិយុត្តិ បទបញ្ញត្តិ និងគោលនយោបាយ ដែលត្រូវវាយតម្លៃ។ ទិដ្ឋភាពទាំងនេះ រួមមាន៖ (១) ការបង្កើត (២) កិច្ចប្រតិបត្តិការ (៣) លទ្ធភាពទទួលធនធាន (៤) ការបញ្ចេញមតិ (៥) ការជួបប្រជុំដោយសន្តិវិធី (៦) ទំនាក់ទំនងរវាងរាជរដ្ឋាភិបាលនិងសង្គមស៊ីវិល និង (៧) កិច្ចសហប្រតិបត្តិការនិងសម្ព័ន្ធភាពអង្គការសង្គមស៊ីវិល។ ទិដ្ឋភាពទាំងបីដែលមិនត្រូវបានពិនិត្យមើលក្នុងការវាយតម្លៃនេះ រួមមានសេរីភាពអ៊ីនធឺណេត ការយកពន្ធ និង លទ្ធភាពទទួលព័ត៌មាន។

ដោយអនុវត្តតាមការណែនាំពីការស្រាវជ្រាវ សម្រាប់ធ្វើការវាយតម្លៃថ្នាក់ជាតិ លើបរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិលក្នុងទូទាំងពិភពលោក របាយការណ៍ប្រចាំប្រទេសសម្រាប់កម្ពុជាផ្តោតយ៉ាងជាក់លាក់លើចំណុចខ្សោយ និងបញ្ហាប្រឈមទាំងឡាយ ដែលត្រូវបានកំណត់ក្នុងទិដ្ឋភាពទាំងប្រាំពីរនៃបរិយាកាសអំណោយផល សម្រាប់សង្គមស៊ីវិល។ របកគំហើញ គឺផ្អែកលើការស្រាវជ្រាវឯកសារ ការសម្ភាសន៍ជាមួយភាគីពាក់ព័ន្ធសំខាន់ៗចំនួន ២៤ នាក់ និងកិច្ចដំណើរការនៃសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិដែលមានអ្នកចូលរួមចំនួន ៧៥ នាក់នៅរាជធានីភ្នំពេញនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣។

របាយការណ៍នេះពិភាក្សាគោលបំណងពីរ នៃគោលបំណងចំនួនបីនៃការស្រាវជ្រាវៈ កំណត់ក្របខ័ណ្ឌគតិយុត្តិ បទបញ្ញត្តិ និង បរិយាកាសគោលនយោបាយ ដែលប៉ះពាល់លទ្ធភាពរបស់សង្គមស៊ីវិលកម្ពុជាក្នុងការបំពេញមុខងារនៅកម្រិតជាតិនិងក្រោមជាតិ និងកំណត់បញ្ហា ចំណុចខ្សោយ និងបញ្ហាប្រឈមសំខាន់ៗនៃក្របខ័ណ្ឌគតិយុត្តិ បទបញ្ញត្តិ និងបរិយាកាសគោលនយោបាយ ដែលប៉ះពាល់ លទ្ធភាពរបស់សង្គមស៊ីវិលកម្ពុជាក្នុងការបំពេញមុខងារនៅកម្រិតជាតិ និងក្រោមជាតិ។ គោលដៅទីបី ពោលគឺការកំណត់ថាតើត្រូវធ្វើដូចម្តេច ដើម្បីជំនះបានបញ្ហាប្រឈមទាំងឡាយនៃក្របខ័ណ្ឌគតិយុត្តិ បទបញ្ញត្តិ និងគោលនយោបាយ សម្រាប់សង្គមស៊ីវិលកម្ពុជា ដើម្បីបង្កើនលំហ

ប្រជាធិបតេយ្យនៅកម្ពុជា គឺជាប្រធានបទសម្រាប់ផែនការសកម្មភាពបន្ថែម ដែលមានគួរចែករំលែកដោយសង្គមស៊ីវិល និងរាជរដ្ឋាភិបាល ហើយប្រធានបទនេះមិនត្រូវបានពិភាក្សាយ៉ាងជាក់លាក់ទេក្នុងរបាយការណ៍នេះ។

ចំណុចខ្វះខាតនៃរបាយការណ៍នេះ គឺពឹងផ្អែកច្រើនខ្លាំងលើទស្សនៈរបស់បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងតំណាងតិចតួច ចំពោះមតិពីរាជរដ្ឋាភិបាល អង្គការសហគមន៍ និងបណ្តាញសារព័ត៌មាន។ ទំហំសំណាកតូច និងពេលវេលាតិចតួច គឺជាចំណុចខ្វះខាតបន្ថែម។ ការសន្ទនាកាន់តែច្រើន ជាពិសេសជាមួយមន្ត្រីរាជរដ្ឋាភិបាលអាចផ្តល់ពន្លឺកាន់តែច្រើនលើរបកគំហើញ និងពង្រឹងផែនការសកម្មភាពបន្ថែម។

បច្ចុប្បន្ន មានអង្គការមិនមែនរដ្ឋាភិបាល (NGOs) និងសមាគមដែលដំណើរការ ប្រហែល ១.៣៥០ នៅកម្ពុជា។ ចំណាយសរុបប្រចាំឆ្នាំដោយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងក្នុងស្រុកនៅកម្ពុជា ត្រូវបានប៉ាន់ស្មានថាមានចំនួន ៦០០-៧០០ លានដុល្លារអាមេរិក និងមានលក្ខណៈប្រដូចប្រសងនឹងចំណាយសរុបរបស់រាជរដ្ឋាភិបាលលើសេវាកម្មសង្គម (គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ឆ្នាំ២០១៣)។ សិទ្ធិបង្កើតអង្គការសង្គមស៊ីវិលនៅកម្ពុជា ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញកម្ពុជា ហើយពលរដ្ឋអាចមាន និងប្រើសិទ្ធិនេះក្នុងការអនុវត្តជាក់ស្តែង ។ ក្រមរដ្ឋប្បវេណីកម្ពុជាដ៏វែង និងស្មុគ្រស្មាញឆ្នាំ២០០៧ កំណត់របៀបដែលអង្គការមិនមែនរដ្ឋាភិបាល និងសមាគមអាចត្រូវបានបង្កើត និងចុះបញ្ជី ហើយបទប្បញ្ញត្តិទាំងឡាយក្នុងក្រមនេះ ត្រូវបានបំពេញបន្ថែមដោយច្បាប់ បទប្បញ្ញត្តិ និងប្រកាសបន្ថែមផ្សេងៗ។ លក្ខខ័ណ្ឌចុះបញ្ជី ជាទូទៅ មានលក្ខណៈស្មុគ្រស្មាញ និងពិបាក។ ក្នុងការអនុវត្តជាក់ស្តែង ឆន្ទានុសិទ្ធិរបស់រាជរដ្ឋាភិបាល ដើរតួនាទីដ៏ធំមួយក្នុងការកំណត់ការចុះបញ្ជី។ ប៉ុន្តែ បុគ្គលិកក្រសួងមហាផ្ទៃ ជាធម្មតា គឺមានដើម្បីជួយសម្រួលកិច្ចដំណើរការការចុះបញ្ជី ជាថ្នូរនឹងថ្លៃបង់ក្រៅផ្លូវការ។

បច្ចុប្បន្ន ច្បាប់ពាក់ព័ន្ធដែលអាចអនុវត្តបានចំពោះសង្គមស៊ីវិលនៅកម្ពុជា រួមមាន*ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧ ច្បាប់ស្តីពីសារពើពន្ធឆ្នាំ២០០៤ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ឆ្នាំ២០០៩ ច្បាប់ប្រឆាំងអំពើពុករលួយឆ្នាំ២០១០* និង*ច្បាប់ស្តីពីការប្រឆាំងភេរវកម្មឆ្នាំ២០០៧*។ លក្ខខ័ណ្ឌរដ្ឋបាលសំខាន់ៗដែលប៉ះពាល់អង្គការសង្គមស៊ីវិល រួមមានដូចខាងក្រោម៖

- ចុះហត្ថលេខាកិច្ចព្រមព្រៀងគម្រោងយ៉ាងហោចណាស់ជាមួយក្រសួងមួយ - ចំណុចនេះមានលក្ខណៈសំខាន់ជាពិសេសសម្រាប់អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ដែលមិនអាចចុះបញ្ជីបានដោយមិនមានកិច្ចព្រមព្រៀងមួយ
- រាយការណ៍សកម្មភាពគម្រោងជូនរាជរដ្ឋាភិបាល
- ប្រកាសទ្រព្យសម្បត្តិ (ប៉ះពាល់តែបុគ្គលិកជាន់ខ្ពស់ប៉ុណ្ណោះ)
- សុំការអនុញ្ញាតដើម្បីធ្វើការជួបជុំជាសាធារណៈ និង

- របាយការណ៍អំពីការផ្លាស់ប្តូរការងារបុគ្គលិកជាន់ខ្ពស់ សមាសភាពនៃក្រុមប្រឹក្សាភិបាល និង ការផ្លាស់ប្តូរទីតាំងការិយាល័យ។

ក្នុងការអនុវត្តជាក់ស្តែង លក្ខខ័ណ្ឌបែបនេះជាច្រើន លើកលែងតែការសុំការអនុញ្ញាតសម្រាប់ការជួបប្រជុំ មិនត្រូវបានបំពេញដោយអង្គការសង្គមស៊ីវិលទេ។ អង្គការសង្គមស៊ីវិល មិនស្ថិតក្រោមសវនកម្ម ឬអធិការកិច្ចរបស់រាជរដ្ឋាភិបាលទេ។ ការត្រួតពិនិត្យរបស់រាជរដ្ឋាភិបាលលើអង្គការសង្គមស៊ីវិលគឺមានលក្ខណៈល្មម។ មានករណីកត់ត្រាទុកមួយចំនួនដែលអង្គការសង្គមស៊ីវិល ជាពិសេសអង្គការដែលជំរុញសិទ្ធិមនុស្ស ជួបប្រទះសម្ពាធខ្លាំងឲ្យបញ្ឈប់សកម្មភាពពួកគេ ហើយក្នុងករណីខ្លះសកម្មភាពពួកគេត្រូវបានបញ្ឈប់ដោយមន្ត្រីមួយចំនួនរបស់រាជរដ្ឋាភិបាល។ គេឃើញមានការបារម្ភកាន់តែច្រើនឡើងក្នុងចំណោមអ្នកឆ្លើយមួយចំនួន ដែលថាបុគ្គលខ្លះក្នុងរាជរដ្ឋាភិបាលកម្ពុជាចង់បន្តប្រើសម្ពាធ ជាមធ្យោបាយមួយនៃការត្រួតត្រាលើសកម្មភាពរបស់អង្គការសង្គមស៊ីវិលមួយចំនួន។

អង្គការសង្គមស៊ីវិលកម្ពុជា ពឹងផ្អែកយ៉ាងច្រើនលើហិរញ្ញប្បទានឥតសំណង និងអំណោយអន្តរជាតិ ហើយបរិស្ថានគតិយុត្តិសម្រាប់ទទួលបានមូលនិធិ អាចចាត់ទុកបានថាមានលក្ខណៈអនុញ្ញាត។ ឧបសគ្គមិនមែនផ្អែកច្បាប់ជាច្រើនចំពោះការទទួលមូលនិធិ ត្រូវបានផ្សារភ្ជាប់ជាមួយនឹងការថយចុះនៃការមានមូលនិធិអន្តរជាតិ ដែលជាហេតុបង្កើនការប្រកួតប្រជែងរកមូលនិធិទាំងនេះ និងសមត្ថភាពទាបជាទូទៅក្នុងការស្វែងរកមូលនិធិ ក្នុងចំណោមអង្គការសង្គមស៊ីវិលក្នុងស្រុក។ ជាការឆ្លើយតបទៅនឹងបញ្ហាទាំងនេះ អង្គការសង្គមស៊ីវិលកំពុងចូលរួមកាន់តែច្រើនឡើងក្នុងសហគ្រាសសង្គម។ សកម្មភាពមនុស្សធម៌ក្នុងស្រុកគឺមានភាពស្ដួចស្ដើង ហើយហិរញ្ញប្បទានឥតសំណងពី រាជរដ្ឋាភិបាលគឺជារឿងមិនធម្មតា ថ្វីបើកំពុងកើនឡើងក្តី។

មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ចែងថាប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការជួបប្រជុំ។ ប៉ុន្តែ សារព័ត៌មាននៅកម្ពុជាត្រូវបានគេយល់ថា ‛មិនមានសេរីភាព’ ហើយលំហសម្រាប់សេរីភាពបញ្ចេញមតិបាននិងកំពុងរួញចុះតាំងពី ឆ្នាំ២០១២។ ទូរទស្សន៍ និងកាសែត ត្រូវបានគ្រប់គ្រងភាគច្រើនដោយគណបក្សនយោបាយដែលមានឥទ្ធិពលគ្របដណ្តប់។ ប៉ុន្តែ មាននិយ័តកម្មតិចតួចប៉ុណ្ណោះលើអ៊ីនធឺណេត។ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ និង សំណើច្បាប់ថ្មីប្រឆាំងអ៊ីធឺណេត (នឹង) ផ្តល់ក្របខ័ណ្ឌគតិយុត្តិសម្រាប់សេរីភាពបញ្ចេញមតិនៅកម្ពុជា ដោយដោះស្រាយបញ្ហានៃការបរិហារកេរ្តិ៍ ការផ្តល់ព័ត៌មានមិនពិត និងការញុះញង់។ ក្រមព្រហ្មទណ្ឌនេះរារាំងយ៉ាងច្រើនចំពោះសេរីភាពបញ្ចេញមតិ ហើយតួអង្គសង្គមស៊ីវិលមួយចំនួនបារម្ភថា ច្បាប់ប្រឆាំងការគ្រប់គ្រងប្រព័ន្ធអ៊ីនធឺណេតក៏នឹងមានលក្ខណៈរារាំងផងដែរ។ ច្បាប់ប្រឆាំងអំពើពុករលួយ ឆ្នាំ២០១០ រឹតត្បិតបន្ថែមទៀតលើសេរីភាពធ្វើការតវ៉ា។ ប៉ុន្តែ អង្គការសង្គមស៊ីវិលហាក់ដូចជាយល់ដោយខ្លួនឯងអំពីអ្វីដែលអាច និងមិនអាចនិយាយ ដោយប្រើចំណេះដឹងខាងវប្បធម៌ ដើម្បីអនុវត្តការវិនិច្ឆ័យអំពីយុទ្ធសាស្រ្តស៊ូមតិនានា។ អ្នកផ្តល់សម្ភាសន៍ យល់ថាការទិតៀនរបស់ពួកគេ ចំពោះរាជរដ្ឋាភិបាល – នៅពេលដែលស្ថិតក្នុង

ព្រំដែនមិនមានការបញ្ជាក់ក្នុងកម្រិតមួយ – ជាទូទៅត្រូវបានយោគយល់។ អង្គការសង្គមស៊ីវិលកំពុងធ្វើយុទ្ធនាការ ដើម្បីសុំឲ្យរាជរដ្ឋាភិបាលដាក់ឲ្យអនុវត្តច្បាប់ស្តីពីសេរីភាពទទួលព័ត៌មាន។

*ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីឆ្នាំ២០០៩* កំណត់ថាបុគ្គល ឬអង្គការសង្គមស៊ីវិលដែលគ្រោងធ្វើបាតុកម្ម/ការតវ៉ាត្រូវបានតម្រូវឲ្យជូនដំណឹង (ក្នុងការអនុវត្តជាក់ស្តែង សុំការអនុញ្ញាតពី) រាជរដ្ឋាភិបាល ប្រាំថ្ងៃមុនពេលធ្វើបាតុកម្ម/ការតវ៉ា។ ក្នុងករណីខ្លះ បុគ្គលពីកម្លាំងសន្តិសុខមូលដ្ឋាន និងកងកម្លាំងសន្តិសុខជាតិ ក្នុងកិច្ចសហប្រតិបត្តិការជាមួយ អាជ្ញាធររដ្ឋាភិបាល ថ្នាក់មូលដ្ឋាន (និងថ្នាក់ជាតិ) មួយចំនួន បានធ្វើសកម្មភាព ដើម្បីរឹតត្បិតសេរីភាពនៃការធ្វើចលនា និងសេរីភាពខាងការជួបប្រជុំរបស់ពលរដ្ឋ។ ឧទាហរណ៍នៃចំណុចនេះ រួមមានការបដិសេធមិនផ្តល់ការអនុញ្ញាតចំពោះការតវ៉ាដោយសន្តិវិធី ការអះអាងថាសមាជិកសហគមន៍ត្រូវមានការអនុញ្ញាតដើម្បីធ្វើដំណើរ សូម្បីតែពីភូមិមួយទៅភូមិមួយ ការតាមដានការជួបប្រជុំដោយនគរបាល និងអាជ្ញាធររដ្ឋ ការថតរូបអ្នកចូលរួមការជួបប្រជុំ និងការសួរឈ្មោះ និងព័ត៌មានទំនាក់ទំនងរបស់អ្នកចូលរួមការជួបប្រជុំ ការរំខានការជួបប្រជុំដោយនគរបាល និងការប្រើយុទ្ធវិធីបង្ខិតបង្ខំ ដើម្បីពាក់ព័ន្ធជាមួយសហគមន៍ទាំងឡាយដែលចូលរួមជាមួយអង្គការមិនមែនរដ្ឋាភិបាល[1]។

ទំនាក់ទំនងរវាងរាជរដ្ឋាភិបាល និងសង្គមស៊ីវិលនៅកម្ពុជា មានលទ្ធភាពកែលម្អច្រើនក្នុងវិស័យនៃទំនុកចិត្ត ជំនឿ ការគោរព និងបដិការ។ ទោះជាយ៉ាងណាក្តី ទំនាក់ទំនងមានលក្ខណៈខុសគ្នាយ៉ាងច្រើនអាស្រ័យលើប្រភេទនៃអង្គការសង្គមស៊ីវិល សមាជិក និងទីកន្លែងរបស់អង្គការ ប្រភេទការងារដែលអង្គការអនុវត្ត (ពោលគឺ ការតស៊ូមតិ ឬការផ្តល់សេវាកម្ម)។ ប្រភេទនៃទំនាក់ទំនងក៏មានលក្ខណៈខុសគ្នាផងដែរ អាស្រ័យលើកម្រិត នៃរាជរដ្ឋាភិបាល ដែលអង្គការសង្គមស៊ីវិលពាក់ព័ន្ធ។ អង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធក្នុងការផ្តល់សេវាកម្មក្នុងវិស័យនានា ដូចជាសុខភាព ការអភិវឌ្ឍកសិកម្ម មនុស្សធម៌ និងការអប់រំ ជាទូទៅ មានទំនាក់ទំនង ជាមួយរាជរដ្ឋាភិបាលប្រសើរជាង។ អង្គការសង្គមស៊ីវិលដែលជំរុញប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ច្រើនមានការលំបាកច្រើនជាងក្នុងការកំណត់ចំណុចរួម និងការយល់គ្នាជាមួយរាជរដ្ឋាភិបាល។ ទំនាក់ទំនងរវាងសង្គមស៊ីវិល និងរាជរដ្ឋាភិបាល ច្រើនមានលក្ខណៈរឹងមាំ និងមានប្រសិទ្ធភាពជាង នៅថ្នាក់ខេត្ត ស្រុក និងឃុំ ប៉ុន្តែមានលក្ខណៈខ្សោយជាងនៅកម្រិតជាតិ។ កិច្ចប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិលនៅថ្នាក់ក្រោមជាតិ ទទួលរងឥទ្ធិពលពីទំនាក់ទំនងរបស់ពួកគេជាមួយមន្ត្រីមូលដ្ឋានដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត និងការបកស្រាយរបស់មន្ត្រីទាំងនោះ អំពីក្របខ័ណ្ឌគតិយុត្តិដែលគ្រប់គ្រងសកម្មភាពរបស់អង្គការសង្គមស៊ីវិល។ ឯកសារយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល មានសារចម្រុះអំពីតួនាទី និងគុណតម្លៃរបស់អង្គការសង្គមស៊ីវិល ហើយក្នុងការអនុវត្តជាក់ស្តែង គេនៅឃើញមានលទ្ធភាពច្រើនសម្រាប់សម្លេងកាន់តែច្រើនថែមទៀតពីសង្គមស៊ីវិលនៅក្នុងការសន្ទនា និងការបង្កើតគោលនយោបាយសាធារណៈ។

[1] http://www.icnl.org/research/monitor/cambodia.html, accessed 28 February 2013

សម្ព័ន្ធភាពនៃអង្គការសង្គមស៊ីវិល គឺជារឿងធម្មតានៅកម្ពុជា។ កិច្ចសហប្រតិបត្តិការក្នុងចំណោមអង្គការសង្គមស៊ីវិល កំពុងកើនឡើង ប៉ុន្តែ ជម្រៅនៃកិច្ចសហប្រតិបត្តិការជាទូទៅនៅមានកម្រិតទាប។ ម្យ៉ាងទៀត កម្រិតនៃកិច្ចសហប្រតិបត្តិការ មានលក្ខណៈខុសគ្នាយ៉ាងច្រើន តាមវិស័យ។ ជាទូទៅ កិច្ចសហប្រតិបត្តិការអន្តរវិស័យមានកម្រិតទាប។ ក្រុមអង្គការសមាជិកភាពមានយន្តការតិចតួចបំផុតសម្រាប់ធ្វើការវាយតម្លៃសមិទ្ធកម្មការងារ និងឱកាសមានកម្រិតក្នុងការទទួលនិងដោះស្រាយបណ្តឹងរបស់សមាជិក។ ពុំមានការត្រួតពិនិត្យរបស់រាជរដ្ឋាភិបាលលើភាពជាដៃគូ និងសម្ព័ន្ធភាព។

ច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាលនិងសមាគម ត្រូវបានស្នើឡើង និងស្ថិតក្នុងសេចក្តីព្រាងទីបួន។ អង្គការសង្គមស៊ីវិលជាច្រើនយល់ថាសេចក្តីព្រាងច្បាប់ថ្មីស្តីពីអង្គការមិនមែនរដ្ឋាភិបាល និងសមាគមនេះ នឹងបង្កើនតួនាទីរបស់រាជរដ្ឋាភិបាល ក្នុងការត្រួតពិនិត្យលើអង្គការសង្គមស៊ីវិល និងអនុញ្ញាតឲ្យមានការត្រួតត្រាច្រើនពេកដោយរាជរដ្ឋាភិបាលលើសកម្មភាពអង្គការសង្គមស៊ីវិល។ ក្នុងលក្ខណៈវិជ្ជមានជាង ការបោះឆ្នោតជាតិនៅខែកក្កដា ឆ្នាំ២០១៣ ប្រហែលជាអាចជួយជំរុញការពាក់ព័ន្ធក្នុងលក្ខណៈស្ថាបនារវាងរាជរដ្ឋាភិបាល និងសង្គមស៊ីវិល ដូចដែលអ្នកផ្តល់សម្ភាសន៍មួយចំនួនបានព្យាករ។ ប៉ុន្តែ ប្រការដែលថាតើរាជរដ្ឋាភិបាលកម្ពុជានឹងអាចលើកស្ទួយបន្ថែមទៀតនូវបរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិលនៅកម្ពុជា បានដល់កម្រិតណា គឺត្រូវរង់ចាំមើលសិន។

# ផ្នែកទី១: សេចក្តីផ្តើម

សង្គមស៊ីវិល មិនត្រឹមតែស្ថិតក្រោមក្របខ័ណ្ឌគតិយុត្តិ និងបទបញ្ញត្តិប៉ុណ្ណោះទេ ប៉ុន្តែ ថែម ទាំងផ្នែកសេដ្ឋកិច្ច នយោបាយ វប្បធម៌ សាសនា និងបរិយាកាសសង្គម សម្រាប់កិច្ចប្រតិបត្តិការ។ ការវាយតម្លៃពេញលេញមួយ លើបរិយាកាសមួយសម្រាប់កិច្ចប្រតិបត្តិការសង្គមស៊ីវិលនឹងពិនិត្យមើល គ្រប់ទិដ្ឋភាពទាំងនេះ ពោលគឺ សេដ្ឋកិច្ច នយោបាយ វប្បធម៌ សាសនា និងសង្គម ក្នុងកិច្ចប្រឹងប្រែង មួយដើម្បីជំរុញការយល់ដឹងពីសក្តានុពល និងជោគជ័យនៃសង្គមស៊ីវិល។

របាយការណ៍នេះ ផ្តោតលើក្របខ័ណ្ឌគតិយុត្តិ បទបញ្ញត្តិ និងបរិយាកាសគោលនយោបាយ ដែល អង្គការសង្គមស៊ីវិលធ្វើប្រតិបត្តិការ ដោយសារប្រការនេះគឺជាគន្លឹះសម្រាប់លទ្ធភាព ចុះបញ្ជី ប្រតិបត្តិការ ទទួលបានធនធាន និងចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងការតស៊ូមតិ ដែលចំណុច ទាំងអស់នេះ រួមចំណែកដល់លទ្ធភាពរីកលូតលាស់ និងទទួលបានជោគជ័យរបស់សង្គមស៊ីវិល។ លើសពីនេះ ច្បាប់ និងបទប្បញ្ញត្តិគ្រប់គ្រងអង្គការសង្គមស៊ីវិល និងរបៀបត្រូវបានអនុវត្ត ដែលបង្កើត បរិយាកាសអំណោយផលមួយផ្នែករបស់សង្គមស៊ីវិល ព្រមទាំងកំណត់កត្តាសំខាន់ៗផ្សេងទៀតជា ច្រើនៈ លទ្ធភាពរបស់អង្គការសង្គមស៊ីវិលមួយក្នុងការទាក់ទង និងចូលរួមជាមួយអង្គការផ្សេងទៀត ការចូលរួមជួបប្រជុំដោយសន្តិវិធី ការសុំលើកលែងពន្ធ ការចូលរួមសកម្មភាពមនុស្សធម៌ និងការ ទទួលព័ត៌មាន។ កត្តាទាំងអស់នេះ ក៏ដូចជា ការទំនាក់ទំនងរវាងអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាល របស់ខ្លួន ជួយកំណត់ប្រភេទនៃបរិយាកាសអំណោយផលសម្រាប់សង្គមស៊ីវិល ក្នុងប្រទេសមួយ។ គួរអោយកត់សំគាល់ ពេលដាក់កត្តាទាំងនេះបញ្ចូលគ្នា វាមានឥទ្ធិពលខ្លាំងលើទស្សនៈរបស់ សាធារណជន - ពោលគឺ ដល់សសៃឈាមនៃសង្គមស៊ីវិលដែលដំណើរការល្អមួយ - ដល់ការអនុវត្ត ការងារសំខាន់ៗរបស់សង្គមស៊ីវិល។

ដើម្បីកែលម្អ និងពង្រឹងវិស័យសង្គមស៊ីវិលនៃប្រទេសមួយ វាគឺជាប្រការសំខាន់ដែលត្រូវវាយ តម្លៃស្ថានភាពបច្ចុប្បន្ននៃបរិយាកាសអំណោយផលលើវិស័យនេះឲ្យបានត្រឹមត្រូវ និងមិនលំអៀង។ ការវាយតម្លៃថ្នាក់ជាតិមួយចំនួន លើបរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិល ក្នុង ប្រទេសជាច្រើន ត្រូវបានបង្កើតឡើងរួមគ្នាដោយអង្គការ CIVICUS: សម្ព័ន្ធភាពពិភពលោកសម្រាប់ ការចូលរួមរបស់ប្រជាពលរដ្ឋ និងមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ច្បាប់ស្តីពី ការមិនយកចំណេញ (ICNL)។ ជាផ្នែកមួយនៃកម្មវិធីគំនិតផ្តួចផ្តើមលំហាពលរដ្ឋ (Civic Space Initiative program) និង ភាព ជាដៃគូជាមួយ មាត្រា ១៩ (ARTICLE19) និង ចលនាពិភពលោកដើម្បីប្រជាធិបតេយ្យ (World Movement for Democracy) ដោយជំនួយឧបត្ថម្ភពីទីភ្នាក់ងារអភិវឌ្ឍអន្តរជាតិស៊ុយអែដ អង្គការ CIVICUS និង ICNL បានផលិតរួមគ្នានូវការណែនាំសម្រាប់ស្រាវជ្រាវ ដែលបង្ហាញពីរបៀបក្នុងការ វាយតម្លៃនេះ។ ការវាយតម្លៃថ្នាក់ជាតិទាំងនេះ គឺមានបំណងដឹកនាំធ្វើដោយស្ថាប័នក្នុងស្រុក ផ្អែកលើ ទិន្នន័យបឋមដែលត្រូវបានប្រមូលនៅថ្នាក់មូលដ្ឋាន និងធ្វើការផ្ទៀងផ្ទាត់ដោយកិច្ចដំណើរការឯកភាព

ពីភាគីពាក់ព័ន្ធ ដែលករណី សម្រាប់ប្រទេសកម្ពុជា មានទម្រង់ជាកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ។ បញ្ហាទាំងឡាយដែលបានកំណត់ក្នុងបរិយាកាសអំណោយផលសម្រាប់សង្គមស៊ីវិល លើកឡើងក្នុងរបាយការណ៍នេះ គឺត្រូវបានលើកមកពិភាក្សាក្នុងកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិមួយដែលប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែវិច្ឆិកា ព្រមទាំងកំណត់យុទ្ធសាស្ត្រសំខាន់ៗ ដើម្បីរួមដោះស្រាយបញ្ហាប្រឈមសំខាន់ៗទាំងនេះ។ ចុងក្រោយ គោលបំណងនៃការវាយតម្លៃថ្នាក់ជាតិអាចជាឈ្នាន់សម្រាប់ឲ្យតួអង្គក្នុងស្រុកកែលម្អលើគតិយុត្តិ និងបរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិល។ តាមការប្រមូលភស្តុតាងលើបញ្ហាពាក់ព័ន្ធ និងជំរុញការសន្ទនាអំពីរបៀបដែលបញ្ហាទាំងនេះ អាចធ្វើការដោះស្រាយ ការវាយតម្លៃថ្នាក់ជាតិ ត្រូវបានរំពឹងថានឹងជួយសម្រួលដល់ការពង្រឹងសង្គមស៊ីវិល និងការកែលម្អទំនាក់ទំនងរវាងសង្គមស៊ីវិល និងរាជរដ្ឋាភិបាល។ មានផែនការសកម្មភាពអមមួយដាច់ដោយឡែកសម្រាប់របាយការណ៍នេះ។

## គោលបំណងនៃការស្រាវជ្រាវ

របាយការណ៍នេះ ទទួលបន្ទុកដោយ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា។ របាយការណ៍គឺផ្អែកលើការចុះប្រមូលព័ត៌មានផ្ទាល់ និងការស្រាវជ្រាវឯកសារ។ គោលបំណងចំនួនបីនៃការស្រាវជ្រាវត្រូវបានកំណត់ដូចខាងក្រោម:

១. ក្របខ័ណ្ឌគតិយុត្តិ បទប្បញ្ញត្តិ និងបរិយាកាសគោលនយោបាយ ដែលមានឥទ្ធិពលលើលទ្ធភាពរបស់សង្គមស៊ីវិលនៅកម្ពុជាក្នុងការបំពេញមុខងារនៅកម្រិតជាតិ និងក្រោមជាតិ
២. បញ្ហា ចំណុចខ្សោយ និងបញ្ហាប្រឈមសំខាន់ៗនៃក្របខ័ណ្ឌគតិយុត្តិ បទប្បញ្ញត្តិ និងបរិយាកាសគោលនយោបាយមានឥទ្ធិពលលើ លទ្ធភាពរបស់សង្គមស៊ីវិលកម្ពុជាក្នុងការបំពេញមុខងារនៅកម្រិតជាតិ និងក្រោមជាតិ
៣. វិធីជំនះបញ្ហាប្រឈមនៃក្របខ័ណ្ឌគតិយុត្តិ បទបញ្ញត្តិ និងគោលនយោបាយសម្រាប់សង្គមស៊ីវិលនៅកម្ពុជា ដើម្បីបង្កើនលំហប្រជាធិបតេយ្យនៅកម្ពុជា

គោលដៅទីបី មិនត្រូវបានបំពេញដោយរបាយការណ៍នេះទេ ប៉ុន្តែ ដោយផែនការសកម្មភាពអមជាមួយ។

## និយមន័យ

ក្នុងន័យទូលាយ បរិយាកាសអំណោយផលសម្រាប់តួអង្គសង្គមសំដៅលើ "ស្ថានភាពដែលនៅក្នុងនោះ សង្គមស៊ីវិលធ្វើការ។"[2] បរិយាកាសអំណោយផលមួយសម្រាប់តួអង្គសង្គម គឺផ្អែកលើការគោរព និងការលើកជ្រោងសិទ្ធិជាមូលដ្ឋាន ដែលអនុញ្ញាតឲ្យប្រជាពលរដ្ឋរៀបចំ និងចូលរួមក្នុងការអភិវឌ្ឍ។ ជាឧទាហរណ៍ ចំណុចនេះរួមមានការធានានូវ៖

- សេរីភាពខាងការបង្កើតសមាគម និងសេរីភាពខាងការជួបប្រជុំ
- ការទទួលស្គាល់ស្របច្បាប់ដែលជួយសម្រួលការងាររបស់អង្គការសង្គមស៊ីវិល
- សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ
- សេរីភាពនៃការធ្វើចលនា សិទ្ធិចល័ត និងសិទ្ធិធ្វើដំណើរ
- សិទ្ធិធ្វើប្រតិបត្តិការដោយគ្មានការជ្រៀតជ្រែករបស់រដ្ឋ និង
- លទ្ធភាពស្របច្បាប់ក្នុងការស្វែងរក និងទទួលធនធានចាំបាច់ ជាការគាំទ្រចំពោះតួនាទីស្របច្បាប់ក្នុងការអភិវឌ្ឍ។

គោលបំណងនៃការវាយតម្លៃនេះ អង្គការសង្គមស៊ីវិល (CSO) ត្រូវបានកំណត់និយមន័យជាការចងក្រងជាប្រព័ន្ធមួយនៃបុគ្គលដែលឯករាជ្យពីរដ្ឋាភិបាល និងមិនបំពេញមុខងារជាអាជីវកម្មដើម្បីរកចំណេញ[3]។ ជាទូទៅ អង្គការសង្គមស៊ីវិលនៅកម្ពុជា ត្រូវបានគេយល់ថាមានរាប់បញ្ចូលសមាគមបែបប្រពៃណី អង្គការសហគមន៍មូលដ្ឋាន 'ទំនើប' អង្គការមិនមែនរដ្ឋាភិបាល (NGOs) សហជីព អង្គការយុវជន ក៏ដូចជា ក្រុមធានាគារខួរក្បាល (think tanks) និងអង្គការស្រាវជ្រាវឯករាជ្យ គ្រឹះស្ថានឧត្តមសិក្សាឯករាជ្យ សមាគមនិស្សិត អង្គការនិងសមាគមសារព័ត៌មានឯករាជ្យ និងសមាគមអាជីវកម្ម (Bañez-Ockelford ឆ្នាំ២០១១)។

អង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា ត្រូវបានបង្កើតជាប្រភេទអង្គការខុសៗគ្នា[4] – អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិត្រូវបានគ្រប់គ្រងដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រីឯអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអង្គការសហគមន៍ (CBOs) ត្រូវបានគ្រប់គ្រងដោយក្រសួងមហាផ្ទៃ ឬគណៈរដ្ឋមន្ត្រី។ ម្យ៉ាងទៀត អង្គការសហគមន៍មួយចំនួនហាក់បីដូចជាអាចចុះបញ្ជីជាមួយ – និង ត្រូវបានគ្រប់គ្រងដោយ – រដ្ឋាភិបាលថ្នាក់ខេត្ត ទោះបីជាគេមិនដឹងច្បាស់ថាតើក្របខ័ណ្ឌគតិយុត្តិអ្វីគ្រប់គ្រងចំណុចនេះ។ របាយការណ៍នេះផ្តោតជាពិសេសលើបទពិសោធន៍របស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអង្គការសហគមន៍។

---

[2] https://civicus.org/eei/downloads/Civicus_EEI%20REPORT%202013_WEB_FINAL.pdf, accessed 28 November 2013

[3] It is acknowledged that some civil society conduct social enterprises, which have a motive of generating profits that directly benefit community members.

[4] More information about different organisational types in Cambodia is included in Appendix 3.

អង្គការ CIVICUS និងមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ច្បាប់ស្តីពីការមិនយកចំណេញ បានកំណត់ទិដ្ឋភាពចំនួនដប់នៃក្របខ័ណ្ឌគតិយុត្តិ បទបញ្ញត្តិ និងបរិយាកាសគោលនយោបាយសម្រាប់អង្គការសង្គមស៊ីវិល[5]។ ទិដ្ឋភាពចំនួនប្រាំពីរនៃទិដ្ឋភាពទាំងនេះ ត្រូវបានជ្រើសរើសដោយគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា សម្រាប់ការសិក្សានៅកម្ពុជា ដែលរួមមាន (១) ការបង្កើត (២) កិច្ចប្រតិបត្តិការ (៣) លទ្ធភាពទទួលធនធាន (៤) ការបញ្ចេញមតិ (៥) ការជួបប្រជុំដោយសន្តិវិធី (៦) ទំនាក់ទំនងរវាងរាជរដ្ឋាភិបាលនិងសង្គមស៊ីវិល និង (៧) កិច្ចសហប្រតិបត្តិការនិងសម្ព័ន្ធភាពអង្គការសង្គមស៊ីវិល។ ទិដ្ឋភាពចំនួនបីដែលមិនត្រូវបានពិនិត្យមើលក្នុងការវាយតម្លៃនេះ រួមមាន សេរីភាពអ៊ីធឺណេត ការយកពន្ធ និងលទ្ធភាពទទួលព័ត៌មាន។ ទោះជាយ៉ាងណាក្តី ព័ត៌មានអំពីទិដ្ឋភាពទាំងបីនេះត្រូវបានដាក់បញ្ចូលក្នុងផ្នែកផ្សេងទៀតនៃរបាយការណ៍។ ទិដ្ឋភាពទាំងប្រាំពីរដែលបានវាយតម្លៃនៃបរិយាកាសអំណោយផលសម្រាប់សង្គមស៊ីវិលនៅកម្ពុជា ត្រូវបានកំណត់ន័យដូចខាងក្រោម ៖

**(១) ការបង្កើត**

ការបង្កើត សំដៅលើសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការចងក្រងខ្លួនឯងទៅជាក្រុមដែលអាចជជែកពិភាក្សា បង្កើតសមាគម និងព្យាយាមជះឥទ្ធិពលលើសង្គមឲ្យកាន់តែទូលាយ។ សិទ្ធិនេះ ត្រូវបានគេស្គាល់ជាផ្លូវការថាជាសេរីភាពខាងការបង្កើតសមាគម។ សេរីភាពខាងការជួបប្រជុំ ត្រូវបានការពារនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស - មាត្រា ២០ និង២៣ – និង អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ – មាត្រា ២២។ កម្ពុជាគឺជាប្រទេសហត្ថលេខីមួយនៃលិខិតូបករណ៍ទាំងពីរនេះ និងធានាសេរីភាពខាងការជួបប្រជុំនៅក្នុងរដ្ឋធម្មនុញ្ញ (មាត្រា ៤១)។ ភាពងាយស្រួលដែលពលរដ្ឋកម្ពុជាអាចបង្កើតសមាគមនិងចុះបញ្ជីជាក្រុមសង្គមស៊ីវិលជាចំណាប់អារម្មណ៍នៅទីនេះ។

**(២) កិច្ចប្រតិបត្តិការ**

សម្រាប់គោលបំណងនៃការស្រាវជ្រាវនេះ កិច្ចប្រតិបត្តិការសំដៅលើលទ្ធភាពរបស់អង្គការសង្គមស៊ីវិលក្នុងការធ្វើសកម្មភាពរបស់ខ្លួន ដោយគ្មានការជ្រៀតជ្រែកពីរដ្ឋ។ ការត្រួតពិនិត្យសមស្របរបស់រាជរដ្ឋាភិបាលលើអង្គការសង្គមស៊ីវិល ត្រូវបានទទួលស្គាល់ថាមានសារៈសំខាន់។

**(៣) លទ្ធភាពទទួលធនធាន**

សម្រាប់គោលបំណងនៃការស្រាវជ្រាវនេះ លទ្ធភាពទទួលធនធាន សំដៅលើលទ្ធភាពអង្គការសង្គមស៊ីវិល ក្នុងការទទួលបានមធ្យោបាយផ្នែកហិរញ្ញវត្ថុពីប្រភពផ្សេងៗ ដូចជាពីរាជរដ្ឋាភិបាលកម្ពុជា តាមរយៈហិរញ្ញប្បទានឥតសំណង និងអំណោយអន្តរជាតិ ពីសប្បុរសជន និងតាមរយៈសកម្មភាពរកចំណូលក្នុងមូលដ្ឋាន រួមទាំងសហគ្រាសសង្គម។

---

[5] The Enabling Environment National Assessment (EENA) research guide is currently not publicly available.

### (៤) ការបញ្ចេញមតិ

សិទ្ធិមានសេរីភាពបញ្ចេញមតិ គឺជាសិទ្ធិមនុស្សជាមូលដ្ឋានមួយដែលត្រូវបានការពារដោយមាត្រា ១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងដោយមាត្រា ១៩ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។ សេរីភាពបញ្ចេញមតិ មានសារៈសំខាន់បំផុតចំពោះជីវិតនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស ដោយសារវាគឺជាគ្រឹះដ៏សំខាន់នៃរាល់សិទ្ធិមនុស្សទាំងអស់ រួមទាំងសិទ្ធិចូលរួមក្នុងជីវភាពនយោបាយ ដោយសារចរឹតលក្ខណៈអន្តរវិស័យរបស់វា ក៏ដូចជាតួនាទីរបស់វាក្នុងការធានាឲ្យបាននូវការកាពារសិទ្ធិប្រកបដោយប្រសិទ្ធភាព។ វាគឺជាសេរីភាពមួយដែលរាប់បញ្ចូលសិទ្ធិបញ្ចេញមតិដែលមានលក្ខណៈចម្រូងចម្រាស់ជាសាធារណៈ។ ប្រការដែលថា គំនិតលើកឡើងមិនអាចបញ្ជាក់ លើការ ការពារបុគ្គលម្នាក់ក្នុងការសម្តែងមតិនោះទេ។ ប៉ុន្តែ សេរីភាពបញ្ចេញមតិមិនមែនរាប់បញ្ចូលត្រឹមតែសិទ្ធិសម្តែងមតិប៉ុណ្ណោះទេ[6]។ រដ្ឋធម្មនុញ្ញកម្ពុជាធានាសេរីភាពបញ្ចេញមតិក្នុងមាត្រា ៤១។

### (៥) ការជួបប្រជុំដោយសន្តិវិធី

ការជួបប្រជុំដោយសន្តិវិធី គឺជាបច្ចេកស័ព្ទទូលាយមួយដែលគ្របដណ្តប់លើការប្រមូលផ្តុំគ្រប់ប្រភេទទាំងអស់ រួមទាំងការធ្វើបាតុកម្មដោយសន្តិវិធី។ ដូចបានលើកឡើងខាងលើ សិទ្ធិខាងការជួបប្រជុំដោយសន្តិវិធី គឺជាសេរីភាពជាមូលដ្ឋានមួយដែលត្រូវបានធានាស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ពោលគឺ ស្របតាម មាត្រា ២០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) ស្របតាមមាត្រា ២១ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (ICCPR) និងមាត្រា ១៥ នៃអនុសញ្ញាស្តីពីសិទ្ធិរបស់កុមារ។ វិធានទូទៅក្រោមមាត្រា ២១ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គឺថាការរឹតត្បិតណាមួយលើសេរីភាពនេះ ត្រូវបានហាមឃាត់ លុះត្រាតែមានចែងដោយច្បាប់ ដែលត្រូវរងការសាកល្បងដ៏តឹងរឹងលើភាពចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យនិងត្រូវបានដាក់ឲ្យអនុវត្តតែដើម្បីផលប្រយោជន៍សន្តិសុខជាតិឬ សុវត្ថិភាពនិងសណ្តាប់ធ្នាប់សាធារណៈ ការពារសុខភាពនិងសីលធម៌សាធារណៈ ឬការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃប៉ុណ្ណោះ[7]។

### (៦) ទំនាក់ទំនងរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល

គោលបំណងនៃការស្រាវជ្រាវនេះ ទំនាក់ទំនងរវាងរាជរដ្ឋាភិបាលកម្ពុជា រួមមាន គ្រប់ កម្រិតនៃរដ្ឋាភិបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិល មានសារៈសំខាន់ជាគន្លឹះចំពោះលទ្ធភាព របស់សង្គមស៊ីវិល ក្នុងការរួមចំណែកប្រកបដោយអត្ថន័យដល់ការអភិវឌ្ឍប្រទេសកម្ពុជា។ ការស្រាវជ្រាវនេះ ព្យាយាមចងក្រងជាឯកសារនូវប្រភេទនិងកម្រិតនៃភាពជាដៃគូរវាងរាជរដ្ឋាភិបាល និង សង្គមស៊ីវិល និង របៀបដែលទំនាក់ទំនងនេះត្រូវបានយល់ឃើញដោយភាគីទាំងពីរ។

---

[6] http://www.article19.org/data/files/pdfs/publications/cambodia-gagged-democracy-at-risk-.pdf accessed 17 November 2013

[7] www.cambodia.ohchr.org, accessed 18 November 2013

(៧) **កិច្ចសហប្រតិបត្តិការ និងសម្ព័ន្ធភាពអង្គការសង្គមស៊ីវិល**

សម្រាប់គោលបំណងនៃការស្រាវជ្រាវនេះ កិច្ចសហប្រតិបត្តិការនិងសម្ព័ន្ធភាពអង្គការសង្គមស៊ីវិលសំដៅលើកម្រិតដែលតួអង្គសង្គមស៊ីវិលអាចធ្វើការរួមគ្នាដើម្បីសម្រេចបានគោលដៅរួម ដោយប្រើភាពជាដៃគូផ្លូវការ ឬទម្រង់ផ្សេងទៀតនៃកិច្ចសហការ។

## **រចនាសម្ព័ន្ធនៃរបាយការណ៍**

របាយការណ៍ប្រចាំប្រទេសសម្រាប់កម្ពុជា សង្ខេបព័ត៌មានពាក់ព័ន្ធស្តីពីទិដ្ឋភាពនីមួយៗនៃទិដ្ឋភាពទាំងប្រាំពីរដែលបានជ្រើសរើស ដោយផ្តោតជាពិសេសលើបញ្ហា បញ្ហាប្រឈម និងចំណុចខ្សោយទាំងឡាយពាក់ព័ន្ធនឹងទិដ្ឋភាពនីមួយៗ។ (ផែនការសកម្មភាពអម គួសបង្ហាញសក្តានុពលដំណោះស្រាយចំពោះបញ្ហា បញ្ហាប្រឈម និងចំណុចខ្សោយទាំងនេះ។) របាយការណ៍ប្រចាំប្រទេសសម្រាប់កម្ពុជា ត្រូវបានរៀបចំតាមទិដ្ឋភាពទាំងប្រាំពីរនេះ។ ទិដ្ឋភាពនីមួយៗ បង្កើតជាផ្នែកដោយឡែកមួយនៃរបាយការណ៍ ជាមួយចំណងជើងសំខាន់ៗដែលកំណត់អត្តសញ្ញាណទិដ្ឋភាពមួយណាដែលកំពុងត្រូវបានពិភាក្សា។ ផ្នែកនីមួយៗ ចាប់ផ្តើមជាមួយទស្សនៈរួមមួយនៃបេកគំហើញសំខាន់ៗរួមមានបទប្បញ្ញត្តិច្បាប់ដែលមានលក្ខណៈវិជ្ជមានក៏ដូចជាមានបញ្ហា រួមជាមួយសេចក្តីព្រាងច្បាប់ និងបញ្ហាអនុវត្ត។ បន្ទាប់ពីទស្សនៈរួមនេះ មានការពិភាក្សាស៊ីជម្រៅអំពីច្បាប់ និងបទប្បញ្ញត្តិជាធរមានដែលអាចអនុវត្តបានទាក់ទិននឹងទិដ្ឋភាពនីមួយៗ ដែលបង្ហាញលទ្ធផលនៃការពិភាក្សាជាមួយ អ្នកផ្តល់សម្ភាសន៍ និង អ្នកផ្តល់ព័ត៌មានសំខាន់ៗផ្សេងទៀត អំពីរបៀបដែលការអនុវត្តច្បាប់/បទប្បញ្ញត្តិកើតឡើងក្នុងការអនុវត្តជាក់ស្តែង និងរបៀបដែលនៅក្នុងនោះការអនុវត្តច្បាប់/បទប្បញ្ញត្តិ ត្រូវបានជួបប្រទះដោយអង្គការសង្គមស៊ីវិល និងបុគ្គលរងផលប៉ះពាល់។ ផ្នែកចុងក្រោយនៃជំពូកនីមួយៗ សង្ខេបចំណុចខ្សោយនិងបញ្ហាប្រឈមទាំងឡាយ ពាក់ព័ន្ធនឹងច្បាប់/បទប្បញ្ញត្តិ និងរបៀបដែលនៅក្នុងនោះច្បាប់/បទប្បញ្ញត្តិទាំងនេះត្រូវបានអនុវត្ត និងជួបប្រទះ ក៏ដូចជាចំណុចខ្សោយ ឬបញ្ហាប្រឈមផ្សេងទៀតដែលទាក់ទិននឹងទិដ្ឋភាពនីមួយៗ។ ផ្នែកចុងក្រោយនៃជំពូកនីមួយៗនេះ ត្រូវបានរំពឹងថានឹងផ្តល់មូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍផែនការតស៊ូមតិមួយ ដែលដោះស្រាយចំណុចខ្សោយនិងបញ្ហាប្រឈម។

ផ្នែក/ជំពូកនីមួយៗ បញ្ជាក់យ៉ាងច្បាស់នូវរបៀបដែលព័ត៌មានសម្រាប់ទិដ្ឋភាពនោះត្រូវបានប្រមូល (ទោះជាតាមការស្រាវជ្រាវឯកសារ ការសម្ភាសន៍ និង/ឬវិធីសាស្ត្រផ្សេងទៀតក្តី) និងនៅទីណាអាចអនុវត្តបាន ចំនួនបុគ្គលដែលត្រូវបានសម្ភាសន៍ ឬបានចូលរួមក្នុងការផ្តល់ព័ត៌មាន។

# ផ្នែកទី ២: វិធីសាស្ត្រ

ក្រុមស្រាវជ្រាវបានធ្វើការដោយសហការជាមួយស្ថាប័នឧបត្ថម្ភការស្រាវជ្រាវ ពោលគឺគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) និងដោយប្រយោលជាមួយក្រុមផ្តល់ប្រឹក្សាការងារស្រាវជ្រាវ ដើម្បីកំណត់វិធីសាស្ត្រសមស្របសម្រាប់ប្រមូល និងវិភាគព័ត៌មានចាំបាច់។

វិធីសាស្ត្រមានទម្រង់សំខាន់ៗពីរនៃការបង្កើតទិន្នន័យ ពោលគឺ ការសិក្សាឯកសារ និងការសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ។ ការពិភាក្សាជាមួយក្រុមអ្នកពាក់ព័ន្ធសំខាន់ៗក៏ត្រូវបានគ្រោងផងដែរ ប៉ុន្តែ មិនអាចធ្វើបានតាមពេលវេលាដែលមាន។ ទិន្នន័យត្រូវបានវិភាគតាមប្រធានបទដោយក្រុមស្រាវជ្រាវ ហើយការវិភាគត្រូវបានបញ្ជាក់ដោយស្ថាប័នឧបត្ថម្ភការស្រាវជ្រាវនិងក្រុមផ្តល់ប្រឹក្សា។ សេចក្តីសង្ខេបមុនមួយនៃរបាយការណ៍នេះ ក៏ត្រូវបានពិភាក្សាផងដែរនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិមួយ នៃភាគីពាក់ព័ន្ធសង្គមស៊ីវិលកម្ពុជា (រួមទាំងរាជរដ្ឋាភិបាល និងបណ្តាញសារព័ត៌មាន) ដែលបានប្រព្រឹត្តទៅនៅរាជធានីភ្នំពេញនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣ និងមានអ្នកចូលរួម ៧៥ នាក់។

សម្រាប់ការសិក្សាឯកសារ គេហទំព័រនិងឯកសារបោះពុម្ពផ្សាយផ្សេងៗត្រូវបានសិក្សាដោយក្រុមស្រាវជ្រាវ។ គួរឲ្យកត់សម្គាល់ សមាជិកមួយរូបនៃក្រុមស្រាវជ្រាវបានសរសេរការសិក្សាឯកសារមួយកាលពីពេលមុនដែលពិនិត្យមើលប្រធានបទដូចគ្នា ហើយការសិក្សាឯកសាររបស់លោកស្រីត្រូវបានពិនិត្យមើលរកព័ត៌មានពាក់ព័ន្ធ។

ការសម្ភាសន៍បុគ្គលត្រូវបានធ្វើជាមួយភាគីពាក់ព័ន្ធផ្សេងៗ រួមមានអ្នកគ្រប់គ្រងជាន់ខ្ពស់នៃអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក សម្ព័ន្ធភាពអង្គការមិនមែនរដ្ឋាភិបាល ម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍ សហជីព និងស្ថាប័នសង្គមស៊ីវិលដែលធ្វើការសិក្សាស្រាវជ្រាវ។ អ្នកផ្តល់សម្ភាសន៍ ត្រូវបានជ្រើសរើសរួមគ្នាដោយគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា និងអ្នកពិគ្រោះយោបល់ ដោយពេលធ្វើការគូសផែនទីដ៏ពេញលេញ ដែលនៅក្នុងនោះ ជំនាញនិងបទពិសោធន៍របស់មុខសញ្ញាអ្នកផ្តល់សម្ភាសន៍ផ្សេងៗ ត្រូវបានពិភាក្សានិងផ្ទៀងផ្ទាត់ជាមួយទិដ្ឋភាពទាំងប្រាំពីរដែលបានជ្រើសរើស។ លក្ខណៈវិនិច្ឆ័យជ្រើសរើសចម្បង គឺជំនាញនៅក្នុងទិដ្ឋភាពមួយ ឬច្រើននៃទិដ្ឋភាពទាំងប្រាំពីរនៃបរិយាកាសអំណោយផលនៃការសិក្សា។ អ្នកដែលមានបទពិសោធន៍ល្អៗ និងជ្រុលនិយម ទាំងវិជ្ជមាន និងអវិជ្ជមាន ត្រូវបានផ្តោតយ៉ាងជាក់លាក់នៅក្នុងកិច្ចដំណើរការជ្រើសរើស ថ្វីបើក្រុមស្រាវជ្រាវមិនមែនសុទ្ធតែមានជោគជ័យ ក្នុងការរកបានព័ត៌មានទំនាក់ទំនង និងការអនុញ្ញាតធ្វើការសម្ភាសន៍អ្នកទាំងនេះក្តី។ ក្នុងការជ្រើសរើសអ្នកផ្តល់សម្ភាសន៍ ការពិចារណាសមស្របក៏ត្រូវបានផ្តល់ផងដែរចំពោះការធានាឲ្យបានថាបទពិសោធន៍របស់ស្ត្រី ក្រុមជនជាតិដើមភាគតិច យុវជន និងជនពិការ នឹងត្រូវបានគេស្តាប់ឮ។

ភាគីពាក់ព័ន្ធសរុបចំនួន ២៤ នាក់បានចូលរួមក្នុងការសម្ភាសន៍ផ្ទាល់ជាបុគ្គល បទសម្ភាសន៍មួយត្រូវបានធ្វើជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗពីរនាក់។ ជាសរុប អ្នកផ្តល់សម្ភាសន៍ចំនួន ១៧ នាក់ត្រូវបានស្រង់ពី អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបួននាក់ ពីអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ។ អ្នកផ្តល់សម្ភាសន៍ប្រាំមួយនាក់ អាចនិយាយតាងនាមឲ្យអង្គការ/សម្ព័ន្ធភាព សមាជិកភាពនៃ អង្គការមិនមែនរដ្ឋាភិបាល។ អ្នកផ្តល់សម្ភាសន៍ ពីរនាក់ផ្នែកបណ្ឌិតសភា និងពីរនាក់មកពីសហជីព[8]។ ជារួម អ្នកផ្តល់សម្ភាសន៍ ១០នាក់ គឺជានារី។ បញ្ជីអ្នកផ្តល់សម្ភាសន៍មានបង្ហាញជូនក្នុងឧបសម្ព័ន្ធទី២។

មិនមានអ្នកយកព័ត៌មាន/អ្នកកាសែតត្រូវបានសម្ភាសន៍ទេ ដោយសារ ជាដំបូងក្រុមស្រាវជ្រាវ និង CCC មិនអាចកំណត់អត្តសញ្ញាណអ្នកកាសែត ដែលមានឯកទេសខាងរាយការណ៍អំពីសង្គមស៊ីវិល។ ប៉ុន្តែ ប្រព័ន្ធផ្សព្វផ្សាយអំពីស្ត្រីសម្រាប់អង្គការមិនមែនរដ្ឋាភិបាលមួយ ត្រូវបានដាក់បញ្ចូលក្នុងចំណោមអ្នកផ្តល់សម្ភាសន៍។ ការកំណត់អត្តសញ្ញាណមុខសញ្ញាអ្នកផ្តល់សម្ភាសន៍ពីបណ្តាញព័ត៌មាននៅពេលបន្ទាប់ បាននាំឲ្យមានកិច្ចប្រឹងប្រែងរួមមួយក្នុងការអញ្ជើញភាគីពាក់ព័ន្ធទាំងនេះ ឲ្យចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅថ្ងៃទី២៨ ខែវិច្ឆិកា។

ការលំបាកខ្លាំងក្នុងការជ្រើសរើសមន្ត្រីរាជរដ្ឋាភិបាលឲ្យចូលរួមក្នុងបទសម្ភាសន៍មួយ ត្រូវបានជួបប្រទះ ដោយសារការស្រាវជ្រាវបានប្រព្រឹត្តទៅក្នុងអំឡុងពេលក្រោយពេលបោះឆ្នោត ដែលនៅពេលនោះ មន្ត្រីតាមអាណត្តិបោះឆ្នោតជាច្រើនជាប់រវល់ ឬមិនអាចចូលរួម។ ក្រុមស្រាវជ្រាវបានគ្រោងសម្ភាសន៍មន្ត្រីរាជរដ្ឋាភិបាលមួយចំនួន។ ប៉ុន្តែ ទោះបីជាមានសំណើជាច្រើនតាមលិខិត ទូរស័ព្ទ និងសារអេឡិចត្រូនិច ពុំមានអ្នកណាម្នាក់ឆ្លៀតពេលនិយាយតាងនាមឲ្យរាជរដ្ឋាភិបាលឡើយ។

គម្រោងពិភាក្សាក្រុមជាមួយភាគីពាក់ព័ន្ធសំខាន់ៗ ពិសេសអ្នកពាក់ព័ន្ធចូលរួមជាមួយអង្គការសហគមន៍។ ដោយសារការពិភាក្សា ក្រុមគោលដៅមួយមិនបានធ្វើ ហើយដោយហេតុដូច្នោះ អ្នកដែលមកពីអង្គការសហគមន៍មិនអាចធ្វើជាតំណាងគ្រប់គ្រាន់ ក្នុងការសម្ភាសន៍ភាគីពាក់ព័ន្ធសំខាន់ៗ បុគ្គលទាំងឡាយដែលពាក់ព័ន្ធក្នុងអង្គការសហគមន៍ត្រូវបានជ្រើសរើសឲ្យចូលរួម ក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅថ្ងៃទី ២៨ ខែវិច្ឆិកា ក្នុងចំនួនច្រើនជាងការគ្រោង។ ប្រការនេះនាំឲ្យអង្គការសហគមន៍ខ្លះចូលរួមក្នុងរបកគំហើញបឋមនៃការស្រាវជ្រាវ។

ការសម្ភាសន៍ត្រូវបានធ្វើដោយអ្នកពិគ្រោះយោបល់ និងក្រុម។ ការសម្ភាសន៍អនុវត្តតាមកាលវិភាគកំណត់ជាមុន ដែលត្រូវបានសាកល្បងជាដំបូងទាំងស្រុងជាមួយអ្នកផ្តល់សម្ភាសន៍មួយរូបដោយសមាជិកក្រុមស្រាវជ្រាវទាំងបីនាក់។ ក្រោយពេលបញ្ចប់ការសម្ភាសន៍សាកល្បង កាលវិភាគត្រូវបានកែនៅពេលបន្ទាប់នោះ។ សូមមើលឧបសម្ព័ន្ធទី ១ សម្រាប់កម្មវិធីសម្ភាសន៍ចុងក្រោយ។ អ្នកផ្តល់សម្ភាសន៍ភាគច្រើន បានឆ្លើយសំណួរទាក់ទិននឹងទិដ្ឋភាពតែមួយ ឬពីរប៉ុណ្ណោះនៃទិដ្ឋភាពទាំងប្រាំពីរនៃបរិយាកាសអំណោយផល។ ការផ្ទៀងផ្ទាត់អ្នកផ្តល់សម្ភាសន៍ទៅនឹងទិដ្ឋភាពត្រូវបានធ្វើជាមុន

[8] These numbers do not total 24, as categories are not mutually exclusive and some interviewees identified as representing multiple groups of stakeholders.

ដោយក្រុមស្រាវជ្រាវ។ ប៉ុន្តែ អ្នកផ្តល់សម្ភាសន៍ក៏មានឱកាសលើកឡើងផងដែរនូវចំណាប់អារម្មណ៍ពួកគេលើទិដ្ឋភាពដោយឡែកនៃបរិយាកាសអំណោយផល។ ការសម្ភាសន៍មានរយៈពេលពី ៤៥ នាទីដល់ និង ២ម៉ោងកន្លះ។

ដើម្បីវិភាគទិន្នន័យ ចម្លើយពីអ្នកផ្តល់សម្ភាសន៍ត្រូវបានប្រៀបធៀប ពិនិត្យមើល និងតាមការចាំបាច់ ត្រូវបានពិភាក្សាដោយក្រុមស្រាវជ្រាវ។ នៅពេលខ្លះ ការបញ្ជាក់ព័ត៌មានត្រូវបានស្វែងរកក្រៅផ្លូវការពីសហការី និងអ្នកស្គាល់នៅក្នុងសង្គមស៊ីវិលនៅកម្ពុជា។ ព័ត៌មានទាំងអស់ដែលដាក់បញ្ចូលក្នុងរបាយការណ៍នេះ តំណាងឲ្យទស្សនៈទាំងឡាយដែលត្រូវបានបញ្ជាក់ដោយប្រភពផ្សេងៗ បើមិនមានរបាយការណ៍ផ្សេង។

ក្នុងករណីជាច្រើន ការដកស្រង់សំដី ដែលបានបង្ហាញក្នុងរបាយការណ៍នេះត្រូវបានកែសម្រួលដើម្បីតំណាងឲ្យការលើកឡើងដោយបុគ្គលមួយចំនួន ក្នុងការខិតខំការពារអនាមិកភាពនៃអ្នកផ្តល់សម្ភាសន៍។ ជាធម្មតា ការដកស្រង់សំដីសរុបធ្វើឲ្យមានការលំបាក ក្នុងការផ្សារភ្ជាប់ទៅនឹងសកម្មភាពនៃបុគ្គលដោយឡែកណាមួយ។ ជាការបញ្ជាក់ គោលបំណងនៃការស្រាវជ្រាវនេះមិនមែនសំដៅវាយតម្លៃ ឬចាត់ការទទួលខុសត្រូវលើសកម្មភាពជាក់លាក់ទៅបុគ្គលណាមួយឡើយ។ ក្នុងការបង្ហាញសក្ខីកម្ម ការស្រាវជ្រាវគ្រាន់តែបង្ហាញទស្សនៈរបស់អ្នកផ្តល់សម្ភាសន៍ដែលបានចូលរួម ក្នុងលក្ខណៈមិនលំអៀងតាមដែលអាចធ្វើទៅបាន។

## ចំណុចខ្វះខាត

មានចំណុចខ្វះខាតមួយចំនួនក្នុងការសិក្សានេះ ដែលមានដូចខាងក្រោម៖

១. ទស្សនៈរបស់ភាគីពាក់ព័ន្ធខ្លះ ជាពិសេសរាជរដ្ឋាភិបាល បណ្តាញសារព័ត៌មាន និងអង្គការសហគមន៍មិនចុះបញ្ជី មានតំណាងមិនគ្រប់គ្រាន់ក្នុងរបាយការណ៍នេះ។ ដូចបានកត់សម្គាល់ខាងលើ មានការលំបាកជាខ្លាំងក្នុងការកំណត់អត្តសញ្ញាណតួអង្គរាជរដ្ឋាភិបាលដែលមានឆន្ទៈ និងមានពេលផ្តល់សម្ភាសន៍ នៅពេលធ្វើការស្រាវជ្រាវ។ បើមានពេលបន្ថែម ឬជំនួយពីភាគីពាក់ព័ន្ធផ្សេងទៀត ក្រុមស្រាវជ្រាវប្រហែលជាអាចកំណត់អត្តសញ្ញាណភាគីពាក់ព័ន្ធរាជរដ្ឋាភិបាលដែលសុខចិត្តផ្តល់បទសម្ភាសន៍ និងប្រហែលជាអាចសម្រួលការពិភាក្សាក្រុមគោលដៅមួយជាមួយអង្គការសហគមន៍ ដូចដែលបានគ្រោងទុក។ ដូចបានកត់សម្គាល់ខាងលើ កិច្ចប្រឹងប្រែងជាពិសេសមួយត្រូវបានធ្វើដើម្បីអញ្ជើញអង្គការសហគមន៍ និងបណ្តាញសារព័ត៌មាន ចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅថ្ងៃទី២៨ ខែវិច្ឆិកា ដែលជាយុទ្ធសាស្ត្រជោគជ័យមួយកម្រិតទៀត។

២. ទំហំសំណាកអ្នកផ្តល់សម្ភាសន៍ ២៤ នាក់គឺពិតជាតូច ដោយសារមានអង្គការសង្គមស៊ីវិលមានដំណើរការចំនួនប្រហែល ១ ៣៥០ នៅកម្ពុជា។ គេមិនអាចអះអាងបានទេថាទស្សនៈ

ដែលបង្ហាញក្នុងរបាយការណ៍នេះ ពិតជាតំណាងតួអង្គសង្គមស៊ីវិលនៅកម្ពុជា។ សមាសភាពនៃសំណាកពិតជាមានឥទ្ធិពលដោយផ្ទាល់លើប្រភេទ សក្ខីកម្មដែលត្រូវបានបង្ហាញជូនអ្នកស្រាវជ្រាវ។

៣. ពេលវេលា គឺជាចំណុចខ្វះខាតដ៏សំខាន់មួយនៃការសិក្សា។ ចំនួនថ្ងៃសរុប ៣៤,៥ ថ្ងៃត្រូវបានកំណត់សម្រាប់បញ្ចប់របាយការណ៍ និងផែនការសកម្មភាពអម។ បើមានពេលបន្ថែម ក្រុមស្រាវជ្រាវប្រហែលជាអាចសិក្សាឯកសារ ឲ្យបានកាន់តែស៊ីជម្រៅថែមទៀត សម្ភាសន៍ភាគីពាក់ព័ន្ធថែម និងវិភាគស៊ីជំម្រៅ និងបញ្ជាក់កាន់តែហ្មត់ចត់នូវព័ត៌មានដែលបានប្រមូល។

ការចូលរួមទាបនៃភាគីពាក់ព័ន្ធសំខាន់ៗមួយចំនួន គួបផ្សំនឹងទំហំសំណាកតូច មានន័យថារបាយការណ៍នេះ ត្រូវបានចាត់ទុកថាជាឧបករណ៍អប់រំមួយសម្រាប់សង្គមស៊ីវិល ដើម្បីបង្កើនការយល់ដឹងអំពីបញ្ហាប្រឈមនៃបរិយាកាសអំណោយផល។ ដោយសារកង្វះមតិសំខាន់ៗដូចដែលលើកឡើងខាងលើ របាយការណ៍នេះមិនអាចចាត់ទុកថាតំណាងឲ្យគ្រប់បញ្ហាប្រឈមពាក់ព័ន្ធទាំងអស់ចំពោះមុខបរិយាកាសអំណោយផលឡើយ។

# ផ្នែកទី ៣: ការបង្កើតអង្គការសង្គមស៊ីវិល

## ទស្សនៈរួម

បច្ចុប្បន្ន មានអង្គការមិនមែនរដ្ឋាភិបាល (NGOs) និងសមាគមមានដំណើរការប្រហែល ១ ៣៥០ នៅកម្ពុជា។ សិទ្ធិបង្កើតអង្គការសង្គមស៊ីវិល ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញកម្ពុជា ហើយក្នុងការអនុវត្តជាក់ស្តែង ប្រជាពលរដ្ឋអាចទទួលបាននិងប្រើសិទ្ធិនេះ។ ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ ដ៏វែងនិងស្មុគ្រស្មាញកំណត់របៀបដែលអង្គការមិនមែនរដ្ឋាភិបាលនិងសមាគមអាចបង្កើតនិងចុះបញ្ជីនៅកម្ពុជា ហើយបទប្បញ្ញត្តិក្នុងក្រមនេះ ត្រូវបានបំពេញបន្ថែមទៀតដោយច្បាប់ បទប្បញ្ញត្តិ និងប្រកាសផ្សេងៗជាច្រើន។ ភាពស្មុគ្រស្មាញ និងភាពមិនច្បាស់លាស់នៃលក្ខខ័ណ្ឌច្បាប់ទាំងនេះសម្រាប់ការចុះបញ្ជី ជាក់ស្តែង មានន័យថាជួនកាលវាមានលក្ខណៈពិបាកយល់ និងអាចបកស្រាយតាមវិធីខុសៗគ្នា។ អាស្រ័យហេតុនេះ អង្គការសង្គមស៊ីវិលមានបទពិសោធន៍ខុសៗគ្នាជាមួយកិច្ចដំណើរការចុះបញ្ជី ដោយសារឆន្ទានុសិទ្ធិបុគ្គលរបស់មន្ត្រីជាច្រើននៅតាមក្រសួងពាក់ព័ន្ធ និងការិយាល័យរដ្ឋាភិបាលមូលដ្ឋាន អាចមានឥទ្ធិពលលើលទ្ធផលនៃកិច្ចដំណើរការនេះ។ លក្ខខ័ណ្ឌចុះបញ្ជីត្រូវបានយល់ឃើញដោយអង្គការសង្គមស៊ីវិលមួយចំនួនថា មានលក្ខណៈស្មុគ្រស្មាញនិងពិបាក។ ប៉ុន្តែ អ្នកផ្តល់សម្ភាសន៍បានឯកភាពថាបុគ្គលិកក្រសួងមហាផ្ទៃ ជាធម្មតា អាចរកបានដើម្បីជួយសម្រួលកិច្ចដំណើរការចុះបញ្ជី ជាថ្នូរនឹងការបង់ថ្លៃក្រៅផ្លូវការ។ អ្នកផ្តល់សម្ភាសន៍ មិនបានដឹងអំពីយន្តការតវ៉ា និងករណីណាមួយដែលនៅក្នុងនោះ ការតវ៉ាអាចត្រូវបានដាក់ជូនឡើយ។ សំណើច្បាប់ថ្មីមួយស្តីពីអង្គការមិនមែនរដ្ឋាភិបាលនិងសមាគម ប្រហែលជាអាចជួយសម្រួលនិងបូកសរុបបទប្បញ្ញត្តិច្បាប់សម្រាប់ការចុះបញ្ជី។ ប៉ុន្តែ តួអង្គសង្គមស៊ីវិលជាច្រើនមានការបារម្ភខ្លាំងថាសំណើកែប្រែចំពោះបទប្បញ្ញត្តិច្បាប់ទាំងឡាយដែលកំណត់លក្ខខណ្ឌបង្កើត ជាក់ស្តែង នឹងបង្កើតឧបសគ្គថែមទៀតចំពោះការបង្កើតអង្គការសង្គមស៊ីវិល។

## របកគំហើញ

រដ្ឋធម្មនុញ្ញកម្ពុជា[9] ធានាសិទ្ធិរបស់ប្រជាជនកម្ពុជាក្នុងការបង្កើតអង្គការសង្គមស៊ីវិល ដោយសារសិទ្ធិនេះមានមូលដ្ឋានលើគោលការណ៍នៃប្រជាធិបតេយ្យសេរីនិយម និងពហុនិយម ដែលមានចែងយ៉ាងច្បាស់។ មាត្រា ៤២ ចែងថាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ

---

[9] The Cambodian Constitution was adopted by the Constitutional Assembly in Phnom Penh on 21 September 1993.

ហើយសិទ្ធិទាំងនេះត្រូវកំណត់ដោយច្បាប់។ ពលរដ្ឋខ្មែរក៏អាចចូលរួមផងដែរក្នុងអង្គការមហាជនដើម្បីអត្ថប្រយោជន៍ទៅវិញទៅមកដើម្បីការពារសមិទ្ធផលជាតិ និងសណ្ដាប់ធ្នាប់សង្គម[10]។

*ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧* គឺជាច្បាប់គោលដែលកំណត់របៀបអង្គការមិនមែនរដ្ឋាភិបាល – និង អាចរួមទាំងសមាគមផងដែរ ទោះបីជាចំណុចនេះមិនមានលក្ខណៈច្បាស់លាស់ក្តី – អាចត្រូវបានបង្កើត និងត្រូវបានចុះបញ្ជី។ បទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីកំពុងត្រូវបានអនុវត្តជាផ្លូវការប្រកបដោយប្រសិទ្ធភាព គិតមកដល់ខែធ្នូ ឆ្នាំ២០១១។ ច្បាប់ថ្មីមួយស្តីពី*ការប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១* បញ្ជាក់ចំណុចនេះ ដែលធ្វើវិសោធនកម្មនិងបំពេញបន្ថែមក្នុងពេលតែមួយនូវមាត្រានានាក្នុង*ក្រមរដ្ឋប្បវេណី*។

> នៅក្នុងច្បាប់នេះ អង្គការមួយដែលត្រូវបានផ្តល់ឋានៈស្ថិតក្រោមសិទ្ធិ និងកាតព្វកិច្ចឯករាជ្យពីសមាជិកទាំងឡាយដែលបង្កើតជាអង្គការ ត្រូវហៅថា "សមាគមបញ្ចូលគ្នា" និងបានចូលរួមវិភាគទានជាទ្រព្យ ត្រូវបានផ្តល់ឋានៈស្ថិតក្រោមសិទ្ធិ និងកាតព្វកិច្ចឯករាជ្យ [ពីអ្នករួមវិភាគទាននៃទ្រព្យនោះ] ត្រូវហៅថាជា "មូលនិធិបញ្ចូលគ្នា" មួយ។ ច្បាប់នេះ នីតិបុគ្គលដែលមិនមានចំណេញក្នុងចំណោមកិច្ចការរបស់ខ្លួនត្រូវហៅថា "នីតិបុគ្គលមិនរកចំណេញ" និង នីតិបុគ្គលដែលមានចំណេញក្នុងចំណោមកិច្ចការរបស់ខ្លួនត្រូវហៅថា "នីតិបុគ្គលរកចំណេញ"។ នីតិបុគ្គលមិនរកចំណេញ អាចត្រូវបានបង្កើតក្រោមច្បាប់នេះ ឬច្បាប់ឬបទបញ្ញត្តិផ្សេងទៀត (*ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧* ២.១.១)។

ភាសានៃ*ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧* មានលក្ខណៈច្របូកច្របល់ និងមិនងាយយល់។ ទាំងមន្ត្រីរាជរដ្ឋាភិបាល ទាំងបុគ្គលិកនៃអង្គការសង្គមស៊ីវិល មិនប្រើពាក្យមានសង្គតិភាពដើម្បីពិពណ៌នាបញ្ហានៃការចុះបញ្ជីឡើយ។ ឧទាហរណ៍ ការបែងចែករវាងសមាគមបញ្ចូលគ្នា និងមូលនិធិបញ្ចូលគ្នា មិនត្រូវបានយល់ទូលាយឡើយ ហើយពាក្យ 'នីតិបុគ្គលមិនរកចំណេញ' មិនត្រូវបានប្រើទេក្នុងការអនុវត្តជាក់ស្តែង[11]។ អាស្រ័យហេតុនេះ គេមានការពិបាកក្នុងការកំណត់ថាតើអង្គការស្ថិតក្រោមក្រមរដ្ឋប្បវេណី។ ឧទាហរណ៍ សមាគមតូចៗខ្លះ ដែលត្រូវបានគេស្គាល់ថាជាអង្គការសហគមន៍ (CBOs) ហាក់បីដូចជារួចខ្លួនពីលក្ខខ័ណ្ឌនិយ័តកម្ម ថ្វីបើអង្គការសហគមន៍មួយចំនួនហាក់បីដូចជាបានចុះបញ្ជីជាមួយរាជរដ្ឋាភិបាលកម្ពុជា។ ឧបសគ្គមួយនៃឧបសគ្គទាំងឡាយចំពោះការយល់ដឹងកាន់តែច្រើនអំពីក្រមរដ្ឋប្បវេណីដោយមន្ត្រីសាធារណៈ និងសាធារណជន គឺលើកឡើងដ៏វែងនៃច្បាប់នេះ។ ច្បាប់នេះ មាន ១.៣០៥ មាត្រា ក្នុងគន្លឹប្រាំបួន ថ្វីបើមានតែបទប្បញ្ញត្តិទាំងនេះមួយចំនួនតូចប៉ុណ្ណោះដែលហាក់បីដូចជាត្រូវអនុវត្តចំពោះអង្គការមិនមែនរដ្ឋាភិបាល និង/ឬ សមាគម។

---

[10] http://www.constitution.org/cons/cambodia.htm, accessed 16 November 2013

[11] Definitions of civil society organisations as used by the Cooperation Committee for Cambodia, a leading membership organisation of civil society actors, is attached as Appendix 3.

ច្បាប់ក្តោបរួមស្តីពីអង្គការមិនមែនរដ្ឋាភិបាលនិងសមាគម ត្រូវបានស្នើឡើង ដែលបំពេញបន្ថែមលើ*ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧* និងដែលអាច – ទោះបីជាមិនមែនសុទ្ធតែអញ្ចឹងក្តី – ធ្វើឲ្យមានលក្ខណៈងាយស្រួល និងប្រមូលផ្តុំព័ត៌មានដែលពាក់ព័ន្ធនឹងការបង្កើត និងកិច្ចប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិល។ បច្ចុប្បន្ននេះ ច្បាប់នេះស្ថិតក្នុងសេចក្តីព្រាងទីបួន។ សេចក្តីព្រាងច្បាប់នេះត្រូវបានតវ៉ាដោយអង្គការសង្គមស៊ីវិលមួយចំនួន ដែលបានសម្តែងការបារម្ភថាច្បាប់នេះអាចត្រូវបានប្រើដើម្បីរារាំងការទិតៀនស្ថាប័នរាជរដ្ឋាភិបាល ដោយអង្គការសង្គមស៊ីវិល ឬដើម្បីរិតត្បិតសេរីភាពរបស់សមាគមនិងការបញ្ចេញមតិ។ តាមពិត ភាពចាំបាច់នៃច្បាប់អាចត្រូវគេចោទជាសំណួរបាន[12]។ គួរឲ្យកត់សម្គាល់ ដូចបានបង្ហាញជូនខាងលើ អង្គការសង្គមស៊ីវិលអាចទទួលបានឋានៈស្របច្បាប់រួចទៅហើយតាមរយៈក្រមរដ្ឋប្បវេណី។ កាលពីខែធ្នូ ឆ្នាំ២០១១ នាយករដ្ឋមន្ត្រីកម្ពុជា ហ៊ុន សែន ក្នុងការផ្តល់ចម្លើយមួយផ្នែកទៅកាន់ការបារម្ភរបស់សង្គមស៊ីវិល ក៏ដូចជា ការបារម្ភចេញពីដៃគូអភិវឌ្ឍន៍អន្តរជាតិ និងម្ចាស់ជំនួយឧបតោភាគី បានសន្យាពន្យារពេលដាក់ឲ្យអនុវត្តច្បាប់នោះរហូតដល់ក្រោយពេលបោះឆ្នោតជាតិ ដែលប្រព្រឹត្តទៅក្នុងពាក់កណ្តាលឆ្នាំ២០១៣[13]។ សេចក្តីប្រកាសថ្មីៗមួយ[14] បង្ហាញថាសំណើច្បាប់នេះនឹងត្រូវបានអនុវត្តជាផ្នែកមួយនៃអាណត្តិបច្ចុប្បន្ន (ទី៥) នៃរាជរដ្ឋាភិបាលនៃនាយករដ្ឋមន្ត្រី ហ៊ុន សែន។

ផ្នែក ៤៦-១១៨ នៃ*ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧* ចែងលម្អិតអំពីការចុះបញ្ជី និងការរំសាយនីតិបុគ្គលមិនរកចំណេញ និងលក្ខខ័ណ្ឌចុះបញ្ជីផ្សេងៗទៀត។ ប៉ុន្តែ ស្ថានភាព និងនីតិវិធីសម្រាប់ការចុះបញ្ជីអង្គការមិនមែនរដ្ឋាភិបាល បច្ចុប្បន្ននេះ ក៏ត្រូវបានគ្រប់គ្រងដោយច្បាប់និងបទប្បញ្ញត្តិបន្ថែមមួយចំនួនទៀតដែរ[15]។ យោងតាមបទបញ្ជារដ្ឋបាលរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលគេស្គាល់ថាជាប្រកាស[16] អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ពោលគឺ អង្គការមិនមែនរដ្ឋាភិបាលដែលគ្រប់គ្រងដោយពលរដ្ឋកម្ពុជា ត្រូវចុះបញ្ជីតាមរយៈក្រសួងមហាផ្ទៃ។ បទប្បញ្ញត្តិផ្សេងនិងពិបាកជាង ត្រូវបានអនុវត្តចំពោះការចុះបញ្ជីអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ។ ក្រសួងមហាផ្ទៃ តម្រូវឲ្យដាក់ជូននូវឯកសារខាងក្រោម៖

១. ពាក្យសុំចុះបញ្ជីប្រាំច្បាប់ ដោយមានចុះហត្ថលេខា (បញ្ជាក់ដោយមន្ត្រីឃុំ និងស្រុកនៅខាងខ្នងទម្រង់)
២. លិខិតអនុញ្ញាតពីរច្បាប់ ចេញដោយសាលាក្រុង ទាក់ទិននឹងទីតាំងនៃការិយាល័យនៃអង្គការក្នុងស្រុក

---

12 See, for example, http://www.sithi.org/admin/upload/media/[2012-08-30]The/2011_10_19_%20Fact%20Sheet%20%E2%80%93%20LANGO%20and%20the%20Shrinking%20Space%20for%20Civil%20Society%20in%20Cambodia.pdf, accessed 31 March 2013
13 http://www.rfa.org/english/news/cambodia/delayed-12282011172731.html, accessed 15 March 2013
14 http://www.cambodiadaily.com/news/government-pushes-ahead-with-ngo-law-48245/, accessed 8 December 2013
15 http://cambodianlaw.wordpress.com/2010/07/16/doing-good-by-doing-it-right-setting-up-an-ngo-in-cambodia/, accessed 16 November 2013
16 http://www.icnl.org/research/monitor/cambodia.html, accessed 28 February 2013

៣. ប្រវត្តិរូបរបស់ស្ថាបនិកជាតិកម្ពុជាយ៉ាងហោចណាស់បីនាក់ រួមមាននាយក ប្រធានរដ្ឋបាល និង ហិរញ្ញិក (ប្រាំច្បាប់ក្នុងមួយនាក់) និងរូបថត ៤ x ៦ របស់ស្ថាបនិកម្នាក់ៗ (ភ្ជាប់នឹងអត្តសញ្ញាណប័ណ្ណខ្មែរ ឬលិខិតបញ្ជាក់កំណើត ឬឯកសារមានតម្លៃស្មើ)។ សូមកត់សម្គាល់ថា ថ្វីបើបរទេសអាចចូលរួមក្នុងការគ្រប់គ្រង និងដំណើរការនៃអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកក្តី ក៏បុគ្គលិកសំខាន់ៗ រួមមាន ប្រធាន មន្ត្រីរដ្ឋបាល និងហិរញ្ញិក – ត្រូវតែជាពលរដ្ឋកម្ពុជា[17]

៤. លក្ខន្តិកៈប្រាំច្បាប់ (អនុស្សារណៈ និងលក្ខន្តិកៈរបស់សមាគម) នៃអង្គការក្នុងស្រុក ដោយផ្អែកលើគម្រូមួយដែលចេញដោយក្រសួងមហាផ្ទៃ ដោយមានហត្ថលេខារបស់នាយក

៥. រចនាសម្ព័ន្ធអង្គការប្រាំច្បាប់ ដោយផ្អែកលើគម្រូមួយដែលចេញដោយមហាផ្ទៃ ដោយមានហត្ថលេខារបស់នាយក

៦. ផែនទីនៃអាសយដ្ឋានរបស់អង្គការមិនមែនរដ្ឋាភិបាលចំនួនប្រាំច្បាប់ ដែលត្រូវបញ្ជាក់ដោយសង្កាត់មូលដ្ឋាន កិច្ចសន្យាជួលអគារបួនច្បាប់ និងរូបថត ១០ x ១៥ នៃផ្ទៃខាងមុខនៃការិយាល័យ រូបថតការិយាល័យពីសន្លឹក និងរូបថតម្ចាស់ផ្ទះនិងនាយកជាមួយគ្នានៅខាងមុខការិយាល័យពីរសន្លឹក។ លក្ខខ័ណ្ឌចុងក្រោយនេះ គឺសម្រាប់សមាគម ឬអង្គការដែលមានការិយាល័យនៅរាជធានីភ្នំពេញ។ លក្ខខ័ណ្ឌធូរជាងត្រូវបានអនុវត្តចំពោះសមាគមនិងអង្គការនៅតាមខេត្ត។

ចំពោះអនុស្សារណៈ និងលក្ខន្តិកៈរបស់សមាគម មិនមានរបៀបវារៈឬគោលបំណងជាក់លាក់ណាមួយរបស់អ្នកសុំចុះបញ្ជីត្រូវបានហាមឃាត់ឡើយ។ ហេតុដូច្នេះ អង្គការសិទ្ធិមនុស្ស និងជម្រុញប្រជាធិបតេយ្យមានសិទ្ធិចុះបញ្ជី។ អ្នកផ្តល់សម្ភាសន៍រាយការណ៍ថា បុគ្គលិកក្រសួងមហាផ្ទៃពិនិត្យមើលជាប្រចាំលើសង្គតិភាពនៅក្នុងបេកសកកម្ម និងចក្ខុវិស័យ និងអនុលោមភាពរបស់អង្គការចុះបញ្ជីជាមួយនឹងចំណុចផ្សេងទៀតនៃអនុស្សារណៈ។ អ្នកផ្តល់សម្ភាសន៍ម្នាក់បានលើកឡើងអំពីប្រការដែលត្រូវបានស្នើដោយ ក្រសួងមហាផ្ទៃឲ្យប្តូរបេសកកម្ម និងចក្ខុវិស័យរបស់អង្គការ ក៏ដូចជាមាត្រាទាក់ទិននឹងការតម្លើងឋានៈ និង ការរៀបចំបណ្តាញ (ហើយសំណើនេះត្រូវបានបំពេញ)។

ទាក់ទិននឹងលក្ខខ័ណ្ឌមូលធននៃការចុះបញ្ជីអង្គការសង្គមស៊ីវិល *ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧* ចែងថា សមាគមបញ្ចូលគ្នាមានការទទួលខុសត្រូវមានកម្រិតត្រូវតែមានមូលដ្ឋានទ្រព្យមិនតិចជាង ២០.០០០.០០០ (ម្ភៃលាន) រៀល ដែលស្មើនឹងប្រហែល ៥.០០០ ដុល្លារអាមេរិក ហើយមូលនិធិបញ្ចូលគ្នាមួយត្រូវរក្សាមូលដ្ឋានទ្រព្យមិនទាបជាង ២០០.០០០.០០០ (ពីររយលាន) រៀល (ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៧) ឬ ប្រហែល ៥០.០០០ ដុល្លារអាមេរិក។ គេមិនដឹងច្បាស់ទេថាតើអង្គការសង្គមស៊ីវិលដឹងអំពី ឬយកចិត្តទុកដាក់គោរពតាមបទបញ្ញត្តិនេះឬទេ ដោយសារពុំមានព័ត៌មានអំពីលក្ខខ័ណ្ឌមូលធននេះត្រូវបានទារដោយក្រសួងមហាផ្ទៃនៅពេលចុះបញ្ជីឡើយ។

[17] http://cambodianlaw.wordpress.com/2010/07/16/doing-good-by-doing-it-right-setting-up-an-ngo-in-cambodia/, accessed 16 November 2013

ការចុះបញ្ជីត្រូវធ្វើដោយផ្ទាល់ មិនអាចធ្វើបានតាមប្រព័ន្ធអេឡិកត្រូនិកទេ។ ជាធម្មតា គេត្រូវចំណាយពេលពីរបីខែដើម្បីចុះបញ្ជីពេញលេញ។ ដោយសារលក្ខខ័ណ្ឌចុះបញ្ជីសម្រាប់អង្គការនៅក្រៅរាជធានីភ្នំពេញ មានលក្ខណៈធូរជាង ការចុះបញ្ជីលឿនជាងនៅតាមខេត្តគឺអាចធ្វើបាន។ អ្នកផ្តល់ព័ត៌មានម្នាក់មកពីខេត្តមួយបាននិយាយថាអង្គការរបស់គាត់ បានទទួលការចុះបញ្ជីក្រោយរយៈពេលតែ ១៥ ថ្ងៃប៉ុណ្ណោះ។

ក្រោយពេលទទួលហើយ ការចុះបញ្ជីមិនចាំបាច់ធ្វើឡើងវិញទេ: ពុំមានរយៈពេលអតិបរមាឬអប្បបរមានៃការចុះបញ្ជីត្រូវបានបញ្ជាក់ក្នុងក្រមរដ្ឋប្បវេណីឡើយ។ ប៉ុន្តែ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិចាំបាច់ត្រូវបន្តអនុស្សារណៈនៃការយោគយល់របស់ខ្លួន ជាមួយក្រសួងការបរទេសរាល់បីឆ្នាំម្តង។ ការផ្លាស់ប្តូរណាមួយចំពោះអាសយដ្ឋានអង្គការ ការផ្លាស់ប្តូរនៃក្រុមប្រឹក្សាភិបាល ឬ ក្នុងចំណោមបុគ្គលិកជាន់ខ្ពស់ ឬការផ្លាស់ប្តូរចំពោះអនុស្សារណៈ និងលក្ខន្តិកៈរបស់សមាគម ចាំបាច់ត្រូវរាយការណ៍ជូនក្រសួងមហាផ្ទៃ។

វិធានការការពារតាមនីតិវិធីទាក់ទិននឹងការចុះបញ្ជី ហាក់បីដូចជានៅខ្វះខាត ដោយក្រសួងមហាផ្ទៃ ឬក្រសួងការបរទេសមានឆន្ទានុសិទ្ធិទាំងស្រុងក្នុងការបដិសេធការចុះបញ្ជី[18]។ ពុំមានអ្នកផ្តល់សម្ភាសន៍ណាអាចចង្អុលបង្ហាញឧទាហរណ៍ណាមួយ នៃការតវ៉ាដែលត្រូវបានដាក់ជូនដោយអង្គការមួយដែល ត្រូវបានបដិសេធ ឬមានការយឺតយ៉ាវការចុះបញ្ជីរបស់ខ្លួន។ គេហាក់បីដូចជាមិនឃើញមានយន្តការតវ៉ាផ្លូវការទេ។

អ្នកផ្តល់សម្ភាសន៍ខ្លះ និយាយថាថ្លៃក្រៅផ្លូវការត្រូវបង់ឲ្យមន្ត្រីឃុំ និងស្រុក ដើម្បីទទួលបានការបោះត្រាចាំបាច់លើឯកសារ។ ជាក់ស្តែង អង្គការមិនមែនរដ្ឋាភិបាលធំៗមួយចំនួនប្រើភ្នាក់ងារដែលជួយសម្រួលកិច្ចដំណើរការចុះបញ្ជី និងដែលយកថ្លៃសរុបសម្រាប់សេវាកម្មនេះ។ អ្នកផ្តល់សម្ភាសន៍សម្រាប់ការស្រាវជ្រាវនេះ បាននិយាយថាពួកគេបានបង់ប្រាក់ជូនមន្ត្រីរាជរដ្ឋាភិបាលប្រហែល ៣០០ ដុល្លារអាមេរិកជាថ្លៃក្រៅផ្លូវការ ដើម្បីសម្រួលពាក្យសុំចុះបញ្ជីរបស់ខ្លួនឲ្យបានរលូននិងឆាប់។ អ្នកផ្តល់សម្ភាសន៍មួយចំនួនពីសង្គមស៊ីវិលបានបង្ហាញ ការមិនសប្បាយចិត្ត ដែលមន្ត្រីរាជការខ្លះនៅក្នុងក្រសួងមហាផ្ទៃ មិនបានជួយពួកគេក្នុងអំឡុងពេលដំណើរការចុះបញ្ជី។ ឧទាហរណ៍ ចំណុចនេះរួមមានមន្ត្រីការិយាធិបតេយ្យ ខកខានមិនបានផ្តល់ព័ត៌មានដែលអាចជួយសម្រួលការរៀបចំ និងការចងក្រងឯកសារទាំងស្រុងមួយកញ្ចប់សម្រាប់ការចុះបញ្ជី លុះត្រាតែថ្លៃសម្រួលការត្រូវបានបង់។ ប៉ុន្តែបុគ្គលិកអង្គការសង្គមស៊ីវិលខ្លះ ដែលបានសម្ភាសន៍បានលើកឡើង ពីការទទួលបានជំនួយទាន់ពេល។ កម្រិតនៃកិច្ចសហប្រតិបត្តិការដោយបុគ្គលមន្ត្រីរាជការ នៅក្នុងក្រសួងហាក់បីដូចជាពឹងផ្អែកក្នុងកម្រិតមួយលើប្រការដែលថាតើសង្គមស៊ីវិលដាក់ពាក្យសុំមានទំនាក់ទំនងរឹងមាំឬទេ ជាមួយបុគ្គលនោះ ឬសហការី។

[18] http://www.icnl.org/research/monitor/cambodia.html, accessed 28 February 2013

អ្វីដែលគេដឹងជាសាធារណៈអំពីប្រាក់ខែដ៏ទាបរបស់មន្ត្រីរាជការ នៅកម្ពុជា[19] បុគ្គលិកនៅក្រសួងមហាផ្ទៃប្រហែលជាមានប្រាក់ខែចាយមិនគ្រប់ មិនមានធនធានគ្រប់គ្រាន់ និងត្រូវធ្វើការងារច្រើន។ ប៉ុន្តែ ពុំមានអ្នកផ្តល់សម្ភាសន៍ណាម្នាក់បញ្ជាក់ចំណុចនេះយ៉ាងច្បាស់លាស់ទេ។

យោងតាមជំរឿនមួយដែលធ្វើនៅចុងឆ្នាំ២០១១ អង្គការមិនមែនរដ្ឋាភិបាល (NGOs) និងសមាគមសកម្មនៅកម្ពុជា នៅពេលនេះមានចំនួន ១ ៣៥០ (គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ឆ្នាំ២០១២)។ អង្គការមួយចំនួនធំត្រូវបានចុះបញ្ជីជាផ្លូវការ រួមទាំងអង្គការតូចៗនៅតាមសហគមន៍ប្រហែល ១ ១១០។ អង្គការទាំងនេះច្រើនធ្វើការក្រៅផ្លូវការនៅកម្រិតមូលដ្ឋាន និងមិនសុទ្ធតែបានចុះបញ្ជីអំពីវត្តមានពួកគេជាមួយអាជ្ញាធរឡើយ (Cord Cambodia ឆ្នាំ២០១១)។ អាស្រ័យហេតុនេះ គេឃើញមានបញ្ហាជាមួយអង្គការបានចុះបញ្ជីដែលលែងធ្វើសកម្មភាពផង និងអង្គការមិនបានចុះបញ្ជីដែលធ្វើសកម្មភាពផង។ ចំណុចនេះ ត្រូវបានធ្វើឲ្យមានលក្ខណៈធ្ងន់ធ្ងរថែមទៀតដោយការលំបាកទូទៅក្នុងការកំណត់តួលេខពិតនៃអង្គការមិនមែនរដ្ឋាភិបាល និងសមាគមបានចុះបញ្ជីដោយសារប្រព័ន្ធទិន្នន័យដែលរក្សាដោយក្រសួងមហាផ្ទៃ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអង្គការសង្គមស៊ីវិលសមាជិកភាព មិនសុទ្ធតែធ្វើបច្ចុប្បន្នភាព ឬស៊ីគ្នាទេ។

សេចក្តីព្រាងច្បាប់បច្ចុប្បន្នស្តីពីអង្គការមិនមែនរដ្ឋាភិបាល និងសមាគម ត្រូវបានរំពឹងថានឹងមានឥទ្ធិពលខ្លាំងលើការបង្កើត និងកិច្ចប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិលនៅកម្ពុជា។ ការបារម្ភដ៏សំខាន់ទាក់ទិននឹងសេចក្តីព្រាងច្បាប់នេះ គឺការផ្តល់អំណាចច្រើន ដល់មន្ត្រីរាជរដ្ឋាភិបាលមូលដ្ឋាន និងថ្នាក់ជាតិ ដែលអាចត្រូវបានប្រើដើម្បីគ្រប់គ្រងលើសិទ្ធិរបស់សមាជិកអង្គការសង្គមស៊ីវិលក្នុងការចងក្រង និងបញ្ចេញមតិ។ គេឃើញមានផ្នែកមួយចំនួនគួរឲ្យបារម្ភនៅក្នុងសេចក្តីព្រាងច្បាប់ទីបួន (ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១១) ដែលមានលក្ខណៈជាក់លាក់ចំពោះការបង្កើតអង្គការសង្គមស៊ីវិលៈ

១. ការចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល បន្តមានលក្ខណៈស្មុគ្រស្មាញខ្លាំង។ លក្ខខ័ណ្ឌឯកសារនៅតែមានលក្ខណៈលំបាក ហើយលក្ខខ័ណ្ឌថ្មីតម្រូវឲ្យមានការិយាល័យមួយត្រូវបានស្នើឡើង ដែលបង្កើតឧបសគ្គចំពោះអង្គការតូចតាច។ ម្យ៉ាងទៀត ខណៈដែលសកម្មភាព ដែលធ្វើដោយសមាគមមិនបានបានចុះបញ្ជីនឹងពិតជាមានលក្ខណៈស្របច្បាប់ "ការជូនដំណឹងជាលាយលក្ខណ៍អក្សរ" អំពីសកម្មភាពក៏នឹងត្រូវបានតម្រូវ លើអង្គការសហគមន៍ដែរ។

២. ព្រាងច្បាប់នេះមិនមានដាក់បញ្ចូលរយៈពេលសម្រាប់កិច្ចដំណើរការតវ៉ាសម្រាប់ការបដិសេធការចុះបញ្ជី។

[19] See, for example, http://www1.worldbank.org/publicsector/civilservice/rightsizing/KH%20CSR%20Case_Draft2%200914.doc, accessed 30 November 2013

៣. គេហាក់បីដូចជាពុំឃើញមានវិធានការការពារណាមួយ ដើម្បីធានាឲ្យបានថាការបដិសេធ ការចុះបញ្ជី ឬការរំលាយដោយមិនស្ម័គ្រចិត្ត ត្រូវបានធ្វើក្នុងលក្ខណៈគ្មានលំអៀង និងពុំមានការលើកឡើងអំពីសិទ្ធិតវ៉ាក្រោយពេលព្យួរ ឬបិទឡើយ។

៤. ព្រាងច្បាប់នេះស្នើឡើងថាសមាជិកស្ថាបនិកដែលសមស្របនៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវតែគឺមានសញ្ជាតិខ្មែរ ហើយឧបសគ្គបន្ថែមចំពោះការចុះបញ្ជី និងសកម្មភាពនៃអង្គការមិនមែនរដ្ឋាភិបាលបរទេសក៏ត្រូវបានស្នើឡើងផងដែរ។

ការទិតៀនទូទៅមួយលើសេចក្ដីព្រាងច្បាប់នេះ គឺថាបច្ចេកស័ព្ទសំខាន់ៗមិនត្រូវបានកំណត់និយមន័យឡើយ ហើយផ្នែកជាច្រើនមានលក្ខណៈមិនច្បាស់លាស់។

## វិធីសាស្ត្រ

ព័ត៌មានខាងលើ ត្រូវបានប្រមូលពីការសិក្សាឯកសារជាច្រើន ជាពិសេស*ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧* ការវិភាគបោះពុម្ពផ្សាយអំពីក្រមរដ្ឋប្បវេណី និងការវិភាគអំពីសំណើច្បាប់ថ្មីស្ដីពីអង្គការមិនមែនរដ្ឋាភិបាលនិងសមាគម។ ក្នុងន័យនេះ ការតាមដានមើលច្បាប់ស្ដីពីអង្គការមិនមែនរដ្ឋាភិបាល (http://www.icnl.org/research/monitor/cambodia.html) មានប្រយោជន៍ជាពិសេស។ ការសម្ភាសន៍ផ្លូវការជាមួយ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា និងអង្គការជនជាតិដើមភាគតិច បានផ្ដល់ព័ត៌មានអំពីរបៀបដែលបទប្បញ្ញត្តិច្បាប់ថ្មីត្រូវបានបកស្រាយ និងអនុវត្តក្នុងការអនុវត្តជាក់ស្ដែង។ ព័ត៌មានដែលមានត្រូវបានសម្រិតសម្រាំងនិងផ្ទៀងផ្ទាត់នឹងភស្តុតាងពីនេះពីនោះ បានមកពីការការសន្ទនាក្រៅផ្លូវការជាមួយតួអង្គសង្គមស៊ីវិល។

## សេចក្តីសង្ខេបបញ្ហាប្រឈមសំខាន់ៗ

បញ្ហាប្រឈមសំខាន់ៗទាក់ទិននឹងការបង្កើតអង្គការសង្គមស៊ីវិលនៅកម្ពុជា រួមមានៈ

- កង្វះភាពច្បាស់លាស់ក្នុងបទប្បញ្ញត្តិសំខាន់ៗនៃក្រមរដ្ឋប្បវេណីកម្ពុជា រួមទាំងនិយមន័យនៃអង្គការមិនមែនរដ្ឋាភិបាល
- លក្ខខ័ណ្ឌចុះបញ្ជីស្មុគ្រស្មាញ ដែលជួនកាលមានលក្ខណៈពិបាកយល់និងអនុវត្តតាម
- អវត្តមាននៃលក្ខណៈវិនិច្ឆ័យមិនលំអៀងដែលត្រូវបានអនុវត្តទូទៅដោយមន្ត្រីក្រសួងក្នុងការកំណត់គុណសម្បត្តិអង្គការសង្គមស៊ីវិលសម្រាប់ការចុះបញ្ជី
- ការបង់ថ្លៃក្រៅផ្លូវការដោយបុគ្គលិកសង្គមស៊ីវិលជូនបុគ្គលមន្ត្រីក្រសួង ដើម្បីទទួលបានជំនួយសម្រាប់កិច្ចដំណើរការចុះបញ្ជី
- អវត្តមាននៃយន្តការតវ៉ាសម្រាប់ការព្យាយាមចុះបញ្ជីមិនបានសម្រេច
- ភាពមិនប្រាកដប្រជា និងមន្ទិលក្នុងចំណោមតួអង្គសង្គមស៊ីវិលទាក់ទិននឹងសំណើផ្លាស់ប្តូរចំពោះបទប្បញ្ញត្តិច្បាប់ដែលកំណត់លក្ខខ័ណ្ឌសម្រាប់ការបង្កើត (ពោលគឺ សំណើដាក់ឲ្យអនុវត្តច្បាប់មួយស្តីពីអង្គការមិនមែនរដ្ឋាភិបាល និងសមាគម)
- គម្លាតរវាងអ្នកសម្រេចច្បាប់ និង ការអនុវត្តច្បាប់ជាក់ស្តែង។

## ផ្នែកទី ៤: កិច្ចប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិល

### ទស្សនៈរួម

បច្ចុប្បន្ន ច្បាប់ពាក់ព័ន្ធដែលអាចអនុវត្តបានចំពោះសង្គមស៊ីវិលនៅកម្ពុជា រួមមាន*ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ ច្បាប់ស្តីពីសារពើពន្ធឆ្នាំ២០០៤ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីឆ្នាំ២០០៩ ច្បាប់ប្រឆាំងអំពើពុករលួយឆ្នាំ២០១០ និងច្បាប់ប្រឆាំងភេរវកម្មឆ្នាំ២០០៧*។ លក្ខខណ្ឌរដ្ឋបាលសំខាន់ៗដែលមានឥទ្ធិពលលើអង្គការសង្គមស៊ីវិល រួមមានកិច្ចតម្រូវឲ្យ៖

- ចុះកិច្ចព្រមព្រៀងគម្រោងជាមួយក្រសួងយ៉ាងហោចណាស់មួយ - ចំណុចនេះមានលក្ខណៈសំខាន់ជាពិសេសសម្រាប់អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ដែលមិនអាចចុះបញ្ជីបានដោយគ្មានកិច្ចព្រមព្រៀងបែបនេះ
- រាយការណ៍អំពីសកម្មភាពគម្រោងជូនរាជរដ្ឋាភិបាល
- ប្រកាសទ្រព្យសម្បត្តិ (ប៉ះពាល់តែបុគ្គលិកជាន់ខ្ពស់ប៉ុណ្ណោះ)
- សុំការអនុញ្ញាតដើម្បីធ្វើការជួបប្រជុំសាធារណៈ និង
- រាយការណ៍អំពីការផ្លាស់ប្តូរការងាររបស់បុគ្គលិកជាន់ខ្ពស់ សមាសភាពនៃក្រុមប្រឹក្សាភិបាល និង ការផ្លាស់ប្តូរទីតាំងការិយាល័យ។

ក្នុងការអនុវត្តជាក់ស្តែង លក្ខខណ្ឌជាច្រើននៃលក្ខខណ្ឌទាំងនេះ លើកលែងតែការសុំការអនុញ្ញាតសម្រាប់ការជួបប្រជុំ មិនត្រូវបានបំពេញដោយអង្គការសង្គមស៊ីវិលទេ។ អង្គការសង្គមស៊ីវិលមិននិយាយអំពីប្រការត្រូវទទួលរងការធ្វើសវនកម្មឬអធិការកិច្ចរបស់រាជរដ្ឋាភិបាល ហើយជាទូទៅ យល់ថាការត្រួតពិនិត្យលើអង្គការសង្គមស៊ីវិល មិនមែនគឺជាអាទិភាពខ្ពស់សម្រាប់នាយកដ្ឋានរបស់រាជរដ្ឋាភិបាលភាគច្រើន។ ការត្រួតពិនិត្យដោយស្ថាប័នរាជរដ្ឋាភិបាលពាក់ព័ន្ធលើការងារ ត្រូវបានអ្នកផ្តល់សម្ភាសន៍ជាបុគ្គលិកអង្គការយល់ឃើញ ថាមានលក្ខណៈល្មម។ តាមពិត អ្នកផ្តល់សម្ភាសន៍ខ្លះហាក់ដូចជឿថា ការខកខានមិនបានអនុវត្តច្បាប់យ៉ាងទៀងទាត់ដោយរាជរដ្ឋាភិបាលមានឥទ្ធិពលធ្វើឲ្យការត្រួតពិនិត្យពួកគេមានលក្ខណៈបំពាន ឬអត្តនោម័ត។ អ្នកផ្តល់សម្ភាសន៍ទាំងនោះបានរាយការណ៍ថាកង្វះសង្គតិភាព និងភាពដូចគ្នានេះនៅក្នុងការអនុវត្តច្បាប់ ជាក់ស្តែងអាចក្លាយជាបន្ទុកកាន់តែធ្ងន់ដែលតម្រូវដោយច្បាប់ឬគោលនយោបាយ។ កិច្ចប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិលនៅថ្នាក់ក្រោមជាតិ រងផលប៉ះពាល់ពីការបកស្រាយរបស់មន្ត្រីទាំងនោះ ពីក្របខ័ណ្ឌគតិយុត្តិដែលគ្រប់គ្រងសកម្មភាពអង្គការសង្គមស៊ីវិល។ គេឃើញមានការកត់សំគាល់ករណីមួយចំនួននៃអង្គការសង្គមស៊ីវិល ជាពិសេស អង្គការដែលជំរុញសិទ្ធិមនុស្ស ត្រូវទទួលរងពាក្យសម្តី ឬសកម្មភាពពីមន្ត្រីរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ - ការប្រើការបង្ខិតបង្ខំ ឬកម្លាំងដោយមន្ត្រីទាំងនោះ។ លើសពីនេះទៀត គេឃើញមានករណីកត់ត្រា ដែលនៅក្នុងនោះមន្ត្រីមូលដ្ឋានរបស់រាជរដ្ឋាភិបាល

បានបញ្ជាឲ្យអង្គការសង្គមស៊ីវិលបញ្ឈប់សកម្មភាពអង្គការ។ គេឃើញមានការបារម្ភកាន់តែច្រើនក្នុងចំណោមបុគ្គលិកសង្គមស៊ីវិល ដែលថាមន្ត្រីមូលដ្ឋានស្រុក និងខេត្ត ហាក់បីដូចជាមាននិន្នាការប្រើសម្ពាធខ្លាំង និងក្នុងករណីខ្លះ ប្រើកម្លាំងក្នុងការដោះស្រាយជាមួយពួកគេ។ អង្គការសង្គមស៊ីវិលជាច្រើនយល់ថាសំណើច្បាប់ថ្មីស្តីពី អង្គការមិនមែនរដ្ឋាភិបាល និងសមាគម នឹងបង្កើននូវតួនាទីមិនចាំបាច់របស់រាជរដ្ឋាភិបាល ក្នុងការត្រួតពិនិត្យអង្គការសង្គមស៊ីវិល ព្រមទាំងផ្តល់អំណាចដល់មន្ត្រីមួយចំនួនក្នុងរាជរដ្ឋាភិបាលត្រួតត្រាកាន់តែងាយស្រួលលើកិច្ចប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិល។

## របកគំហើញ

ច្បាប់ពាក់ព័ន្ធដែលអាចអនុវត្តចំពោះសង្គមស៊ីវិលនៅកម្ពុជា រួមមាន*ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ ច្បាប់ស្តីពីសារពើពន្ធឆ្នាំ២០០៤ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ច្បាប់ប្រឆាំងអំពើពុករលួយឆ្នាំ២០១០* និង *ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីឆ្នាំ២០០៩*។ ដូចបានកត់សម្គាល់ក្នុងផ្នែកដែលពិភាក្សាអំពីការបង្កើតអង្គការសង្គមស៊ីវិល ក្រមរដ្ឋប្បវេណីកំណត់ប្រភេទអង្គការមិនមែនរដ្ឋាភិបាល និងសមាគម។ អង្គការមិនមែនរដ្ឋាភិបាលអាចសុំការលើកលែងពន្ធស្របតាម*ច្បាប់ស្តីពីសារពើពន្ធឆ្នាំ២០០៤* (មាត្រា ៩)។ *ច្បាប់ប្រឆាំងភេរវកម្ម ឆ្នាំ២០០៧* តម្រូវឲ្យអង្គការមិនមែនរដ្ឋាភិបាលទទួលតែមូលនិធិ 'ស្អាត' រីឯ*ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩* និង *ច្បាប់ប្រឆាំងអំពើពុករលួយឆ្នាំ២០១០* ចែងពីការក្លែងបន្លំ។ ក្នុងករណីនៃ*ច្បាប់ប្រឆាំងអំពើពុករលួយឆ្នាំ២០១០* រាជរដ្ឋាភិបាលកម្ពុជាបានប្រកាន់យកជំហានមិនដែលមានកាលពីមុននៃការរាប់បញ្ចូលមេដឹកនាំសង្គមស៊ីវិល នៅក្នុងដែនអនុវត្តនៃច្បាប់ដោយតម្រូវឲ្យពួកគេប្រកាសទ្រព្យសម្បត្តិ។ *ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ឆ្នាំ២០០៩* ត្រូវបានពន្យល់នៅពេលក្រោយក្នុងរបាយការណ៍នេះ – សូមមើលផ្នែកទី ៦។

ក្រៅពីការចុះបញ្ជីអង្គការ អង្គការសង្គមស៊ីវិលត្រូវបានរំពឹងឲ្យចុះកិច្ចព្រមព្រៀងគម្រោងជាមួយក្រសួងរាជរដ្ឋាភិបាល។ ការទទួលបានកិច្ចព្រមព្រៀងមួយ មានន័យថាជាការដាក់ជូនលិខិតសំណើគាំទ្រមួយ ឯកសារចម្លងនៃផែនការយុទ្ធសាស្ត្រ ឬផែនការសកម្មភាពគម្រោង ថវិកាគម្រោងបញ្ជីបុគ្គលិក និងបញ្ជីយានយន្ត[20]។ គេមិនដឹងទេថាតើសំណើកិច្ចព្រមព្រៀងគម្រោងត្រូវបានវាយតម្លៃដោយផ្អែកលើមូលដ្ឋានអ្វី។ ស្ទើរតែ ៩៥% នៃអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិបានចុះបញ្ជីទាំងអស់មានអង្គការចុះកិច្ចព្រមព្រៀងយ៉ាងហោចណាស់មួយ ជាមួយរាជរដ្ឋាភិបាល និង មាន ៨៦% សម្រាប់អង្គការក្នុងស្រុក (គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ឆ្នាំ២០១៣)។ ប៉ុន្តែ គេឃើញមានភាពស្រពិចស្រពិលខ្លះក្នុងស្ថិតិនេះ ដោយអង្គការសង្គមស៊ីវិលខ្លះចាត់ទុកការចុះបញ្ជី ជាការអភិវឌ្ឍកិច្ចព្រមព្រៀងផ្លូវការជាមួយរាជរដ្ឋាភិបាល ដែលអាចនាំទៅដល់ការរាយការណ៍លើស អំពីកិច្ចព្រមព្រៀងនេះ (គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ឆ្នាំ២០១៣)។ អ្នកផ្តល់សម្ភាសន៍ពីរនាក់ បានរាយការណ៍ថាបានបង់ថ្លៃក្រៅផ្លូវការជូនបុគ្គលមន្ត្រីក្នុងក្រសួងពាក់ព័ន្ធមួយៈ "ប្រសិនបើយើងចុះកិច្ច

[20] http://www.ccc-cambodia.org/aboutus/faq.html, accessed 1 December 2013

ព្រមព្រៀងជាមួយក្រសួង និងធ្វើការជាមួយពួកគេជាសហភាគី យើងបង់ប្រាក់ថ្លៃសេវាជាមួយគោលបំណងមិនច្បាស់លាស់ និងវិក្ក័យបត្រក្រៅផ្លូវការ”។

ក្រោយការចរចារកិច្ចព្រមព្រៀងគម្រោងមួយ អង្គការសង្គមស៊ីវិលត្រូវចុះបញ្ជីសកម្មភាពគម្រោងរបស់ខ្លួនជាមួយ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (Bañez-Ockelford ឆ្នាំ២០១១ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ឆ្នាំ២០១៣)។ អង្គការសង្គមស៊ីវិលបានចុះបញ្ជីត្រូវផ្តល់ព័ត៌មានបច្ចុប្បន្នភាពទៅជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រៀងរាល់ត្រីមាស (Bañez-Ockelford ឆ្នាំ២០១១)។ ប៉ុន្តែ អង្គការសង្គមស៊ីវិលភាគច្រើន មិនរាយការណ៍ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាទេ (គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ឆ្នាំ២០១៣)។ ព័ត៌មានបច្ចុប្បន្នភាពគម្រោង ត្រូវបានរំពឹងថាត្រូវរួមមានរបាយការណ៍សកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុ។ ម្យ៉ាងទៀត ការរាយការណ៍ជូនក្រសួងមហាផ្ទៃ ត្រូវធ្វើប្រចាំឆ្នាំ។

សកម្មភាពគម្រោងរបស់អង្គការសង្គមស៊ីវិល មិនហាក់បីដូចជាត្រូវបានវាយតម្លៃលើការសម្របសកម្មភាពទាំងនោះទៅនឹងអាទិភាពរបស់រាជរដ្ឋាភិបាល ដូចដែលត្រូវបានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍ជាតិ និងពុំមានលក្ខខ័ណ្ឌកំណត់សកម្មភាពគម្រោងត្រូវសម្របតាមនោះទេ។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) បានចេញគោលការណ៍ណែនាំទាក់ទិននឹងសេចក្តីជូនដំណឹងអំពីសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល ក្នុងទម្រង់ជាសៀវភៅណែនាំអង្គការមិនមែនរដ្ឋាភិបាល។ សៀវភៅនេះ ហាក់បីដូចជាអាចរកបានតែក្នុងទម្រង់ជាឯកសារបោះពុម្ពប៉ុណ្ណោះ[21] និងមានការយល់ដឹងតិច អំពីសៀវភៅណែនាំនេះក្នុងចំណោមអង្គការក្នុងស្រុក។ ពុំមានអ្នកផ្តល់សម្ភាសន៍ដែលបានពិគ្រោះអំពីបញ្ហានេះ បានលើកឡើងពីការបានដាក់របាយការណ៍សកម្មភាព ឬ របាយការណ៍ហិរញ្ញវត្ថុតាមការកំណត់ ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬក្រសួងមហាផ្ទៃឡើយ។ ការផ្លាស់ប្តូរចំពោះតំណែងសំខាន់ៗ ដូចជា នាយក ប្រធាន និងលេខា ក៏ត្រូវបានតម្រូវឲ្យរាយការណ៍ផងដែរ ប៉ុន្តែអ្នកផ្តល់សម្ភាសន៍ស្ទើរតែទាំងអស់ ក៏មិនដែលមានបទពិសោធន៍ដាក់ជូនរបាយការណ៍នេះទេ។ អ្នកផ្តល់សម្ភាសន៍ម្នាក់បាននិយាយអំពីការជូនដំណឹងដល់ រាជរដ្ឋាភិបាលអំពីការផ្លាស់អាសយដ្ឋានការងាររបស់អង្គការ (និង ការបង់ថ្លៃក្រៅផ្លូវការសម្រាប់ធ្វើដូច្នេះ)។

ប្រសិនបើអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកកំពុងធ្វើសកម្មភាព ក្នុងខេត្តមួយក្រៅពីកន្លែងដែលពួកគេបានចុះបញ្ជី នោះគេត្រូវរាយការណ៍ជូនអាជ្ញាធរមូលដ្ឋានប្រាំថ្ងៃមុន។ ប្រការដែលថាតើការរាយការណ៍នេះត្រូវបានធ្វើឬទេ គឺមានលក្ខណៈខុសគ្នាច្រើន និងហាក់បីដូចជាអាស្រ័យលើកត្តាមួយចំនួន រួមមានការវាយតម្លៃរបស់អង្គការសង្គមស៊ីវិលដោយខ្លួនឯងអំពីលទ្ធភាពដែលសកម្មភាពមួយនឹងទាក់ទាញការពិនិត្យពិច័យពីមន្ត្រីមូលដ្ឋាន ដែលអាចរហូតដល់ទៅព្យាយាមជ្រៀតជ្រែក ឬបញ្ឈប់សកម្មភាពនោះ។ នៅតាមខេត្តខ្លះ គោលការណ៍ណែនាំនេះត្រូវបានបកស្រាយដោយបុគ្គលជាអាជ្ញាធរទីនោះថា តម្រូវអោយមានការយល់ព្រមលើសកម្មភាពរបស់អង្គការសង្គមស៊ីវិលពីអាជ្ញាធរខេត្ត។ អ្នកផ្តល់សម្ភាសន៍ម្នាក់បានប្រាប់ថាការសុំការយល់ព្រម ដើម្បីធ្វើសកម្មភាពបែបនេះ

[21] Efforts to track down a citable version of the Guidebook proved unsuccessful.

នៅតាមខេត្ត មានពាក់ព័ន្ធលើការងាររដ្ឋបាលជាច្រើន ហើយពីមួយឆ្នាំទៅមួយឆ្នាំ វាកាន់តែមានលក្ខណៈលំបាកឡើង។

ការអនុវត្ត ការសុំការអនុញ្ញាតពីអាជ្ញាធរខេត្ត ខុសគ្នាច្រើនពីខេត្តមួយទៅខេត្តមួយ។ ក្នុងអំឡុងពេលយុទ្ធនាការបោះឆ្នោតខែកក្កដា ឆ្នាំ២០១៣ មន្ត្រីរាជរដ្ឋាភិបាលថ្នាក់ក្រោមជាតិនៅខេត្តរតនគិរី បានចេញលិខិតមួយដើម្បីប្រាប់អង្គការសង្គមស៊ីវិល ថាពួកគេមិនគប្បីអញ្ជើញភាគីពាក់ព័ន្ធ (ភូមិ) ណាឲ្យមកប្រជុំជាមួយពួកគេទេក្នុងអំឡុងពេលយុទ្ធនាការបោះឆ្នោតនេះ។ អ្នកផ្តល់សម្ភាសន៍ម្នាក់ទៀត បាននិយាយថា៖

> (អង្គការ) មិនអាចចូលការិយាល័យរបស់ខ្លួនសម្រាប់គម្រោងមួយ។ កន្លងមក អភិបាលខេត្តកំពង់ធំមិនអនុញ្ញាតឲ្យអង្គការសង្គមស៊ីវិលធ្វើសិក្ខាសាលាទេ។ ប៉ុន្តែ នៅខេត្តបាត់ដំបង នគរបាលធ្វើការជាមួយ (អង្គការ) ដោយសារពួកគេមិនចង់ឲ្យ (អង្គការ) និយាយរឿងអាក្រក់អំពីពួកគេ ឬ រាយការណ៍ឲ្យកាសែត។
>
> អ្នកផ្តល់សម្ភាសន៍អនាមិក

របាយការណ៍មួយដែលឧបត្ថម្ភដោយអង្គការ UNDP ក៏បានពិនិត្យមើលផងដែរនូវភស្តុតាងនៃការរឹតត្បិតដោយរដ្ឋបាលថ្នាក់ក្រោមជាតិ លើសេរីភាពខាងការជួបប្រជុំ និងការបញ្ចេញមតិ បានសន្និដ្ឋានថា "ចំណុចនេះមិនមែនជាឥរិយាបថទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទេ។ វាកើតឡើងក្នុងមូលដ្ឋាននៅតាមខេត្តមួយចំនួនតូចប៉ុណ្ណោះ ហើយភាគច្រើន វាបណ្តាលមកពីកង្វះសមត្ថភាព និងការយល់ដឹងអំពីសង្គមស៊ីវិលក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិ និងបណ្តាលមកពី គណនេយ្យភាពខ្លាំងឆ្ពោះទៅថ្នាក់លើ និងការភ័យខ្លាចអំពីផលវិបាក ប្រសិនបើពួកគេបាត់បង់ការគ្រប់គ្រង (sic) លើសកម្មភាពអង្គការសង្គមស៊ីវិល ក្នុងខេត្ត ឬស្រុករបស់ពួកគេ" (Merla ឆ្នាំ២០១០ ទំព័រ ២៥)។

ថ្វីបើការរាយការណ៍អំពីសកម្មភាពគម្រោង និងបញ្ហាទាក់ទិន ត្រូវបានតម្រូវយ៉ាងច្បាស់ដោយក្របខ័ណ្ឌបទបញ្ញត្តិរបស់រាជរដ្ឋាភិបាលក្តី ក៏លក្ខខ័ណ្ឌនេះមិនត្រូវបានយល់យ៉ាងទូលាយឡើយ។ សូម្បីតែនៅពេលដែលវាត្រូវបានយល់ក្តី ក៏របៀបដែលលក្ខខ័ណ្ឌនេះត្រូវបានបកស្រាយក្នុងការអនុវត្តជាក់ស្តែងមានលក្ខណៈខុសគ្នាយ៉ាងច្រើនដែរ។ អ្នកផ្តល់សម្ភាសន៍បានរាយការណ៍ផ្សេងៗគ្នាថា៖

ក. មិនបានជូនដំណឹងដល់រាជរដ្ឋាភិបាលអំពីការជួបប្រជុំខាងមុខ – និង មិនដែលត្រូវបានស្នើឲ្យធ្វើដូច្នេះទេ

ខ. ចាំបាច់ត្រូវជូនដំណឹងដល់រាជរដ្ឋាភិបាល តែអំពីការជួបប្រជុំណាដែលមានអ្នកចូលរួមលើសពី ២០០-៣០០ នាក់ និង

គ. ចាំបាច់ត្រូវជូនដំណឹងដល់រាជរដ្ឋាភិបាល តែអំពីការជួបប្រជុំណាដែលមានអ្នកចូលរួមលើសពី ៧០០ នាក់។

អ្នកផ្ដល់សម្ភាសន៍ម្នាក់បានប្រាប់ថាការជួបប្រជុំនៅតាមកន្លែងសាធារណៈ មានលក្ខណៈរសើបជាងការប្រជុំនៅតាមកន្លែងឯកជន ហើយការជួបប្រជុំសាធារណៈទាំងអស់ ជាធម្មតា ត្រូវជូនដំណឹងដល់រាជរដ្ឋាភិបាល អនុលោមតាម*ច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធីឆ្នាំ ២០០៩* – សូមមើលផ្នែកទី ៦។ ស្ទើរតែគ្រប់ករណីទាំងអស់ អ្នកផ្ដល់សម្ភាសន៍បានលើកឡើងពីការមានអារម្មណ៍ថាទទួលរងបន្ទុកពីលក្ខខ័ណ្ឌរដ្ឋបាលពាក់ព័ន្ធនឹង ការដែលត្រូវរាយការណ៍អំពីប្រភេទការជួបជុំទាំងនេះជូនរាជរដ្ឋាភិបាល។

ជារួម អ្នកផ្ដល់សម្ភាសន៍មិនគិតថា រាជរដ្ឋាភិបាលមានការត្រួតពិនិត្យច្រើនលើសង្គមស៊ីវិលទេ។ "យើងមានលទ្ធភាពធ្វើការជាមួយពួកគាត់។ ប៉ុន្តែ វាអាស្រ័យលើអ្នកដែលយើងធ្វើការជាមួយ។ ប្រសិនបើគាត់ជាមនុស្សកណ្ដាល យើងស្រួលធ្វើការជាមួយគាត់"។ តាមការលើកឡើងខាងលើ អ្នកផ្ដល់សម្ភាសន៍ភាគច្រើនហាក់បីដូចជាយល់ថា ឧបសគ្គធំជាងចំពោះកិច្ចប្រតិបត្តិការរបស់សង្គមស៊ីវិលទាក់ទងជាមួយការយល់ដឹង និងសមត្ថភាពអនុវត្តច្បាប់ ប្រកបដោយប្រសិទ្ធភាព និងសមធម៌ របស់មន្ត្រីរាជការមួយចំនួន។ ការដកស្រង់សំដីពីអ្នកផ្ដល់សម្ភាសន៍ពីរនាក់ បង្ហាញចំណុចនេះ៖

> ពួកគេធ្វើមកលើយើងមិនមែនផ្អែកតាមច្បាប់ទេ ប៉ុន្តែ ផ្អែកលើសញ្ចេតនា និងទំនាក់ទំនង។ រាជរដ្ឋាភិបាលប្រើបទបញ្ជា ឬសេចក្ដីសម្រេចជាពាក្យសម្ដី។ ការប្រតិបត្តិច្បាប់ មិនមែនគឺជាការប្ដេជ្ញាចិត្តពិតប្រាកដរបស់រាជរដ្ឋាភិបាលទេ។ អាជ្ញាធរមិនយល់ - មិនដឹងអំពីច្បាប់ និងគោលនយោបាយ។
>
> អ្នកផ្ដល់សម្ភាសន៍អនាមិក

ដូចដែលបានឃើញច្បាស់រួចហើយ អង្គការសង្គមស៊ីវិលជាច្រើនមិនបានបំពេញកាតព្វកិច្ចតាមផ្លូវច្បាប់របស់ខ្លួនឡើយក្នុងការរាយការណ៍ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬក្រសួងមហាផ្ទៃ[22]។ ប្រការនេះមិនត្រូវបានដេញដោលដោយរាជរដ្ឋាភិបាលទេ លើកលែងតែក្នុងករណីដាច់ដោយឡែក។ ប៉ុន្តែ 'ការខកខានមិនបានដាក់របាយការណ៍' ត្រូវបានប្រើនៅពេលខ្លះដោយមន្ត្រីនៅកម្រិតផ្សេងៗក្នុងរាជរដ្ឋាភិបាល ដើម្បីទិតៀនអង្គការសង្គមស៊ីវិលមួយចំនួន ឬ ក្នុងករណីខ្លះ រហូតដល់ជ្រៀតជ្រែកចូលកិច្ចប្រតិបត្តិការរបស់អង្គការទាំងនោះ ឬទាមទារឲ្យអង្គការទាំងនោះផ្អាកកិច្ចប្រតិបត្តិការរបស់ខ្លួន[23]។ ក្នុងឆ្នាំ ២០១១ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ មានឈ្មោះថា សមាគមធាងត្នោត ត្រូវបានព្យួរការងារអស់រយៈពេលប្រាំខែ ដោយសារខកខានមិនបានដាក់របាយការណ៍ជូនរាជរដ្ឋាភិបាល។ សមាគមធាងត្នោត នៅពេលនោះ បានចូលរួមក្នុងការរៀបចំរបាយការណ៍មួយដែលលើកឡើងពីការខកខានរបស់មន្ត្រីមូលដ្ឋាន ក្នុងការលើកជ្រោងសិទ្ធិរបស់សហគមន៍ក្រីក្រនៅទីក្រុងដែលត្រូវផ្លាស់ទីតាំងដោយគម្រោងអភិវឌ្ឍន៍។ សមាគមធាងត្នោតមិនបានតវ៉ាសេចក្ដីសម្រេចនោះទេ ហើយក្រសួងពាក់ព័ន្ធដែលផ្អាកការងារសមាគមធាងត្នោតក៏មិនបានផ្ដល់ព័ត៌មានអ្វីអំពីសិទ្ធិតវ៉ារបស់ពួកគេផងទេ។

---

[22] http://www.aidinfo.org/wp-content/uploads/2009/09/Case-Study-Cambodia.pdf, accessed 21 June 2013

[23] https://www.devex.com/en/news/cambodia-s-consecutive-warnings-suspension-of-critical-ngos-a-preview-of-things-to-come/75689, accessed 21 June 2013

យោងតាម*ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧* មូលហេតុសម្រាប់ការរំលាយសមាគមបញ្ចូលគ្នាមួយ រួមមានៈ ក្ស័យធន ការលំបាកខ្លាំងដែលនាំទៅដល់ការខូចខាតមិនអាចជួសជុលឡើងវិញបាន "ការគ្រប់គ្រងមិនសមរម្យ" ចំនួនសមាជិកបានថយចុះមកត្រឹមមួយនាក់ ការដាក់បញ្ចូលវត្ថុខុសច្បាប់ ការខកខានផ្តើមប្រតិបត្តិការក្នុងរយៈពេលមួយឆ្នាំក្រោយបង្កើត ការបញ្ឈប់អាជីវកម្មរយៈពេលមួយឆ្នាំ ឬលើសពីមួយឆ្នាំ និង/ឬ ការបន្តធ្វើអំពើដែលខុសពី ឬបំពានអំណាចអង្គការ (ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧)។ ពុំមានអ្នកផ្តល់សម្ភាសន៍ណាដឹងករណីណាមួយនៃការរំលាយអង្គការបានចុះបញ្ជីហើយដោយរាជរដ្ឋាភិបាល អនុលោមតាមបទប្បញ្ញត្តិទាំងនេះនៃក្រមរដ្ឋប្បវេណីទេ។ ការរំលាយដោយស្ម័គ្រចិត្តនៃអង្គការមិនមែនរដ្ឋាភិបាល ក៏ត្រូវបានអនុញ្ញាតផងដែរ ហើយនីតិវិធីសម្រាប់ការរំលាយនេះជាធម្មតា មានចែងនៅក្នុងលក្ខន្តិកៈនៃអង្គការបានចុះបញ្ជីនីមួយៗ។

ការបារម្ភកាន់តែច្រើនដែលត្រូវបានសម្តែងដោយអង្គការសិទ្ធិមនុស្សមួយចំនួន ថាមន្ត្រីទទួលអាណត្តិដោយការបោះឆ្នោត និងសមាជិកនៃកងកម្លាំងសន្តិសុខ (ពោលគឺ នគរបាល និងយោធា) កំពុងប្រើសម្ពាធ ការបង្ខិតបង្ខំ និងរហូតដល់ការប្រើកម្លាំង ដើម្បីចាត់ការជាមួយបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងសមាជិកសហគមន៍ ដែលនៅទីនោះ អង្គការមិនមែនរដ្ឋាភិបាលទាំងនោះធ្វើប្រតិបត្តិការ[24]។ និន្នាការនៃឥរិយាបថនេះ ហាក់បីដូចជាឃើញកាន់តែច្បាស់ទាក់ទិននឹងអង្គការមិនមែនរដ្ឋាភិបាលទាំងឡាយ ដែលធ្វើសកម្មភាពការពារសិទ្ធិដីធ្លីរបស់សហគមន៍ក្រីក្របំផុតនៅតាមតំបន់ទីក្រុងនិងជនបទ ការគ្រប់គ្រងធនធានធម្មជាតិ និងការជំរុញសេរីភាពនៃការបញ្ចេញមតិ ការជួបប្រជុំ និងការបង្កើតសមាគម។ ក្នុងចំណោមសកម្មភាពទាំងនេះ ការឃាត់ខ្លួនបុគ្គលិកអង្គការសង្គមស៊ីវិល និងសមាជិកសហគមន៍ដោយនគរបាលមូលដ្ឋាន ចំពោះការពាក់ព័ន្ធក្នុងសកម្មភាពទាំងនេះ គឺជាមូលហេតុនៃការបារម្ភដោយឡែកមួយ។ សម្តីខាងក្រោមគឺជាបទពិសោធន៍រួមនៃអ្នកផ្តល់សម្ភាសន៍បីនាក់ – ការដាក់បញ្ចូលគ្នានេះ គឺសំដៅការពារអនាមិកភាពនៃអ្នកផ្តល់សម្ភាសន៍។

> យើងទទួលការគម្រាមជាច្រើន និងការសម្លុតថានឹងសម្លាប់ ឬបិទការិយាល័យ។ ពួកគេបានបញ្ជូននគរបាលឲ្យតាមដានសកម្មភាពយើង។ មនុស្សចម្លែកដើរតាមរាល់ថ្ងៃ។ គេឈប់ចតនៅជិតផ្ទះខ្ញុំ និងឃ្លាំមើលរាល់អ្វីៗដែលខ្ញុំធ្វើ។ គេបញ្ជូនមនុស្សឲ្យមកបាញ់ខ្ញុំដល់ផ្ទះ ហើយពួកគេសម្លុតកូនស្រីខ្ញុំ។ រឿងនេះធ្វើឲ្យប្រពន្ធខ្ញុំភ័យ។ ថ្មីៗនេះ នៅពេលខ្ញុំរៀបចំទិវាជនជាតិដើមភាគតិច ហើយខ្ញុំមិនបានផ្តល់ [ពេលជូន] សមាជិកសភាឲ្យថ្លែងទៅកាន់សហគមន៍ ពួកគេមិនសប្បាយចិត្ត និងបានប្រាប់ខ្ញុំថា ពួកគេនឹងរាយការណ៍ទៅក្រសួងបរិស្ថានឲ្យបិទការិយាល័យរបស់យើង។
>
> អ្នកផ្តល់សម្ភាសន៍អនាមិក

---

[24] See, for example, http://www.hrw.org/world-report/2013/country-chapters/cambodia, accessed 31 March 2013

ដូចបានកត់សម្គាល់រួចហើយក្នុងផ្នែកទី ២ – វិធីសាស្ត្រ ដកស្រង់សម្ដីដាក់បញ្ចូលគ្នា ធ្វើឲ្យមានការលំបាកក្នុងការផ្សារភ្ជាប់សកម្មភាពទៅនឹងបុគ្គលដោយឡែកណាមួយ។ គេមិនដឹងច្បាស់ទេថាតើ 'យើង' ឬ 'ពួកគេ' អាចគឺជាអ្នកណានៅក្នុងការដកស្រង់សម្ដីខាងលើ។

បច្ចុប្បន្ន អង្គការសង្គមស៊ីវិលនៅកម្ពុជាមិនស្ថិតក្រោមសវនកម្ម ឬអធិការកិច្ចផ្លូវការរបស់រាជរដ្ឋាភិបាលទេ ទោះជាមានការតាមដានក្រៅផ្លូវការលើព្រឹត្តិការណ៍ និងសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល ហាក់ដូចជារឿងធម្មតា។ ដូចគ្នានេះដែរ ការរាយការណ៍ជាសាធារណៈនៃអង្គការសង្គមស៊ីវិលមិនត្រូវបានតម្រូវ ឬបញ្ជាក់នៅក្នុងច្បាប់ពាក់ព័ន្ធឡើយ។ ប៉ុន្តែ សេចក្ដីព្រាងច្បាប់ចុងក្រោយស្ដីពីអង្គការមិនមែនរដ្ឋាភិបាល និងសមាគម មានបទប្បញ្ញត្តិសម្រាប់ការធ្វើសវនកម្មនិងអធិការកិច្ចរបស់រាជរដ្ឋាភិបាលលើអង្គការមិនមែនរដ្ឋាភិបាល។ មានការស្នើឡើងថាអង្គការមិនមែនរដ្ឋាភិបាលត្រូវបើកបញ្ជីហិរញ្ញវត្ថុរបស់ខ្លួន សម្រាប់អធិការកិច្ចដោយក្រសួងហិរញ្ញវត្ថុ ឬអាជ្ញាធរសវនកម្មជាតិ។ អង្គការសង្គមស៊ីវិលជាច្រើនហាក់បីដូចជាយល់ថាសំណើច្បាប់ថ្មីស្ដីពីអង្គការមិនមែនរដ្ឋាភិបាល និងសមាគម នឹងបង្កើនដោយមិនចាំបាច់នូវតួនាទីរបស់រាជរដ្ឋាភិបាលក្នុងការត្រួតពិនិត្យលើអង្គការសង្គមស៊ីវិលនិង អនុញ្ញាតឲ្យរាជរដ្ឋាភិបាលជ្រៀតជ្រែកឬត្រួតត្រាលើអង្គការសង្គមស៊ីវិល។

*ច្បាប់ប្រឆាំងអំពើពុករលួយ ឆ្នាំ២០១០* តម្រូវឲ្យមេដឹកនាំសង្គមស៊ីវិលរាយការណ៍ពីទ្រព្យសម្បត្តិ ប៉ុន្តែ បទបញ្ញត្តិនេះនៅមិនទាន់អនុវត្តនៅឡើយ។

ស្របតាម*ច្បាប់ស្ដីពីសារពើពន្ធ ឆ្នាំ២០០៤* អង្គការមិនមែនរដ្ឋាភិបាលមានសិទ្ធិសុំរួចពន្ធ។ ប្រការនេះមិនមែនមានលក្ខណៈស្វ័យប្រវត្តិទេ ហើយនីតិវិធីសុំអាចត្រូវចំណាយពេលវែង[25]។ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលនៅតែត្រូវបង់ពន្ធប្រាក់ចំណូល (ប្រាក់ខែ) ហើយនៅតែត្រូវតែគោរពតាមលក្ខខ័ណ្ឌពាក់ព័ន្ធផ្សេងទៀត រួមមានការរួមវិភាគទានដល់បេឡាជាតិរបបសន្តិសុខសង្គម។ ក្នុងការអនុវត្តជាក់ស្តែង អង្គការមិនមែនរដ្ឋាភិបាលជាច្រើនមិនបង់ពន្ធទេ ទោះបីជាពួកគេមិនបានទទួលការលើកលែងស្របតាមច្បាប់ក្ដី។

ច្បាប់នៅពេលខាងមុខទាក់ទិននឹងសហជីព សមាគមកសិករ និងការគ្រប់គ្រងដី ក៏ដូចជាសំណើច្បាប់គ្រប់គ្រងប្រព័ន្ធអ៊ីនធឺណេត ក៏អាចប៉ះពាល់ដល់លទ្ធភាពរបស់សង្គមស៊ីវិលក្នុងការធ្វើប្រតិបត្តិការដែរ។ គេត្រូវរង់ចាំមើលថាតើច្បាប់ទាំងនេះនឹងប៉ះពាល់សង្គមស៊ីវិលយ៉ាងដូចម្ដេច។

---

[25] http://cambodianlaw.wordpress.com/2011/05/30/do-ngo-employees-have-to-pay-tax-on-salary/, accessed 1 December 2013

## វិធីសាស្ត្រ

ព័ត៌មានដែលបានពន្យល់នៅទីនេះ គឺផ្អែកលើការសិក្សាឯកសារជាច្រើន និងការសម្ភាសន៍ជាមួយសមាជិកសង្គមស៊ីវិលប្រាំនាក់។ អ្នកផ្តល់សម្ភាសន៍ រួមមានតំណាងមកពីអង្គការមួយដែលដឹកនាំដោយជនជាតិដើមភាគតិច អង្គការផ្តល់សេវាច្បាប់ អង្គការផ្តល់សេវាយុវជន អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងអង្គការសមាជិកភាព។ ព័ត៌មានដែលមានត្រូវបានសម្រិតសម្រាំងនិងផ្ទៀតផ្ទាត់នឹងភស្តុតាងផ្សេងៗដែលបានមកពី ការសន្ទនាក្រៅផ្លូវការជាមួយតួអង្គសង្គមស៊ីវិល។

## សេចក្តីសង្ខេបអំពីបញ្ហាប្រឈមសំខាន់ៗ

បញ្ហាប្រឈមសំខាន់ៗទាក់ទិននឹងកិច្ចប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិលនៅកម្ពុជារួមមាន៖

- អនុលោមភាពទាបជាមួយនឹងបទប្បញ្ញត្តិច្បាប់ជាធរមាន ដោយអង្គការសង្គមស៊ីវិល
- កាតព្វកិច្ចរាយការណ៍ដែលមានលក្ខណៈស្មុគ្រស្មាញ និង ពិបាកយល់
- សមត្ថភាពមិនគ្រប់គ្រាន់នៃមន្ត្រីរាជរដ្ឋាភិបាលពាក់ព័ន្ធដើម្បីអនុវត្តបទប្បញ្ញត្តិច្បាប់ជាធរមាន
- កង្វះឯកភាពគ្នាក្នុងការអនុវត្តក្របខ័ណ្ឌគតិយុត្តិ និងបទប្បញ្ញត្តិច្បាប់ ដោយតួអង្គថ្នាក់ក្រោមជាតិនៅក្នុងរាជរដ្ឋាភិបាល
- ការចំណាយប្រាក់ក្រៅផ្លូវការជូនដល់បុគ្គលិករាជរដ្ឋាភិបាលមួយចំនួន ដើម្បីសម្រួលកិច្ចប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិល
- អវត្តមាន និង អសង្គតិភាព នៃផលវិបាកចំពោះការខកខានមិនបានគោរពតាមកាតព្វកិច្ចស្របច្បាប់
- ម្តងម្កាល ប្រើនូវការបង្ខិតបង្ខំ សម្ពាធ ឬកម្លាំងជាពាក្យសម្តី ឬកងកម្លាំង ដោយក្រុមសន្តិសុខមូលដ្ឋាន និង/ឬ កងកម្លាំងសន្តិសុខជាតិ (ឬ តំណាងពួកគេ) មន្ត្រីទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត និង/ឬ មន្ត្រីរាជរដ្ឋាភិបាល នៅពេលចាត់ការជាមួយបុគ្គលិកមួយចំនួននៃអង្គការមិនមែនរដ្ឋាភិបាល ជាពិសេស អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងការងារសិទ្ធិមនុស្ស
- អវត្តមាននៃយន្តការតវ៉ាក្នុងករណីនៃការលុបបញ្ជី ការព្យួរការងារ ឬការរំលាយ
- ការបារម្ភក្នុងចំណោមតួអង្គសង្គមស៊ីវិលទាក់ទិននឹងសក្តានុពលសម្រាប់បំពានការប្រើច្បាប់គ្រោងថ្មីស្តីពីអង្គការមិនមែនរដ្ឋាភិបាល និងសមាគម។

## ផ្នែកទី ៥: លទ្ធភាពទទួលធនធាន[26]

### ទស្សនៈរួម

ចំណាយសរុបប្រចាំឆ្នាំដោយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងក្នុងស្រុក នៅកម្ពុជា ត្រូវបានប៉ាន់ស្មានថាមានចំនួន ៦០០-៧០០ លានដុល្លារអាមេរិក ដែលប្រដមប្រសងគ្នានឹងចំណាយសរុបបច្ចុប្បន្នរបស់រាជរដ្ឋាភិបាលលើសេវាសង្គមកិច្ច (គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ឆ្នាំ ២០១៣)។ អង្គការសង្គមស៊ីវិលកម្ពុជា ពឹងផ្អែកយ៉ាងខ្លាំងលើហិរញ្ញប្បទានឥតសំណងនិងអំណោយអន្តរជាតិ។ មានឧបសគ្គផ្លូវច្បាប់តិចតួចចំពោះការទទួលមូលនិធិអន្តរជាតិដោយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនៅកម្ពុជា ដូចដែលមានចែងក្នុង*ច្បាប់ប្រឆាំងភេរវកម្ម ឆ្នាំ២០០៧*។ តាមពិតក្របខ័ណ្ឌគតិយុត្តិសម្រាប់ទទួលមូលនិធិអាចចាត់ទុកបានថាមានលក្ខណៈអនុញ្ញាត។ ប៉ុន្តែ គេឃើញមានឧបសគ្គមិនមែនច្បាប់ជាច្រើនចំពោះការទទួលមូលនិធិ ដែលភាគច្រើនផ្សារភ្ជាប់នឹងការថយចុះនៃការមានមូលនិធិអន្តរជាតិ កំណើនការប្រកួតប្រជែងយកមូលនិធិនេះ និងសមត្ថភាពទាបជាទូទៅក្នុងការស្វែងរកមូលនិធិក្នុងចំណោមអង្គការសង្គមស៊ីវិលក្នុងស្រុក។ ជាការឆ្លើយតបទៅនឹងបញ្ហាទាំងនេះ អង្គការមិនមែនរដ្ឋាភិបាលកំពុងចូលរួមកាន់តែច្រើនក្នុងសហគ្រាសសង្គម។ សកម្មភាពមនុស្សធម៌ក្នុងស្រុកគឺមានស្តួចស្តើង ហើយហិរញ្ញប្បទានឥតសំណងពី រាជរដ្ឋាភិបាលគឺជារឿងមិនធម្មតា ថ្វីបើកំពុងកើនឡើងក្តី។

### របកគំហើញ

ចំណាយប្រចាំឆ្នាំសរុបដោយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងក្នុងស្រុក នៅកម្ពុជាត្រូវបានប៉ាន់ស្មានថាមានចំនួន ៦០០-៧០០ លានដុល្លារអាមេរិក (គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ឆ្នាំ២០១៣)។ ចំនួនប៉ាន់ស្មាននេះមានលក្ខណៈចម្រូងចម្រាស់ – របាយការណ៍ស្តីពីប្រសិទ្ធភាពអភិវឌ្ឍន៍កម្ពុជា ឆ្នាំ២០១១ លើកឡើងថា មានវិភាគទានតិចជាងចំនួននេះច្រើនប្រហែល ២០០ លានដុល្លារអាមេរិក[27]។ ក្នុងន័យទូលាយ កម្រិតនៃចំណាយរបស់អង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជាហាក់បីដូចជាមានលក្ខណៈប្រដមប្រសងនឹងចំណាយសរុបបច្ចុប្បន្នរបស់រាជរដ្ឋាភិបាល លើសេវាសង្គមកិច្ច (គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ឆ្នាំ២០១២)។ មួយផ្នែក ប្រាក់នេះត្រូវចាយលើបុគ្គលិកកម្ពុជាប្រហែល ៤៣.០០០ នាក់ (គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ឆ្នាំ២០១៣)។ ប្រាក់ខ្លះ

---

[26] For the purposes of this research, access to financial resources is of key interest and this section addresses this issue. Civil society organisations also require access to technical and human resources, however, a review of how these resources can be accessed in Cambodia was beyond the scope of the research.

[27] See http://www.cdc-crdb.gov.kh/cdc/aid_management/DER%202011%20FINAL%20(31%20Oct%202011).pdf, accessed 1 December 2013

នៃមូលនិធិទាំងនេះ (ប៉ាន់ស្មានថាមានចំនួន ៩៩ លានដុល្លារ) ត្រូវបានបញ្ចេញដល់សមាគមនិង អង្គការសហគមន៍តូចតាច (គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ឆ្នាំ២០១៣)។

ជាង ៣០% នៃអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិដែលធ្វើប្រតិបត្តិការនៅកម្ពុជា បង្ហាញថា មានចំណាយប្រចាំឆ្នាំលើពី ១ លានដុល្លារ ប៉ុន្តែ មានតែ ៤% នៃអង្គការក្នុងស្រុកប៉ុណ្ណោះដែលស្ថិត ក្នុងប្រភេទនេះ ជាទូទៅ អង្គការក្នុងស្រុកច្រើនមានការលំបាកខាងហិរញ្ញវត្ថុ ជាងអង្គការអន្តរជាតិ (Suárez & Marshall ឆ្នាំ២០១២)។ ប៉ុន្តែ ពុំមានការរឹតត្បិតតាមផ្លូវច្បាប់លើរបៀបដែលអង្គការសង្គម ស៊ីវិលក្នុងស្រុកអាចរៃអង្គាសមូលនិធិឡើយ។ ការលំបាកក្នុងការរកមូលនិធិភាគច្រើនហាក់បីដូចជា ត្រូវបានផ្សារភ្ជាប់ទៅនឹងសមត្ថភាពទាបនៃអង្គការក្នុងស្រុក – ធៀបទៅនឹងអង្គការអន្តរជាតិ – ក្នុងការ កំណត់អត្តសញ្ញាណម្ចាស់ជំនួយសមស្រប ការប្រាស្រ័យទាក់ទងជាមួយពួកគេជាភាសាអង់គ្លេស ការ កសាងទំនាក់ទំនងប្រកបដោយទំនុកចិត្តជាមួយពួកគេ និងការដាក់សំណើច្បាស់លាស់ និងអាច សម្រេចបាន (ប្រកបដោយហេតុផល) ដើម្បីសុំមូលនិធិ។ ដូចនៅតាមប្រទេសភាគច្រើនអញ្ចឹងដែរ លទ្ធភាពទទួលមូលនិធិបរទេសមានលក្ខណៈប្រកួតប្រជែងខ្ពស់។ ស្ទើរតែគ្មានសកម្មភាពមនុស្សធម៌ ក្នុងស្រុក មានន័យថាការរកមូលនិធិក្នុងស្រុកក៏ជួបការលំបាកដែរ។

ទោះបីជាមានការលំបាក ជាមធ្យម អង្គការមិនមែនរដ្ឋាភិបាលរក្សាប្រភពផ្តល់មូលនិធិចំនួនពីរ (Suárez & Marshall ឆ្នាំ ២០១២)។ ហិរញ្ញប្បទានឥតសំណង និងអំណោយ គឺជាប្រភពផ្តល់មូលនិធិ សំខាន់បំផុតនិងទូទៅបំផុតសម្រាប់អង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើប្រតិបត្តិការនៅកម្ពុជា។ ជារួម ហិរញ្ញប្បទានឥតសំណង និងកិច្ចសន្យា ត្រូវបានផ្តល់ដោយអង្គការសហប្រជាជាតិ រដ្ឋាភិបាល បរទេស និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ដោយជិត ៦០% នៃអង្គការក្នុងស្រុកនិងអន្តរជាតិនៅ កម្ពុជាទទួលមូលនិធិពីអង្គការទាំងនេះ។ ដូច្នេះ សង្គមស៊ីវិលកម្ពុជាពឹងផ្អែកយ៉ាងខ្លាំងលើហិរញ្ញប្ប ទានឥតសំណងបែបនេះ។ ជិត ៥៦% នៃអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកទទួលអំណោយពីបុគ្គល – ភាគច្រើនជនបរទេស – និង ៣២% នៃអង្គការក្នុងស្រុករកបានប្រាក់ចំណូលដោយខ្លួនឯង តាមរយៈ សកម្មភាពពាណិជ្ជកម្ម (Suárez & Marshall ឆ្នាំ ២០១២)។ សកម្មភាពពាណិជ្ជកម្ម អាចរួមមាន ចំណូលពីមន្ទីរព្យាបាលរោគ ភោជនីយដ្ឋាន ការជួលការិយាល័យ ការលក់ឯកសារបោះពុម្ពផ្សាយ និង ហាងលក់គ្រឿងសិប្បកម្ម (គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ឆ្នាំ២០១២)។ ជាង ៤០% នៃ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ មានការផ្តល់មូលនិធិរដ្ឋាភិបាលឧបតោភាគី (មិនមែនកម្ពុជា) តាមរយៈជំនួយបរទេស ថ្វីបើមានតែ ២២% ប៉ុណ្ណោះនៃអង្គការមិនមែនរដ្ឋាភិបាលជាតិទទួលមូលនិធិ តាមវិធីនេះ (Suárez & Marshall ឆ្នាំ២០១២)។ យូរៗម្តង អង្គការមិនមែនរដ្ឋាភិបាលខ្លះអាចទទួល មូលនិធិរដ្ឋ។ ការផ្តល់មូលនិធិនិងការជួយគាំទ្ររាជរដ្ឋាភិបាលកម្ពុជា ក្នុងទម្រង់ជាការលើកលែងពន្ធ ឧបត្ថម្ភធន ឬភាពជាដៃគូក្នុងគម្រោង មានចំនួន ៣,៨% នៃចំណូលរបស់អង្គការមិនមែនរដ្ឋាភិបាល (គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ឆ្នាំ២០១២)។

រាល់អង្គការមិនមែនរដ្ឋាភិបាលដែលបានទទួលមូលនិធិនៅកម្ពុជា យ៉ាងហោចណាស់ ទទួល មូលនិធិខ្លះនៃមូលនិធិរបស់ខ្លួនពីបរទេស (Bañez-Ockelford ឆ្នាំ២០១១)។ មូលនិធិបរទេស ជាទូទៅ

គាំទ្រកម្មវិធីនិងសកម្មភាពសង្គមស៊ីវិលពេញលេញ ទោះបីជាអង្គការជាច្រើនមានការលំបាកក្នុងការរកបានមូលនិធិគ្រប់គ្រាន់សម្រាប់សកម្មភាពទាំងឡាយដែលអាចចាត់ទុកថាជា 'ចំណាយប្រតិបត្តិការ' ដូចជាការរៀបចំនិងការគ្រោងកម្មវិធី ការធ្វើផែនការយុទ្ធសាស្ត្រ ការអភិវឌ្ឍអភិបាលកិច្ច ការជំរុញគំនិតច្នៃប្រឌិត ការស្រាវជ្រាវ ការអភិវឌ្ឍសមត្ថភាពបុគ្គលិក និងការងារផ្សេងទៀត។ ម្ចាស់ជំនួយខ្លះសុខចិត្តរួមវិភាគទានដល់ថ្លៃចំណាយទាំងនេះ ប៉ុន្តែ ម្ចាស់ជំនួយខ្លះទៀតមិនព្រម អាស្រ័យលើបទបញ្ជាផ្ទៃក្នុងរបស់ពួកគេ។ ម្ចាស់ជំនួយភាគច្រើន កំណត់អត្រាចំណាយរដ្ឋបាលប្រហែល ១០%។ ជួនកាល អង្គការសង្គមស៊ីវិលក្នុងស្រុកអាចរកបានមូលនិធិគ្មានចំណងពីចំណូលរកបាន ឬពីម្ចាស់ជំនួយជាបុគ្គល។ មូលនិធិទាំងនេះមានប្រយោជន៍ជាពិសេសសម្រាប់បំពេញថ្លៃចំណាយស្នូល ឬចំណាយប្រតិបត្តិការ។

អង្គការនៅតាមសហគមន៍ (CBOs) និងបណ្តាញនៃអង្គការមិនមែនរដ្ឋាភិបាល មិនបានចុះបញ្ជី មិនអាចទទួលមូលនិធិបាន ភាគច្រើនដោយសារគោលនយោបាយម្ចាស់ជំនួយមិនអនុញ្ញាតឲ្យធ្វើដូច្នេះ។ ប៉ុន្តែ ជាធម្មតា អង្គការនិងបណ្តាញទាំងនេះអាចទទួលដោយស្របច្បាប់នូវមូលនិធិដោយប្រយោលតាមរយៈអង្គការមិនមែនរដ្ឋាភិបាលបានចុះបញ្ជី ដែលអាចដើរតួជាអ្នកឧបត្ថម្ភ នៃអង្គការនៅតាមសហគមន៍នោះ ឬលេខាធិការដ្ឋានសម្រាប់បណ្តាញ។

ក្នុងរយៈពេលជាងម្ភៃឆ្នាំកន្លងមកនេះ ស្ថាប័នម្ចាស់ជំនួយបរទេសគឺជាប្រភពប្រាក់ចំណូលអាចទុកចិត្តបានជាងគេសម្រាប់អង្គការសង្គមស៊ីវិលកម្ពុជា។ ប៉ុន្តែ ក្រោយពេលវិនិយោគអស់រយៈពេលម្ភៃឆ្នាំ លើសង្គមស៊ីវិលកម្ពុជា និងជាពិសេស នៅពេលដែលប្រទេសកម្ពុជាត្រៀមខ្លួនក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមមួយក្នុងរយៈពេលពីរបីឆ្នាំខាងមុខនេះ ម្ចាស់ជំនួយជាច្រើនបានចាប់អារម្មណ៍កាន់តែច្រើនឡើងលើការជំរុញនិរន្តរភាពនៃកម្មវិធី ដោយប្រើទម្រង់ផ្តល់មូលនិធិ ជាជម្រើស សំដៅកាត់បន្ថយការវិនិយោគអន្តរជាតិលើការអភិវឌ្ឍកម្ពុជា។ ប្រទេសផ្សេងទៀតក្នុងតំបន់ ជាពិសេសមីយ៉ាន់ម៉ា បានលេចឡើងជាអាទិភាពខ្ពស់ជាងសម្រាប់ការចែកចាយជំនួយ។ នៅពេលថ្មីៗនេះ ម្ចាស់ជំនួយខ្លះបានបិទការិយាល័យរបស់ខ្លួននៅកម្ពុជា។ ឧទាហរណ៍ ក្រសួងអភិវឌ្ឍន៍អន្តរជាតិនៃចក្រភពអង់គ្លេស បានបិទការិយាល័យរបស់ខ្លួននៅកម្ពុជាក្នុងខែមករា ឆ្នាំ២០១១ ប្រទេសកាណាដាបានបញ្ចប់ទំនាក់ទំនងផ្តល់មូលនិធិឧបតោភាគីរបស់ខ្លួនជាមួយកម្ពុជា ដែលចូលជាធរមានចាប់ពីខែមិថុនា ឆ្នាំ២០១៣ ហើយអង្គការ Danida ដែលគឺជាទីភ្នាក់ផ្តល់ជំនួយនៃប្រទេសដាណឺម៉ាក ក៏គ្រោងបិទទ្វារផងដែរ។

ជាការឆ្លើយតបទៅនឹងការប្រែប្រួលអាទិភាពរបស់ម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាលជាច្រើនស្ថិតក្រោមសម្ពាធត្រូវចាប់ផ្តើមរកប្រាក់ចំណូលដោយខ្លួនឯង។ ការបង្កើតសហគ្រាសសង្គមគឺជាការអនុវត្តធម្មតាកាន់តែច្រើននៃអង្គការមិនមែនរដ្ឋាភិបាល។ យោងតាមអ្នកផ្តល់សម្ភាសន៍មួយរូប ស្ថាប័នសារព័ត៌មាន និងអង្គការមិនមែនរដ្ឋាភិបាលអភិវឌ្ឍន៍កសិកម្ម បានទទួលជោគជ័យបង្គួរក្នុងការរកប្រាក់ចំណូលដោយខ្លួនឯង។ មានអង្គការមិនមែនរដ្ឋាភិបាលខ្លះ កំពុងប្រែក្លាយខ្លួនទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬសហគ្រាសសង្គម ឬសកលវិទ្យាល័យ។ ប៉ុន្តែ អង្គការមិនមែនរដ្ឋាភិបាលដែលផ្លាស់ប្តូរ

ឋានៈស្របច្បាប់ខ្លួនទៅជាសហគ្រាស(សង្គម)- ដែលតាមពិត គឺជាគ្រឹះស្ថានរកចំណេញមួយ កំពុងតែ "មិនគោរព" លក្ខន្តិកៈរបស់ខ្លួន។

កិច្ចព្រមព្រៀងភាពជាដៃគូ គឺសំខាន់ណាស់សម្រាប់ការធ្វើប្រតិបត្តិការ (និងទទួលហិរញ្ញប្បទានឥតសំណង) នៅកម្ពុជា។ ប៉ុន្តែ រាជរដ្ឋាភិបាលកម្ពុជាមិនមានភាពជាដៃគូផ្លូវការកម្រិតខ្ពស់ជាមួយសង្គមស៊ីវិល ដែលសម្រួលការផ្ទេរមូលនិធិទៅឲ្យសង្គមស៊ីវិល ពីរាជរដ្ឋាភិបាល។ រាជរដ្ឋាភិបាលបានបង្កើតទំនាក់ទំនងជាមួយផ្នែកឯកជន តាមរយៈវេទិកាពាណិជ្ជកម្ម និងភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ជាពិសេសតាមរយៈ គណៈកម្មាធិការសម្របសម្រួលរាជរដ្ឋាភិបាល-ម្ចាស់ជំនួយ និង វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា។ ប៉ុន្តែ វេទិកាទាំងនេះមិនរាប់បញ្ចូលការចូលរួមរបស់សង្គមស៊ីវិលទេ។ គេពុំឃើញមានយន្តការសមមូល ពោលគឺ វេទិកាឬកិច្ចព្រមព្រៀង ដែលជួយសម្រួលកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងសង្គមស៊ីវិលឡើយ។ គួបផ្សំនឹងតួនាទីមានកម្រិតនៃសង្គមស៊ីវិល (ពោលគឺ ផ្តល់តែសេវាកម្ម) នៅក្នុងយុទ្ធសាស្ត្រថ្មីស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៤-ឆ្នាំ២០១៨ គេហាក់បីដូចជាមើលឃើញថារាជរដ្ឋាភិបាលមិនទទួលស្គាល់ពេញលេញនូវសក្តានុពលតួនាទីដែលអង្គការសង្គមស៊ីវិលអាចបំពេញ ជាដៃគូយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍប្រទេសកម្ពុជា។

ទោះបីជាមិនមានកិច្ចព្រមព្រៀងភាពជាដៃគូក្នុងកម្រិតទូលាយឬខ្ពស់ក្តី ក៏រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតមូលនិធិមួយចំនួនសម្រាប់អង្គការមិនមែនរដ្ឋាភិបាលដែរ ភាគច្រើនតាមសំណើដៃគូបរទេស។ គម្រោងដែលទទួលហិញ្ញប្បទានច្រើនពីអន្តរជាតិ ដូចជាគម្រោងទាមទារអភិបាលកិច្ចល្អដែលត្រូវបានផ្តល់មូលនិធិដោយធនាគារពិភពលោក បានតម្រូវឲ្យរាជរដ្ឋាភិបាលទុកមូលនិធិមួយផ្នែកសម្រាប់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។ លក្ខណៈវិនិច្ឆ័យសម្រាប់ទទួលបានមូលនិធិទាំងនេះជាទូទៅ មានលក្ខណៈច្បាស់លាស់ ដោយសារអនុវត្តតាមគោលការណ៍ណែនាំលទ្ធកម្មដែលកំណត់ដោយម្ចាស់ជំនួយ។ ឧទាហរណ៍ ក្រសួងព័ត៌មាន ក្រសួងការងារ និងក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និងអធិការកិច្ច ដោយប្រើមូលនិធិកញ្ចប់ពីធនាគារពិភពលោក និងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិអូស្ត្រាលី (AusAid) និងតាមរយៈការផ្សារភ្ជាប់អង្គការនានា ដូចជាមូលនិធិអាស៊ី ជាដើម បានចែកចាយមូលនិធិជូនអង្គការមិនមែនរដ្ឋាភិបាលជាង ២០។ ជាឧទាហរណ៍មួយទៀត មូលនិធិជាតិសម្រាប់អង្គការមិនមែនរដ្ឋាភិបាល ដែលសំដៅពង្រីកសេវាច្បាប់ និងសង្គមកិច្ចជូនស្ត្រីនិងយុវនារីជាជនរងគ្រោះនៃអំពើហិង្សាផ្អែកលើយេនឌ័រ និងដែលត្រូវបានគ្រប់គ្រងដោយក្រសួងកិច្ចការនារី ដែលមានការជួយគាំទ្រពីអង្គការ GIZ និងAECID បានផ្តល់មូលនិធិជូនអង្គការមិនមែនរដ្ឋាភិបាល។ អង្គការមិនមែនរដ្ឋាភិបាលប្រាំមួយបានទទួលការគាំទ្រតាមរយៈ មូលនិធិជាតិសម្រាប់អង្គការ។ អ្នកផ្តល់សម្ភាសន៍ម្នាក់ ដែលមានបទពិសោធន៍ក្នុងការទទួលមូលនិធិរាជរដ្ឋាភិបាល បាននិយាយថានីតិវិធីសុំមូលនិធិមានលក្ខណៈស្មុគ្រស្មាញនិងការិយាល័យនិយម។ ចំណុចនេះហាក់បីដូចជាត្រូវបានផ្សារភ្ជាប់ទៅនឹងប្រការដែលថាក្រសួងរាជរដ្ឋាភិបាលពីរ ដែលមានកង្វល់និងរបៀបវារៈខុសគ្នាបន្តិច គ្រប់គ្រងរួមគ្នាលើហិរញ្ញប្បទានឥតសំណង។

ទោះបីជាឧទាហរណ៍នៃការចែកចាយមូលនិធិដោយរាជរដ្ឋាភិបាល ជូនអង្គការមិនមែនរដ្ឋាភិបាលកំពុងកើនឡើងក្តី ក៏អង្គការសង្គមស៊ីវិលជាច្រើននៅតែយល់ថាមូលនិធិរាជរដ្ឋាភិបាលមិនមានលក្ខណៈអាចសុំបានចំពោះពួកគេ។ ម្យ៉ាងទៀត តួនាទីរបស់រាជរដ្ឋាភិបាលជាអ្នកផ្តល់មូលនិធិជូនកាល ត្រូវបានមើលស្រាល។ ម្ចាស់ជំនួយអន្តរជាតិ និងអ្នកគាំទ្រមូលនិធិ ទំនងជាទទួលបានការគួរឲ្យសរសើរច្រើនចំពោះការបានផ្តល់មូលនិធិ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលត្រូវបានគេចាត់ទុកថាជាអ្នកស្វែងរក ជាជាងអ្នកផ្តល់មូលនិធិ។ ពុំមានការយល់ឃើញក្នុងចំណោមតួអង្គសង្គមស៊ីវិលថារាជរដ្ឋាភិបាលនឹងបន្តគាំទ្រដល់ពួកគេជាថវិកា ដោយគ្មានតម្រូវឲ្យធ្វើដូច្នេះពីដៃគូអន្តរជាតិឡើយ។

> រាជរដ្ឋាភិបាលមិនមានបំណងចង់ឃើញអង្គការមិនមែនរដ្ឋាភិបាល មានធនធានល្អជាងទេ។ ក្របខ័ណ្ឌគតិយុត្តិនៅកម្ពុជាមិនលើកទឹកចិត្ត ដល់ការកៀរគរធនធានក្នុងស្រុកសម្រាប់អង្គការមិនមែនរដ្ឋាភិបាលឡើយ។
>
> អ្នកផ្តល់សម្ភាសន៍អនាមិក

ការគួរឲ្យសរសើរ រាជរដ្ឋាភិបាលកម្ពុជាមានប្រវត្តិល្អក្នុងការគាំទ្រអង្គការសង្គមស៊ីវិលនៅពេលមានវិបត្តិជំនួយមនុស្សធម៌ ដូចជាទឹកជំនន់និងព្យុះជាដើម។ រាជរដ្ឋាភិបាលមានទំនាក់ទំនងរឹងមាំជាពិសេសជាមួយកាកបាទក្រហមកម្ពុជា ដែលគឺជាអង្គការមនុស្សធម៌ធំជាងគេបំផុតនៅកម្ពុជា។ ជាសំខាន់ គ្រួសារលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មានសម្ព័ន្ធភាពយ៉ាងស្និទ្ធក្នុងអភិបាលកិច្ចសកម្មភាពនេះ។

មានប្រវត្តិឬវប្បធម៌តិចតួចនៃសកម្មភាពមនុស្សធម៌ដែលផ្តល់អត្ថប្រយោជន៍ ដល់អង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា។ ប៉ុន្តែ ការផ្តល់អំណោយដើម្បីគោលបំណងសាសនា និងជូនគណបក្សនយោបាយ គឺជារឿងធម្មតា ហើយមាត្រា ១៦ នៃ*ច្បាប់ស្តីពីសារពើពន្ធ ឆ្នាំ២០០៤* អនុញ្ញាតឲ្យកាត់បន្ថយពន្ធតិចតួចសម្រាប់ការផ្តល់អំណោយមនុស្សធម៌។ អង្គការមិនមែនរដ្ឋាភិបាលខ្លះ បានសាកល្បងជម្រុញសកម្មភាពមនុស្សធម៌ក្នុងស្រុក ប៉ុន្តែកិច្ចប្រឹងប្រែងទាំងនេះមានលក្ខណៈស្រាល និងមិនទាន់បានធ្វើការទាក់ទាញខ្លាំងនៅឡើយ។ អង្គការ Furada ដែលគឺជាសម្ព័ន្ធភាពនៃអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលផ្តល់សេវាកម្មជូនជនពិការ គឺជាករណីមួយនៃចំណុចនេះ។ អង្គការ Furada បានអភិវឌ្ឍយុទ្ធការរកទីផ្សារ និងបានរៀបចំពិធីប្រមូលមូលនិធិមួយចំនួន។ អង្គការនេះក៏រកបានជំនួយអន្តរជាតិផងដែរក្នុងការអភិវឌ្ឍវប្បធម៌មនុស្សធម៌ក្នុងស្រុកចំពោះជនពិការ។ ប៉ុន្តែ ជោគជ័យរបស់អង្គការ Furada គឺមានតិចតួចណាស់។ ជាទូទៅ សាជីវកម្មនិងជនកម្ពុជាមិនមែនជាអ្នករួមវិភាគទានហិរញ្ញវត្ថុទៀងទាត់ឲ្យអង្គការសង្គមស៊ីវិលទេ។

គម្រោងនានានៅតាមភូមិក្នុងទូទាំងប្រទេសកម្ពុជា ច្រើនតែតម្រូវឲ្យសមាជិកសហគមន៍មូលដ្ឋានចូលរួមវិភាគទានមិនមែនជាសាច់ប្រាក់។ ឧទាហរណ៍ អ្នកភូមិអាចត្រូវបានស្នើឲ្យបរិច្ចាគកម្លាំងពលកម្ម ឬ រកធនធានធម្មជាតិសម្រាប់ការសាងសង់ ដូចជាឫស្សី ជាដើម។

ចំពោះក្របខ័ណ្ឌគតិយុត្តិសម្រាប់ទទួលនិងចាយមូលនិធិ ការរឹតត្បិតគឺមានតិចតួចបំផុត។ *ច្បាប់ប្រឆាំងភេរវកម្មឆ្នាំ ២០០៧* មានបទប្បញ្ញត្តិលម្អិតទាក់ទិននឹងសំណួរនៃជំនួយហិរញ្ញប្បទាន និង ជំនួយសម្ភារៈដល់ភេរវកម្ម និង "ផ្តល់អំណាចច្រើនឲ្យប្រតិបត្តិការក្នុងភាពរិតត្បិតហិរញ្ញប្បទានដល់សកម្មភាពនិងអង្គការទាំងឡាយ ដែលផ្សារភ្ជាប់ទៅនឹងភេរវកម្ម" (Observatory for the Protection of Human Rights Defenders ឆ្នាំ២០១០ ទំព័រ ១១)។ សម្រាប់ចំណាយ ការរឹតត្បិតច្រើនមានប្រភពចេញពីលក្ខន្តិកៈរបស់អង្គការសង្គមស៊ីវិលខ្លួនឯង ជាជាងច្បាប់ជាតិ។ ជាទូទៅ អង្គការសង្គមស៊ីវិល មានបញ្ញត្តិក្នុងលក្ខន្តិកៈរបស់ខ្លួនដើម្បីធានាឲ្យបានថាចំណូលមិនត្រូវបានចែកចាយឲ្យបុគ្គលិក ឬនាយកឡើយ និងថា ក្រោយពេលរំលាយអង្គការ មូលនិធិ ឬទ្រព្យសម្បត្តិ ដែលនៅសល់ ត្រូវបានផ្ទេរយ៉ាងសមស្រប ជូនកាល ទៅឲ្យអង្គការមិនមែនរដ្ឋាភិបាលដែលមានគោលដៅដូចគ្នា និងជូនកាលទៅឲ្យរាជរដ្ឋាភិបាល។

ការរឹតត្បិតខ្លះទាក់ទិននឹងការទទួល និងចាយធនធាន ត្រូវបានស្នើឡើងនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល និងសមាគម។ យោងតាមសេចក្តីព្រាងច្បាប់នេះ តួអង្គសង្គមស៊ីវិលនឹងត្រូវបញ្ជាក់ថាអំណោយមានប្រភពស្របច្បាប់។ បញ្ញត្តិនេះ មិនដូចជាមានបញ្ហាទេ ដោយសារវាមានសង្គតិភាពជាមួយ*ច្បាប់ប្រឆាំងភេរវកម្ម ឆ្នាំ២០០៧*។ សេចក្តីព្រាងច្បាប់នេះ ក៏តម្រូវផងដែរឲ្យអង្គការសង្គមស៊ីវិលកំណត់អត្រាចំណាយរដ្ឋបាល។

## **វិធីសាស្ត្រ**

ព័ត៌មានដែលពន្យល់នៅទីនេះ ត្រូវបានដកស្រង់ពីការសិក្សាឯកសារសំខាន់ៗ ការសម្ភាសន៍ជាមួយតួអង្គសង្គមស៊ីវិលបី និងការសម្ភាសន៍ជាមួយអ្នកសិក្សាមួយរូបដែលមានជំនាញឯកទេសខាងការស្រាវជ្រាវសេដ្ឋកិច្ច។ អ្នកផ្តល់សម្ភាសន៍ រួមមានតំណាងពីអង្គការអន្តរជាតិពីរ និងអង្គការក្នុងស្រុកមួយ។ ព័ត៌មានដែលមានត្រូវបានសម្រិតសម្រាំង និងផ្ទៀងផ្ទាត់ជាមួយនឹងភស្តុតាងពីនេះពីនោះ ព្រមទាំងការសន្ទនាក្រៅផ្លូវការជាមួយតួអង្គសង្គមស៊ីវិល។

## សេចក្តីសង្ខេបអំពីបញ្ហាប្រឈមសំខាន់ៗ

បញ្ហាប្រឈមសំខាន់ៗសម្រាប់អង្គការសង្គមស៊ីវិលកម្ពុជាក្នុងការទទួលបានធនធាន រួមមាន៖

- កង្វះខាតការលើកទឹកចិត្តជាផ្លូវការសម្រាប់ជំនួយដល់អង្គការសង្គមស៊ីវិលពីក្រុមហ៊ុនសាជីវកម្ម
- កំណើនការប្រកួតប្រជែងក្នុងចំណោមអង្គការសង្គមស៊ីវិល ដើម្បីទទួលបានមូលនិធិបរទេស
- កំណើនកង្វល់របស់ម្ចាស់ជំនួយអំពីនិរន្តរភាពហិរញ្ញវត្ថុនៃគម្រោងនិងការផ្លាស់ប្តូរអាទិភាពរបស់ម្ចាស់ជំនួយ (ងាកចេញពីកម្ពុជា)
- សមត្ថភាពស្ថាប័នទាបក្នុងការស្វែងរកមូលនិធិ
- ការទទួលស្គាល់សម្ពាធសម្រាប់អង្គការសង្គមស៊ីវិលឲ្យរកចំណូលដោយឯករាជ្យ
- សក្តានុពលនៃការអភិវឌ្ឍសហគ្រាសសង្គមដែលជំនួសដល់ការងារស្នូលរបស់សង្គមស៊ីវិល
- អវត្តមាននៃកិច្ចព្រមព្រៀងភាពជាដៃគូកម្រិតខ្ពស់ ឬយន្តការផ្តល់ជំនួយផ្លូវការផ្សេងទៀតរវាងរាជរដ្ឋាភិបាល និងសង្គមស៊ីវិលជារួម
- ភាពស្ទើរតែគ្មានវត្តមាននៃការផ្តល់អំណោយ/ជំនួយមនុស្សធម៌ក្នុងស្រុក លើកលែងតែទាក់ទិននឹងការផ្តល់អំណោយ សាសនា និងនយោបាយ
- កង្វះគោលនយោបាយ និងក្របខណ្ឌគតិយុត្តិទាក់ទងនិងសហគ្រាសសង្គម ដោយអង្គការសង្គមស៊ីវិល។

# ផ្នែកទី ៦: ការបញ្ចេញមតិ

## ទស្សនៈរួម

មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ចែងថាប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការជួបប្រជុំ។ ប៉ុន្តែ សារព័ត៌មាននៅកម្ពុជា ត្រូវបានគេយល់ថា 'មិនមានសេរីភាព' ហើយការរំលោភលើសេរីភាពបញ្ចេញមតិបានកំពុងកើនឡើងតាំងពីឆ្នាំ ២០១២ និងឈានចូលឆ្នាំ ២០១៣ ដល់កម្រិតមួយដែលត្រូវបានគេចាត់ទុកថា 'មិនប្រក្រតី'[28]។ ទូរទស្សន៍ និងកាសែត ភាគច្រើនត្រូវបានត្រួតត្រាដោយគណបក្សនយោបាយធំ ប៉ុន្តែ អ៊ីនធឺណេតត្រូវបានគ្រប់គ្រងយ៉ាងស្រាល។ *ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩* និងពេលខាងមុខ សំណើច្បាប់ថ្មីស្តីពីការប្រឆាំងការគ្រប់គ្រងប្រព័ន្ធអ៊ីនធឺណេត ផ្តល់ក្របខ័ណ្ឌគតិយុត្តិសម្រាប់សេរីភាពបញ្ចេញមតិនៅកម្ពុជា ដោយឆ្លើយតបទៅនឹងបញ្ហាបរិហាកេរ្តិ៍ ការផ្តល់ព័ត៌មានមិនពិត និងការញុះញង់។ ច្បាប់ទាំងពីរធ្វើឲ្យតួអង្គសង្គមស៊ីវិលមានកង្វល់ដោយសារវាត្រូវបានគេមើលឃើញថារារាំងដោយមិនចាំបាច់នូវសេរីភាពបញ្ចេញមតិ។ ម្យ៉ាងទៀត មាត្រា ៤១ នៃច្បាប់*ប្រឆាំងអំពើពុករលួយឆ្នាំ២០១០* រឹតត្បិតសេរីភាពការតវ៉ា ជាពិសេស ប្រឆាំងនឹងមន្ត្រីរាជរដ្ឋាភិបាល។ ទោះជាយ៉ាងណាក្តី អង្គការសង្គមស៊ីវិលហាក់បីដូចជាដឹងដោយខ្លួនឯងថាអ្វីអាចនិងមិនអាចនិយាយបានដោយប្រើចំណេះដឹងខាងវប្បធម៌ ដើម្បីធ្វើការវិនិច្ឆ័យអំពីរបៀបតស៊ូមតិប្រសើរបំផុតដើម្បីអ្វីដែលជាតម្រូវការ។ អ្នកផ្តល់សម្ភាសន៍ ក៏យល់ឃើញផងដែរថាការទិតៀនលើរាជរដ្ឋាភិបាល នៅពេលណាស្ថិតក្នុងព្រំដែនសន្ទតនិងមិនមានបញ្ជាក់ណាមួយ ភាគច្រើនត្រូវបានឃោគយល់។ តួអង្គសង្គមស៊ីវិលបាននិងកំពុងបញ្ចុះបញ្ចូលរាជរដ្ឋាភិបាលផ្តើមអោយមានច្បាប់ស្តីពីសេរីភាពព័ត៌មានជាច្រើនឆ្នាំ កន្លងមក។

## របកគំហើញ

មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ចែងថាប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការជួបប្រជុំ។ ជាការគាំទ្រចំពោះចំណុចនេះ កម្ពុជាគឺជាប្រទេសហត្ថលេខី ចំពោះរាល់សន្ធិសញ្ញាសិទ្ធិមនុស្ស

---

28 http://www.freedomhouse.org/report/freedom-press/2013/cambodia, accessed 19 November 2013 and http://www.cchrcambodia.org/admin/media/report/report/english/2013_09_19_CCHR_FoEx_Report_Repression_of_Expression_The_State_of_Free_Speech%20in_Cambodia_EN.pdf, accessed 2 December 2013

អន្តរជាតិ ដែលចែងពីសេរីភាពបញ្ចេញមតិ។ ប៉ុន្តែ ការប្តេជ្ញារបស់រាជរដ្ឋាភិបាលក្នុងការលើកជ្រោង សេរីភាពបញ្ចេញមតិ ត្រូវបានបដិសេធដោយអ្នកផ្តល់សម្ភាសន៍មួយចំនួន។

> ភាគច្រើន អ្វីដែលរាជរដ្ឋាភិបាលនិយាយអំពីការគោរពសិទ្ធិ គឺគ្រាន់តែជាការនិយាយឲ្យតែរួច ប៉ុណ្ណោះ។ គឺគ្មានការអនុវត្តទេ។
>
> អ្នកផ្តល់សម្ភាសន៍អនាមិក

*ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩* មានមាត្រាមួយចំនួនដែលប៉ះពាល់ដោយផ្ទាល់លើសង្គមស៊ីវិល និង សេរីភាពបញ្ចេញមតិ ឧទាហរណ៍ មាត្រា ៣០៥, ៣០៧, ៣១១, ៤៩៥, ៥០២ និង៥២៣។ ក្រមព្រហ្មទណ្ឌកំណត់ក្របខ័ណ្ឌគតិយុត្តិសម្រាប់បរិហារកេរ្តិ៍ ការផ្តល់ព័ត៌មានមិនពិតនិងការញុះញង់។ ការនិយាយបំផ្លើស ឬការមួលបង្កាច់ដែលធ្វើឲ្យខូចកិត្តិយស ឬកេរ្តិ៍ឈ្មោះរបស់បុគ្គល់ឬស្ថាប័នមួយ គឺជាការបរិហារកេរ្តិ៍។ ការបរិហារកេរ្តិ៍ត្រូវបានប្រព្រឹត្តដោយមធ្យោបាយណាមួយខាងក្រោមៈ

១. ដោយពាក្យសម្តី ទោះជាតាមមធ្យោបាយអ្វីក៏ដោយ ដែលត្រូវបានប្រកាសនៅទីកន្លែងសាធារណៈមួយ ឬនៅក្នុងកិច្ចប្រជុំសាធារណៈមួយ។
២. ជាលាយលក្ខណ៍អក្សរ ឬគំនូស ទោះបីជាដោយមធ្យោបាយអ្វីក៏ដោយ ដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈ ឬ ដែលត្រូវបានបើកបង្ហាញជូនសាធារណជន។
៣. ដោយមធ្យោបាយផ្សព្វផ្សាយសោតទស្សន៍ណាមួយដែលសំដៅលើសាធារណជន[29]។

ការបរិហារកេរ្តិ៍ អាចដាក់ទោសបានដោយការផាកពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) ដល់ ១០.០០០.០០០ (ដប់លាន) រៀល។ គិតជាប្រាក់ដុល្លារអាមេរិក ការផាកពិន័យសម្រាប់ការបរិហារកេរ្តិ៍មានចំនួនពី ២៥ ដុល្លារ ដល់ ២.៥០០ ដុល្លារ។

មាត្រា ៥០២ នៃក្រមព្រហ្មទណ្ឌចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌនូវការជេរប្រមាថចំពោះមន្ត្រីសាធារណៈមួយរូបដែលធ្វើសកម្មភាពតាងនាមឲ្យស្ថាប័នរបស់ខ្លួន ហើយមាត្រា ៥២៣ ចាត់ទុកថាខុសច្បាប់ ការបង្ខូចកិត្យានុភាពនៃសេចក្តីសម្រេចតុលាការ *(សូមមើលកម្រងរបាយការណ៍ដែលត្រូវបានដាក់ដោយអង្គការសង្គមស៊ីវិល ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ នៅក្នុងសម័យប្រជុំលើកទី ១៨ នៃការពិនិត្យទៀងទាត់ ជាសកលលើព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៣)*។ យោងតាមរបាយការណ៍ទាំងនេះ មាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ – ការញុះញង់ឲ្យប្រព្រឹត្តបទល្មើសមួយ – ត្រូវបានប្រើយ៉ាងទៀងទាត់ប្រឆាំងនឹង "អ្នកការពារសិទ្ធិមនុស្ស បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងបុគ្គល/ក្រុមផ្សេងទៀតដែលហ៊ាននិយាយប្រឆាំងអាជ្ញាធរ ឬដែលព្យាយាមអប់រំសាធារណជនកម្ពុជាអំពីសិទ្ធិមនុស្ស។ លោក អ៊ូ វីរៈ ប្រធានអង្គការ CCHR ត្រូវបានកោះហៅដើម្បីសួរចម្លើយដោយតុលាការខេត្តរតនគិរី ក្នុងខែតុលា ឆ្នាំ២០១២" ចោទប្រកាន់អំពីការញុះញង់សមាជិកក្រុមជនជាតិដើមភាគតិច ឲ្យតវ៉ាដោយប្រើអំពើហិង្សាចំពោះការដេញចេញពីដីធ្លី (ទំព័រ១២)។

---

[29] http://sogi.sithi.org/admin/upload/media/125-rlhnfhw1371009220.pdf, accessed 19 November 2013

ឥរិយាបថដែលត្រូវបានចាត់ទុកថាជាការបរិហារកេរ្តិ៍ ឬជេរប្រមាថ ដែលត្រូវបានផ្សាយតាមបណ្តាញព័ត៌មាន ត្រូវបានចាត់ចែងក្រោម*ច្បាប់សារព័ត៌មានឆ្នាំ១៩៩៥*។ ប៉ុន្តែ ច្បាប់ដែលធ្វើនិយ័តកម្មបណ្តាញព័ត៌មានមិនត្រូវបានសេរសេរឲ្យបានច្បាស់ ហើយជួនកាលត្រូវបានអនុវត្តមិនស៊ីគ្នា។ កន្លងមក បុគ្គលិកសារព័ត៌មានខ្លះ ត្រូវបានកាត់ទោសស្របតាមបទប្បញ្ញត្តិនៃ*ច្បាប់សារព័ត៌មាន* ដែលហាមឃាត់ការរាយការណ៍ណាដែលត្រូវបានចាត់ទុកថាគម្រោមកំហែងដល់ស្ថេរភាពនយោបាយ[30]។

សារព័ត៌មានកម្ពុជាស្ទើរតែទាំងអស់ សម្របតាមគណបក្សនយោបាយមួយ។ ទូរទស្សន៍គឺជាកម្មសិទ្ធិ ឬត្រូវបានគ្រប់គ្រងទាំងស្រុងដោយអ្នកដែលជិតស្និទ្ធជាមួយ គណបក្សនយោបាយធំកាន់អំណាច។ វិទ្យុមានស្ថានីយ៍មួយចំនួនតូចសម្របតាមគណបក្សប្រឆាំង និង សម្លេងឯករាជ្យសំខាន់ៗ ហើយកាសែតស្ទើរតែទាំងអស់ លើកលែងតែសារព័ត៌មានជាភាសាបរទេស ត្រូវបានគ្រប់គ្រងដោយគណបក្សនយោបាយ ឬ បុគ្គលអ្នកនយោបាយ[31]។

សារព័ត៌មានឯករាជ្យមួយចំនួន ត្រូវបានពិនិត្យពិច័យយ៉ាងដិតដល់ ហើយការបញ្ចេញមតិរបស់ពួកគេ ជួនកាល ត្រូវបានរឹតត្បិតឬគ្រប់គ្រងដោយរាជរដ្ឋាភិបាល។ ឧទាហរណ៍ រាជរដ្ឋាភិបាលបានសម្រេចលុបចោលការផ្សាយកម្មវិធី "សមធម៌ប្រចាំសប្តាហ៍" ក្នុងខែវិច្ឆិកា ឆ្នាំ២០១២។ កម្មវិធីនេះមានប្រភពដើមចេញពីការជួយគាំទ្រពីកម្មវធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) និងអង្គការផ្សេងទៀតក្នុងឆ្នាំ ២០០៣ ជាមធ្យោបាយពេលរាត្រីមួយសម្រាប់ការផ្សាយប្រកបដោយយុត្តិធម៌ និងគ្រប់ជ្រុងជ្រោយអំពីយុទ្ធនាការឃោសនាបោះឆ្នោតជាតិ។ កម្មវិធីនេះមានប្រជាប្រិយភាពខ្លាំងរហូតដល់ធ្វើឲ្យក្រសួងព័ត៌មានឯកភាពបន្តវាជាកម្មវិធីប្រចាំសប្តាហ៍។ សេចក្តីសម្រេចបញ្ឈប់ការផ្សាយកម្មវិធីនេះភ្លាមៗ បានកើតឡើងមុនពេលបោះឆ្នោតនាខែ កក្កដា ឆ្នាំ២០១៣។

សមត្ថភាពសម្រាប់ការរាយការណ៍ពេញលេញ ប្រកបដោយសមធម៌ និងតម្លាភាពដោយសារព័ត៌មានភាសាខ្មែរ អំពីសកម្មភាពរបស់អង្គការសង្គមស៊ីវិល ជាទូទៅ ត្រូវបានចាត់ទុកថាខ្សោយ។ អ្នកធ្វើការក្នុងសង្គមស៊ីវិលជាច្រើនមិនមានជំនឿលើបណ្តាញសារព័ត៌មានទាំងនេះ និងមិនចាត់ទុកថាជាច្រកសមស្របសម្រាប់កិច្ចប្រឹងប្រែងតស៊ូមតិទេ។ បណ្តាញសារព័ត៌មានជាច្រើន មានលក្ខណៈលំអៀង អំពីព័ត៌មានដែលពួកគេផ្តល់ ទៅរកការផ្សាយរបស់រាជរដ្ឋាភិបាល។ ដោយធ្វើដូច្នេះ ពួកគេបង្ហាញថាពួកគេមិនទទួលស្គាល់ វាយតម្លៃខ្ពស់ ឬទទួលយកអ្វីដែលអង្គការសង្គមស៊ីវិលចង់និយាយ។ ពាក់ព័ន្ធសមត្ថភាព អ្នកកាសែតជាច្រើន មិនបានទទួលការបណ្តុះបណ្តាលគ្រប់គ្រាន់លើវិជ្ជាជីវៈ និងសីលធម៌ទាក់ទិននឹងការងាររបស់ពួកគេឡើយ។ តាមពិត អ្នកកាសែតខ្លះត្រូវបានគេរាយការណ៍ថាបានទារប្រាក់ក្រៅផ្លូវការពីបុគ្គលសាធារណៈ រួមទាំងបុគ្គលិកអង្គការសង្គមស៊ីវិល ជាថ្នូរសម្រាប់ការយកព័ត៌មាន។ មជ្ឈមណ្ឌលសីលធម៌វិជ្ជាជីវៈកាសែតកម្ពុជា បច្ចុប្បន្ន កំពុងធ្វើការជាមួយអង្គការសេវាសារព័ត៌មានអប់រំសុខភាពកម្ពុជាលើគម្រោងមួយ ដើម្បីលើកទឹកចិត្តដល់ការប្រកាន់យកក្រមសីលធម៌វិជ្ជាជីវៈកាសែត។

---

[30] http://www.freedomhouse.org/report/freedom-press/2013/cambodia, accessed 19 November 2013
[31] http://licadho-cambodia.org/reports/files/119LICADHOMediaReport2008.pdf, accessed 21 November 2013

ជាទូទៅ អ្នកផ្តល់សម្ភាសន៍មានការយល់ដឹងស្រដៀងគ្នាអំពីអ្វីដែលអាចនិយាយ និងអ្វីដែលមិនអាចនិយាយក្នុងការអនុវត្តជាក់ស្តែង។ អ្នកផ្តល់សម្ភាសន៍ បានបង្ហាញថា ជាទូទៅមានការយោគយល់ល្អចំពោះការទិតៀនរបស់ពួកគេចំពោះគោលនយោបាយរាជរដ្ឋាភិបាល លុះត្រាណាតែការទិតៀននោះត្រូវបានផ្តោតជាបុគ្គលផ្ទាល់លើមន្ត្រីជាន់ខ្ពស់ដោយចេញឈ្មោះ។

> (ពួកគេ) ទំនងជាយោគយល់ ប្រសិនបើការទិតៀនរបស់យើងមានលក្ខណៈទូទៅ។ យើងអាចជួបការតវ៉ាប្រសិនបើពាក្យសម្តីរបស់យើងប៉ះពាល់មន្ត្រីសាធារណៈ។
>
> អង្គការសង្គមស៊ីវិល ដែលទិតៀនរាជរដ្ឋាភិបាលយ៉ាងសកម្ម ពួកគេទទួលលិខិតព្រមាន ប៉ុន្តែរាជរដ្ឋាភិបាលកម្រធ្វើសកម្មភាពប្រឆាំងនឹងពួកគេណាស់។ ជារួម អង្គការសង្គមស៊ីវិលមានសិទ្ធិនិយាយ។ មានតែរាជរដ្ឋាភិបាលទេដែលមានការត្រួតត្រាលើបណ្តាញព័ត៌មាន។
>
> អ្នកផ្តល់សម្ភាសន៍អនាមិក

បទពិសោធន៍នៃការយោគយល់នេះ ហាក់បីដូចជាមិនស្របគ្នាជាមួយការវិភាគរបស់អង្គការសង្គមស៊ីវិលអំពីបរិស្ថានគតិយុត្តិ និងបទបញ្ញត្តិ ដែលគូសបង្ហាញការលំបាករបស់រាជរដ្ឋាភិបាលក្នុងការអនុវត្ត និងប្រតិបត្តិច្បាប់ប្រកបដោយប្រសិទ្ធភាព។ ករណីលោក ម៉ម សូណង់ដូ សកម្មជនសិទ្ធិមនុស្ស និងម្ចាស់វិទ្យុសំបុកឃ្មុំ បង្ហាញពន្លឺខុសគ្នាខ្លះអំពីប្រការដែលថា តើសេរីភាពបញ្ចេញមតិអាចមានលក្ខណៈដូចម្តេចនៅកម្ពុជា:

> លោក ម៉ម សូណង់ដូ គឺជាម្ចាស់វិទ្យុសំបុកឃ្មុំ ដែលជាបណ្តាញសារព័ត៌មានមួយនៃបណ្តាញសារព័ត៌មានឯករាជ្យកម្ពុជា ក្នុងការផ្សាយបទអត្ថាធិប្បាយមានលក្ខណៈទិតៀនរាជរដ្ឋាភិបាលកម្ពុជា។ ស្ថានីយ៍វិទ្យុ របស់លោក សូណង់ដូ បានរាយការណ៍ពីការបំពានសិទ្ធិមនុស្សទាក់ទិននឹងការតវ៉ានាពេលថ្មីៗនៅខេត្តក្រចេះ ដែលរាជរដ្ឋាភិបាលបានចាត់ទុកថាជាការបះបោរ។ យោងតាមការរាយការណ៍សារព័ត៌មានការតវ៉ាបានបណ្តាលឲ្យកុមារីអាយុ ១៤ ឆ្នាំម្នាក់ត្រូវគេបាញ់ស្លាប់ នៅពេលអ្នកស្រុកមូលដ្ឋានប្រឆាំងនឹងកិច្ចប្រតិបត្តិការយោធាមួយ ដើម្បីបោសសម្អាតដីឲ្យក្រុមហ៊ុនឯកជនរុស្ស៊ីមួយ។ អាជ្ញាធរបានឃាត់ខ្លួនលោក សូណង់ដូ ក្នុងខែកក្កដា ហើយនៅថ្ងៃទី១ ខែតុលា តុលាការកម្ពុជាមួយបានរកឃើញថាលោកមានកំហុសពីបទ "បះបោរ" ប្រឆាំងនឹងរដ្ឋ ស្របតាម *ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩* និង បានកាត់ទោសលោកឲ្យជាប់ពន្ធនាគាររយៈពេល ២០ ឆ្នាំ[32]។ ក្រោយពេលមានការប្រឆាំងអន្តរជាតិនិងសាធារណៈ លោក ម៉ម សូណង់ដូ ត្រូវបានដោះលែងពីពន្ធនាគារព្រៃស នៃរាជធានីភ្នំពេញ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៣ ក្រោយពេលជាប់ពន្ធនាគាររយៈពេលប្រាំបីខែនៃការផ្តន្ទាទោសរយៈពេល ២០ឆ្នាំ ដោយការផ្តន្ទាទោសនៅសល់ត្រូវបានព្យួរ។"[33]

[32] http://globalfree.wordpress.com/2012/10/01/cambodian-court-sentences-journalist-to-20-years/ accessed 19 November 2013
[33] http://livewire.amnesty.org/2013/04/12/freed-cambodian-human-rights-defender-speaks-out/ accessed 20 November 2013

ខណៈដែលបណ្តាញសារព័ត៌មាននៅកម្ពុជាគឺជារបស់រដ្ឋ ឬគ្រប់គ្រងដោយរដ្ឋ អ៊ីនធឺណេតបច្ចុប្បន្ន ត្រូវបានធ្វើនិយ័តកម្មតិចតួច។ ក្នុងយុទ្ធនាការបោះឆ្នោតនាពេលថ្មីៗនេះ ប្រជាជនជាច្រើននៅកម្ពុជា និងជាពិសេស យុវជន បានងាកទៅរកបណ្តាញទំនាក់ទំនងសង្គមជាប្រភពចម្បងនៃដំណឹង និងព័ត៌មានទាន់ហេតុការណ៍អំពីស្ថានភាពបច្ចុប្បន្ន និងជាយន្តការមួយសម្រាប់តាមដានការរាប់សន្លឹកឆ្នោត ក្នុងចំណោមការប្រើប្រាស់ផ្សេងទៀត។ ព័ត៌មាននៅលើហ្វេសប៊ុក (Facebook) ត្រូវបានគេចាត់ទុកថាអាចជឿទុកចិត្តបាន ជាងព័ត៌មានក្នុងទម្រង់ផ្សេងទៀតនៃបណ្តាញសារពត៌មាន (គ្រប់គ្រងដោយរដ្ឋ)។ អ្នកផ្តល់សម្ភាសន៍អនាមិក បាននិយាយថាអ៊ីនធឺណេត និងជាក់ស្តែង ហ្វេសប៊ុក (Facebook) បានផ្តល់ជូនប្រជាពលរដ្ឋនូវឱកាសដើម្បីផ្សារភ្ជាប់/ចងក្រង និងពិភាក្សាបញ្ហានយោបាយ ប្រការនេះ អាចត្រូវបានយល់ឃើញដោយ រាជរដ្ឋាភិបាលថា ជាបញ្ហាប្រឈម ចំពោះអំណាច ឬការត្រួតត្រារបស់ខ្លួន។ ការប្រើបណ្តាញទំនាក់ទំនងសង្គម ដោយយុវជន (Facebook, Twitter) ភាគច្រើនបានដំណើរការដោយមិនមាននិយ័តកម្មពីរាជរដ្ឋាភិបាល និងផ្តល់មធ្យោបាយដ៏សំខាន់មួយសម្រាប់ឲ្យក្រុមប្រជាជនមួយចំនួន ជាពិសេស យុវជន គេចវេសការត្រួតពិនិត្យរបស់រាជរដ្ឋាភិបាល។ អង្គការមិនមែនរដ្ឋាភិបាលជាច្រើន ក៏ប្រើបណ្តាញទំនាក់ទំនងសង្គមផងដែរ ជាមធ្យោបាយមួយនៃការបញ្ចេញមតិ និង ការចែករំលែកព័ត៌មាន។

កាលពីខែឧសភា ឆ្នាំ២០១២ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសថាខ្លួនកំពុងតាក់តែងព្រាងច្បាប់គ្រប់គ្រងប្រព័ន្ធអ៊ីនធឺណេតទីមួយ ដើម្បីធ្វើនិយ័តកម្ម និងដើម្បីរឹតត្បិតការប្រើអ៊ីនធឺណេត។ មូលហេតុមួយនៃមូលហេតុនានានៃការអនុម័តច្បាប់គ្រប់គ្រងប្រព័ន្ធអ៊ីនធឺណេតបែបនេះ គឺសំដៅទប់ស្កាត់ "មនុស្សមានគំនិតអាក្រក់ ... កុំឲ្យផ្សព្វផ្សាយព័ត៌មានមិនពិត"។ ច្បាប់នេះស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការតាក់តែង និងនៅមិនទាន់ផ្សព្វផ្សាយជូនសាធារណជននៅឡើយ ប៉ុន្តែ មានការភ័យខ្លាចថាច្បាប់នេះអាចរារាំងសេរីភាពបញ្ចេញមតិតាមអ៊ីនធឺណេតនៅកម្ពុជា។ ច្បាប់ស្តីពីឧក្រិដ្ឋកម្មកុំព្យូទ័រនៃប្រទេសថៃ ដែលត្រូវបានអនុម័តក្នុងឆ្នាំ២០០៧ ផ្តល់ឧទាហរណ៍សមហេតុ ផលមួយអំពីប្រការដែលថាការអនុវត្តច្បាប់គ្រប់គ្រងប្រព័ន្ធអ៊ីនធឺណេត ស្រដៀងគ្នាមួយនៅកម្ពុជា ជំនួសឲ្យការការពារផលប្រយោជន៍ របស់ប្រជាជនកម្ពុជា អាចមានផលប៉ះពាល់ដែលធ្វើឲ្យខូចប្រយោជន៍លើសេរីភាពផ្នែកនយោបាយ សេរីភាពបញ្ចេញមតិ និង "សិទ្ធិដឹងឮ"[34]។

កង្វល់ក៏ត្រូវបានលើកឡើងផងដែរដោយអ្នកផ្តល់សម្ភាសន៍ ទាក់ទិននឹងសេចក្តីព្រាងច្បាប់បច្ចុប្បន្នស្តីពីអង្គការមិនមែនរដ្ឋាភិបាលនិងសមាគម និងលទ្ធភាព ដែលច្បាប់នេះអាចមានផលប៉ះពាល់អវិជ្ជមានលើលទ្ធភាពរបស់អង្គការសង្គមស៊ីវិល ក្នុងការអនុវត្តសិទ្ធិបញ្ចេញមតិដោយសេរីរបស់ខ្លួន។ ដោយឡែក ការកំណត់នៃសេចក្តីព្រាងច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាលនិងសមាគមឲ្យអង្គការសង្គមស៊ីវិល "ជៀសវាងធ្វើសកម្មភាពគាំទ្រគណបក្សនយោបាយ" អាចដាក់សកម្មភាពនយោបាយក្រោមការរឹតត្បិតកាន់តែទូលាយក្រោមច្បាប់ថ្មីនេះ។

[34] http://www.ifex.org/cambodia/2013/04/30/cambodia_internet_censorship_cchr.pdf accessed 17 November 2013

អវត្តមាននៃច្បាប់មួយដែលជំរុញលទ្ធភាពទទួលព័ត៌មាន ត្រូវបានចាត់ទុកដោយអ្នកផ្តល់សម្ភាសន៍មួយចំនួនថាជាឧបសគ្គចំពោះប្រសិទ្ធភាពនៃសង្គមស៊ីវិលនៅកម្ពុជា:

> រាជរដ្ឋាភិបាលកម្ពុជា បានខកខានមិនបានអនុម័តច្បាប់មួយស្តីពីសេរីភាពទទួលព័ត៌មាន (FoI) ដើម្បីអនុវត្តសិទ្ធិទទួលព័ត៌មានផ្អែកលើរដ្ឋធម្មនុញ្ញ ទោះបីជាមានការប្តេជ្ញាតាំងពី ឆ្នាំ២០០៧ ក្តី។ ប្រការនេះ កើតឡើងទោះបីជាគណបក្សនយោបាយប្រឆាំងបានដាក់សេចក្តីព្រាងច្បាប់ស្តីពីសេរីភាពទទួលព័ត៌មានជូនរដ្ឋសភាក្នុងឆ្នាំ២០១០, ២០១២ និង២០១៣ ក៏ដោយ។ សេចក្តីព្រាងចុងក្រោយត្រូវបានបដិសេធ ដោយគណបក្សកាន់អំណាច ដោយឈរលើមូលដ្ឋានថាវាមិនស្របតាមរដ្ឋធម្មនុញ្ញ ទោះជាអ្នកឯកទេសអន្តរជាតិបានរកឃើញថាវាមានចំណុចសំខាន់ៗជាច្រើន នៃច្បាប់ស្តីពីសេរីភាពទទួលព័ត៌មានក្តី *(កម្រងរបាយការណ៍ដាក់ដោយអង្គការសង្គមស៊ីវិល ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ក្នុងអំឡុងពេលប្រជុំលើកទី១៨ នៃការពិនិត្យមើលជាសកលទៀងទាត់លើព្រះរាជាណាចក្រកម្ពុជា* ឆ្នាំ២០១៣ ទំព័រ១៣)។

ជាសង្ខេប ឧបសគ្គចំពោះសេរីភាពបញ្ចេញមតិនៅកម្ពុជាគឺមានលក្ខណៈគួរឲ្យកត់សម្គាល់ និងគឺជាការបារម្ភដ៏ធ្ងន់ធ្ងរមួយនៃតួអង្គសង្គមស៊ីវិល និងអ្នកសង្កេតការផ្សេងទៀត។ អង្គការសង្គមស៊ីវិលហាក់បីដូចជាពូកែធ្វើដំណើរឆ្លងកាត់ទីដ៏លំបាកនេះ។

## វិធីសាស្ត្រ

ព័ត៌មានដែលបានពន្យល់នៅទីនេះ ត្រូវបានដកស្រង់ពីការសិក្សាឯកសារ ជាពិសេស ក្រមព្រហ្មទណ្ឌ ការវិភាគដែលបានបោះពុម្ពផ្សាយ និងពីការសម្ភាសន៍ផ្លូវការជាមួយតួអង្គសង្គមស៊ីវិលចំនួនប្រាំ។ អ្នកផ្តល់សម្ភាសន៍ រួមមានមន្ត្រីសហជីពពីររូប តំណាងម្នាក់ពីអង្គការព័ត៌មានមិនរកចំណេញមួយ និងតំណាងម្នាក់មកពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមួយ។ សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ត្រូវបានចូលរួមដោយអ្នកយកព័ត៌មានមួយចំនួនដែលបានផ្តល់ព័ត៌មាននិងមតិបន្ថែមដ៏មានតម្លៃ។ ព័ត៌មានដែលមានត្រូវបានសម្រិតសម្រាំងនិងផ្ទៀងផ្ទាត់ ដែលបានមកពីការសន្ទនាក្រៅផ្លូវការជាមួយតួអង្គសង្គមស៊ីវិល។ ដើម្បីព័ត៌មានបច្ចុប្បន្នភាពបន្ថែមអំពីសេរីភាពបញ្ចេញមតិនៅកម្ពុជា សូមមើល http://www.cchrcambodia.org/admin/media/report/report/english/2013_09_19_CCHR_FoEx_Report_Repression_of_Expression_The_State_of_Free_Speech%20in_Cambodia_EN.pdf។

## សេចក្ដីសង្ខេបអំពីបញ្ហាប្រឈមសំខាន់ៗ

បញ្ហាប្រឈមសំខាន់ៗទាក់ទិននឹងការបញ្ចេញមតិនៅកម្ពុជា រួមមាន៖

- បទប្បញ្ញត្តិមានការរឹតត្បិតខ្លាំងនៅក្នុងក្រមព្រហ្មទណ្ឌទាក់ទិននឹងការបរិហារកេរ្តិ៍ ការផ្ដល់ព័ត៌មានមិនពិត និងការញុះញង់
- កង្វះឯករាជ្យភាពនៃបណ្ដាញព័ត៌មានក្នុងស្រុកស្ទើរតែទាំងអស់ ជាពិសេស ទូរទស្សន៍ និងកាសែតភាសាខ្មែរ
- ការជ្រៀតជ្រែកដោយក្រសួងព័ត៌មានក្នុងការផ្សាយកម្មវិធីសារព័ត៌មានដែលជំរុញសិទ្ធិមនុស្ស
- ការប្រើច្បាប់មិនសមស្របដោយសមាជិកមួយចំនួននៃស្ថាប័ននីតិប្រតិបត្តិ និងស្ថាប័នតុលាការនៃរាជរដ្ឋាភិបាល ដើម្បីរឹតត្បិតយ៉ាងធ្ងន់ធ្ងរលើបុគ្គលទាំងឡាយ ដែលសម្ដែងមតិផ្ទុយនឹងរាជរដ្ឋាភិបាល ដែលបង្កើតបរិយាកាសត្រួតពិនិត្យខ្លួនឯង
- កង្វះសមត្ថភាព និង វិជ្ជាជីវៈក្នុងចំណោមអ្នកយកព័ត៌មាន
- អវត្តមាននៃការរាយការណ៍មិនលំអៀង ប្រកបដោយសមធម៌ អំពីសង្គមស៊ីវិលនៅក្នុងបណ្ដាញសារព័ត៌មានក្នុងស្រុក
- យន្តការច្បាប់មិនគ្រប់គ្រាន់ដើម្បីការពារអ្នកកាសែត និងប្រភពព័ត៌មានរបស់ពួកគេ
- សក្ដានុពលដែលច្បាប់ថ្មីស្ដីពីអង្គការមិនមែនរដ្ឋាភិបាលនិងសមាគម រឹតត្បិតសេរីភាពនៃការបញ្ចេញមតិ
- ការអនុម័តសេចក្ដីព្រាងច្បាប់ថ្មីស្ដីពី ការគ្រប់គ្រងប្រព័ន្ធអ៊ីនធឺណេតអាចរឹតត្បិតសេរីភាពនៃការបញ្ចេញមតិ/យោបល់។

# ផ្នែកទី ៧: ការជួបប្រជុំដោយសន្តិវិធី

## ទស្សនៈរួម

មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ចែងថាប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការជួបប្រជុំ។ ច្បាប់*ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ឆ្នាំ២០០៩* កំណត់នីត្យានុកូលភាពនៃការធ្វើបាតុកម្មដោយសន្តិវិធី និងបញ្ជាក់កិច្ចតម្រូវឲ្យជូនដំណឹងសម្រាប់ការធ្វើបាតុកម្ម។ បុគ្គល ឬអង្គការសង្គមស៊ីវិលដែលគ្រោងធ្វើបាតុកម្ម/ការតវ៉ាមួយ ត្រូវបានតម្រូវឲ្យសុំ ការអនុញ្ញាត ឬជូនដំណឹងដល់រាជរដ្ឋាភិបាល ប្រាំថ្ងៃមុនពេលធ្វើបាតុកម្ម/ការតវ៉ា។ ក្នុងករណីខ្លះ សមាជិកខ្លះនៃកងកម្លាំងសន្តិសុខ មន្ត្រីទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត និង/ឬ មន្ត្រី បានធ្វើសកម្មភាពដើម្បីរឹតត្បិតសេរីភាពនៃការធ្វើចលនា និង សេរីភាពខាងការជួបប្រជុំរបស់ពលរដ្ឋកម្ពុជា។ ឧទាហរណ៍នៃចំណុចនេះ រួមមានការបដិសេធមិនផ្តល់ការអនុញ្ញាតសម្រាប់ការតវ៉ាដោយសន្តិវិធី ការតម្រូវឲ្យសមាជិកសហគមន៍មានការអនុញ្ញាតដើម្បីធ្វើដំណើរ សូម្បីតែពីភូមិមួយទៅភូមិមួយ ការតាមដានការជួបប្រជុំដោយនគរបាល និងអាជ្ញាធររដ្ឋ ការថតរូបអ្នកចូលរួមប្រជុំ និងការសួរឈ្មោះនិងព័ត៌មានទំនាក់ទំនងរបស់អ្នកចូលរួមកិច្ចប្រជុំ ការជ្រៀតជ្រែកដោយនគរបាលក្នុងការជួបប្រជុំ និងការប្រើសម្ពាធ ឬការបង្ខិតបង្ខំ លើសហគមន៍ដែលចូលរួមជាមួយអង្គការមិនមែនរដ្ឋាភិបាល[35]។

## របកគំហើញ

មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ចែងថាប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការជួបប្រជុំ។ ពលរដ្ឋខ្មែរអាចចូលរួមផងដែរក្នុងអង្គការមហាជនដើម្បីអត្ថប្រយោជន៍ទៅវិញទៅមក ដើម្បីការពារសមិទ្ធផលជាតិ និង សណ្តាប់ធ្នាប់សង្គម[36]។ រដ្ឋធម្មនុញ្ញបញ្ជាក់ថានឹងមិនមានអ្នកណាម្នាក់អាចអនុវត្តសិទ្ធិនេះ ដើម្បីរំលោភបំពានលើសិទ្ធិរបស់អ្នកដទៃ ដើម្បីប៉ះពាល់លើប្រពៃណីល្អរបស់សង្គម ដើម្បីរំលោភច្បាប់និងសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខជាតិ។ ដោយគាំទ្រចំណុចនេះ ប្រទេសកម្ពុជាគឺជាហត្ថលេខីនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិទាំងនេះ។

[35] http://www.icnl.org/research/monitor/cambodia.html, accessed 28 February 2013
[36] http://www.constitution.org/cons/cambodia.htm, accessed 27 February 2013

*ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ឆ្នាំ២០០៩* កំណត់នីត្យានុកូលភាពនៃការធ្វើបាតុកម្មដោយសន្តិវិធី និង បញ្ជាក់កិច្ចតម្រូវឲ្យជូនដំណឹងសម្រាប់ការធ្វើបាតុកម្ម។ ស្របតាមមាត្រា ៤ នៃច្បាប់នេះ ការធ្វើបាតុកម្មដោយសន្តិវិធី គប្បីមានចរិតលក្ខណៈដូចខាងក្រោម:

១. ការជួបជុំគ្នាឬការដើរដោយសន្តិវិធី ដែលត្រូវបានធ្វើដោយមនុស្សមួយក្រុម
២. ទាមទារជាសាធារណៈ តវ៉ា ឬ សម្តែងសញ្ចេតនា យោបល់ ឬ ឆន្ទៈរបស់ខ្លួន
៣. ដោយប្រើទម្រង់ឬមធ្យោបាយផ្សេងៗដោយសន្តិវិធី។[37]

បទប្បញ្ញត្តិក្រោមច្បាប់នេះ ក៏តម្រូវផងដែរថាក្រុមបុគ្គលណាដែលមានបំណងរៀបចំការជួបប្រជុំដោយសន្តិវិធីនៅកន្លែងសាធារណៈណាមួយ ត្រូវតែជូនដំណឹងជាលាយល័ក្ខអក្សរជូនអាជ្ញាធរមូលដ្ឋាន យ៉ាងហោចណាស់ប្រាំថ្ងៃមុន[38]។ ក្នុងការអនុវត្តជាក់ស្តែង 'ការជូនដំណឹង' នេះតាមពិតមានន័យថាអ្នករៀបចំត្រូវសុំការអនុញ្ញាតដើម្បីរៀបចំការប្រជុំមួយ។ ការអនុញ្ញាតឲ្យធ្វើបាតុកម្មដោយសន្តិវិធី មិនមែនសុទ្ធតែត្រូវបានផ្តល់ឲ្យទេ: 'មានករណីជាច្រើនដែលនៅក្នុងនោះ អាជ្ញាធរមូលដ្ឋានមិនអនុញ្ញាតឲ្យមានការជួបជុំគ្នា ឬការប្រមូលផ្តុំ'។ ការអនុញ្ញាតឲ្យធ្វើបាតុកម្មទំនងដូចជាត្រូវបានបដិសេធច្រើនជាង ប្រសិនបើបាតុកម្មត្រូវបានចាត់ទុកថាមានលក្ខណៈរសើបខាងនយោបាយ: យោងតាមសេចក្តីព្រាងច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាលនិងសមាគម អង្គការសង្គមស៊ីវិលត្រូវបានរំពឹងថាជៀសវាងសកម្មភាពជាកិច្ចគាំទ្រគណបក្សនយោបាយ ហើយលក្ខខ័ណ្ឌនេះអាចត្រូវបានបកស្រាយយ៉ាងអត្តនោម័តដោយបុគ្គលមួយចំនួនក្នុងរាជរដ្ឋាភិបាល។

អ្នកផ្តល់សម្ភាសន៍ បានលើកឡើងថាពួកគេជឿថាមូលហេតុដែលត្រូវបានផ្តល់ដោយមន្ត្រីសាធារណៈ សម្រាប់បដិសេធការអនុញ្ញាតឲ្យធ្វើបាតុកម្ម គឺមានលក្ខណៈមិនស្មោះត្រង់:

> ច្បាប់ក៏ចែងយ៉ាងច្បាស់ផងដែរថាក្នុងករណីដែលបាតុកម្មអាចបណ្តាលឲ្យមានគ្រោះថ្នាក់ ធ្វើឲ្យខូចខាតដល់សន្តិសុខជាតិ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ពួកគេនឹងមិនយល់ស្របទេ។ ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែង ពួកគេបដិសេធការជូនដំណឹងរបស់យើងដោយឆ្លើយថាបាតុកម្មនេះអាចធ្វើឲ្យមានបញ្ហាកកស្ទះចរាចរណ៍។
>
> អ្នកផ្តល់សម្ភាសន៍អនាមិក

ថ្វីបើមានការទទួលយកជាទូទៅក្នុងច្បាប់អន្តរជាតិថា រដ្ឋាភិបាល អាចដាក់ការរឹតត្បិតលើការតវ៉ាដើម្បីកង្វល់សង្គមស្របច្បាប់ ដែលនៅក្នុងនោះ ការកកស្ទះចរាចរណ៍គឺជាកង្វល់មួយក្តីកង្វល់ក្នុងចំណោមបុគ្គលិកសង្គមស៊ីវិលដែលបានសម្ភាសន៍ គឺថាមូលហេតុស្របច្បាប់ទាំងនេះកំពុងត្រូវ

---

[37] http://cambodia.ohchr.org/WebDOCs/DocProgrammes/Law_on_peaceful_demonstration-promulgated_Eng.pdf, accessed 19 November 2013; see also http://cambodia.ohchr.org/EN/PagesFiles/The_right_peaceful_assembly.htm, accessed 17 November 2013
[38] http://www.sithi.org/temp.php?url=publication_detail.php&mid=4769, accessed 17 November 2013

បានប្រើដើម្បីបិទបាំងគំនិតមិនស្របច្បាប់ ពោលគឺចំណង់របស់មន្ត្រីសាធារណៈមួយចំនួនចង់រឹតត្បិតសេរីភាពខាងការជួបប្រជុំរបស់ពួកគេ។ ការបដិសេធខ្លះ ហាក់បីដូចជាមានលក្ខណៈដាច់ណាត់ ដោយគ្មានផ្តល់ការពន្យល់ឬយុត្តិកម្មអ្វីឡើយៈ

> នៅភូមិភាគឦសាន មានការបញ្ជាក់ជាលាយលក្ខណ៍អក្សរថាប្រជាពលរដ្ឋមិនត្រូវបានអនុញ្ញាតឲ្យជួបជុំគ្នាដោយគ្មានការអនុញ្ញាតឡើយ ហើយពួកគេ មិនដែលទទួលបានការអនុញ្ញាតទេ។
>
> អ្នកផ្តល់បទសម្ភាសន៍អនាមិក

បញ្ហាប្រឈមមួយទៀតដែលត្រូវបានលើកឡើងដោយអ្នកផ្តល់បទសម្ភាសន៍ គឺថា*ច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី ឆ្នាំ២០០៩* តម្រូវឲ្យអ្នករៀបចំបាតុកម្មត្រូវកំណត់អត្តសញ្ញាណជាបុគ្គល។ លក្ខខ័ណ្ឌនេះគឺជាការលំបាកសម្រាប់បុគ្គលជាច្រើន ដែលបារម្ភថាការដែលត្រូវបានកំណត់អត្តសញ្ញាណ នឹងនាំឲ្យពួកគេក្លាយជាកម្មវត្ថុនៃការស៊ើបអង្កេតដោយមន្ត្រីរាជរដ្ឋាភិបាលមូលដ្ឋាន ឬរហូតដល់ទៅត្រូវបានឃាត់ខ្លួនដោយនគរបាលមូលដ្ឋាន។ អ្នកផ្តល់បទសម្ភាសន៍មួយរូប បានកត់សម្គាល់ថា ‛ប្រសិនបើបាតុកម្មមហាជនជួបនឹងបញ្ហា ពួកគេអាចចោទប្រកាន់យើង និង ឃាត់ខ្លួនពួកយើង’។

សូម្បីតែនៅពេលដែលបានទទួលការយល់ព្រមក្តី ក៏ព្រឹត្តិការណ៍ជាច្រើនត្រូវបានរំខានដោយនគរបាលមូលដ្ឋានដែលច្រើនតែបដិសេធទំហំក្រុមមនុស្ស ផ្លូវដើរ ឬទីកន្លែងធ្វើសកម្មភាព។ ជូនកាលអ្នកចូលរួមត្រូវបានឃាត់ខ្លួនពីបទញុះញង់ ឬរំខានសន្តិភាព សូម្បីតែការតវ៉ា តាមការមើលឃើញ គឺមានលក្ខណៈប្រកបដោយសន្តិវិធីក្តី[39]។

ទោះបីជាច្បាប់ហាក់បីដូចជាមានលក្ខណៈច្បាស់លាស់អំពីការបញ្ជាក់លក្ខខ័ណ្ឌនានា ដែលស្របតាមនោះ បាតុកម្មមួយអាចត្រូវបានរៀបចំក្តី ក៏ការបារម្ភដែលបានលើកឡើងដោយតួអង្គសង្គមស៊ីវិល និងអ្នកផ្តល់បទសម្ភាសន៍ គឺថាការជួបប្រជុំដោយសន្តិវិធីត្រូវបានរារាំងដោយនគរបាល និងអាជ្ញាធរមូលដ្ឋាន។ ម្យ៉ាងទៀត ពួកគេនិយាយថាការជួបប្រជុំដោយសន្តិវិធី ក្នុងករណីខ្លះ នាំឲ្យនគរបាលមូលដ្ឋាន យោធា ឬបុគ្គលមិនមែនមន្ត្រីស៊ីវិល ធ្វើសកម្មភាពតាំងនាមឲ្យរាជរដ្ឋាភិបាលដោយប្រើកម្លាំងដើម្បីសម្រេចបានគោលដៅរបស់ពួកគេ។ ឧទាហរណ៍ នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ សេចក្តីប្រកាសរួមជាសាធារណៈមួយ[40] ត្រូវបានចេញដោយអង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) ដែលត្រូវបានចុះហត្ថលេខាដោយអង្គការមិនមែនរដ្ឋាភិបាលប្រាំ ដែលសម្តែងកង្វល់របស់ខ្លួនចំពោះការប្រើកម្លាំងហួសហេតុដោយកងកម្លាំងសន្តិសុខកម្ពុជា ដើម្បីបំបែកការជួបជុំដោយសន្តិវិធីដែលដឹកនាំដោយមន្ត្រីគណបក្សសង្គ្រោះជាតិកម្ពុជា (CNRP) និង ដែលត្រូវ

[39] http://www.licadho-cambodia.org/reports.php?perm=149, accessed 17 November 2013
[40] http://www.hrw.org/news/2013/09/24/cambodia-joint-public-statement, accessed 17 November 2013

បានគាំទ្រដោយព្រះសង្ឃមួយក្រុមនៅវត្តភ្នំ។ សេចក្ដីប្រកាសរួមនៃអង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) អះអាងថាប្រការនេះមានឥទ្ធិពលរារាំងប្រជាពលរដ្ឋមិនឲ្យអនុវត្តសិទ្ធិមានសេរីភាពខាងការជួបប្រជុំដោយសន្តិវិធី និងការបញ្ចេញមតិ។ ព្រឹត្តិការណ៍មួយទៀតពីរថ្ងៃក្រោយនៃការអង្គុយដោយសន្តិវិធីដើម្បីគាំទ្រការដោះលែងលោកស្រី យ៉ោម បុប្ផា ដែលគឺជាសកម្មជនមួយរូបពីពន្ធនាគារ បាននាំឲ្យមានការបាញ់ចម្ពាម និងការប្រើអាវុធឆក់អគ្គិសនីដែលត្រូវបានចោទថាត្រូវបានធ្វើដោយកងកម្លាំងសន្តិសុខ។ អ្នកឃ្លាំមើលសិទ្ធិមនុស្ស ក៏ដូចជា តំណាងសារព័ត៌មាន ហាក់បីដូចជាចំណុចដៅនៅកំឡុងពេលឧប្បត្តិហេតុនោះ។

អ្នកផ្ដល់បទសម្ភាសន៍បាននិយាយអំពីករណីមួយចំនួននៃការប្រើកម្លាំងហួសហេតុ ដោយកងកម្លាំងសន្តិសុខមូលដ្ឋាន ក្នុងអំឡុងពេលដែលពួកគេព្យាយាមចូលរួមក្នុងការជួបប្រជុំដោយសន្តិវិធី និង សម្ដែងការទិតៀនរបស់ពួកគេប្រឆាំងនឹងសកម្មភាពមួយចំនួន របស់រាជរដ្ឋាភិបាល។ ក្នុងករណីបឹងកក់ ស្ត្រីវ័យក្មេងម្នាក់ឈ្មោះ យ៉ោម បុប្ផា ត្រូវបានឃាត់ខ្លួនក្នុងការការពារសិទ្ធិរបស់សហគមន៍លោកស្រីនៅអតីតបឹងកក់នៅរាជធានីភ្នំពេញ ដែលនៅទីនោះ ប្រជាជនរាប់ពាន់នាក់ត្រូវបានបណ្ដេញចេញពីគេហដ្ឋានប្រឆាំងនឹងឆន្ទៈពួកគេ ដោយសារដីនោះត្រូវបានជួលឲ្យក្រុមហ៊ុនមួយ ក្នុងឆ្នាំ ២០០៧។ អង្គការលើកលែងទោសអន្តរជាតិ (Amnesty International) បានធ្វើយុទ្ធនាការអន្តរជាតិមួយដើម្បីអំពាវនាវសុំឲ្យមានការដោះលែងលោកស្រី យ៉ោម បុប្ផា។ លោកស្រី យ៉ោម បុប្ផា ត្រូវបានដោះលែងនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៣ ដោយសេចក្ដីសម្រេចរបស់តុលាការកំពូល។

> លោកស្រី យ៉ោម បុប្ផា អាយុ ៣០ ឆ្នាំ គឺជាម្ដាយម្នាក់ ដែលបានការពារសិទ្ធិលំនៅឋានរបស់សហគមន៍លោកស្រី ត្រូវបានឃាត់ខ្លួននៅថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១២ និង ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគាររហូតដល់ ៣ឆ្នាំ គិតចាប់ពី ខែធ្នូ ឆ្នាំមុន ក្រោយការកាត់ទោសមួយដែលត្រូវបានចាត់ទុកដោយមតិជាច្រើនថាមិនមានយុត្តិធម៌។ អ៊ីសាបែល អារ៉ាដន (Isabelle Arradon) អនុប្រធានប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកនៃអង្គការលើកលែងទោសអន្តរជាតិ (Amnesty International) បានមានប្រសាសន៍ថា "លោកស្រី យ៉ោម បុប្ផា គឺជាអ្នកទោសមនសិការមួយរូប ដែលត្រូវបានដាក់ពន្ធនាគារដោយសារសកម្មភាពប្រកបដោយសន្តិវិធីរបស់លោកស្រី និង ការពារសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ របស់លោកស្រីដែលបានបាត់បង់លំនៅឋាន តាមរយៈការបណ្ដេញចេញដោយបង្ខំ" ។
>
> ករណីរបស់លោកស្រី និង ករណីនៃសហគមន៍របស់លោកស្រី តំណាងឲ្យបញ្ហាមួយចំនួនដែលបាននាំទៅដល់ការមិនពេញចិត្តកាន់តែច្រើនឡើងនៅកម្ពុជា – "ការអភិវឌ្ឍវិសមភាព វិវាទដីធ្លី និង ការបណ្ដេញចេញដោយបង្ខំ និង ប្រព័ន្ធយុត្តិធម៌មួយដែលបរាជ័យក្នុងការការពារសិទ្ធិរបស់ប្រជាពលរដ្ឋក្រីក្រ" និង ត្រូវបានប្រើជាញឹកញាប់ដើម្បីរឹតត្បិតសេរីភាពបញ្ចេញមតិ។[41]

[41] http://www.amnesty.org.au/news/comments/33372/, accessed 20 November 2013. See also http://www.amnesty.org/en/news/cambodia-jailed-activist-must-be-released-not-forgotten-2013-09-03, accessed 17 November 2013

ករណីនៃការប្រើកម្លាំងហួសហេតុដែលបានរៀបរាប់ខាងលើ ក៏មិនហាក់បីដូចជាត្រូវបានស៊ើបអង្កេតឲ្យបានមធ្យ័តឡើយ[42]។ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ បានទាញការយកចិត្តទុកដាក់លើកង្វះតម្លាភាពក្នុងកិច្ចដំណើរការស៊ើបអង្កេត លើសកម្មភាពនានានៃបុគ្គលនគរបាល ឬ អាជ្ញាធរមូលដ្ឋានផ្សេងទៀត ដែលត្រូវបានចោទប្រកាន់ពីការប្រើកម្លាំងហួសហេតុប្រឆាំងនឹងអ្នកចូលរួមការជួបប្រជុំដោយសន្តិវិធី *(កម្រងរបាយការណ៍ដែលត្រូវបានដាក់ដោយអង្គការសង្គមស៊ីវិល ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ក្នុងអំឡុងពេលប្រជុំលើកទី១៨ នៃការពិនិត្យមើលជាសកលទៀងទាត់លើព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៣)*។ បាតុកម្មនានាដែលផ្សារភ្ជាប់ទៅនឹងការបោះឆ្នោតជាតិនៅកម្ពុជាត្រូវបានចងក្រងជាឯកសារបានយ៉ាងល្អនៅលើគេហទំព័របណ្តាញព័ត៌មានសង្គម។ អ្នកធ្វើបាតុកម្មខ្លះត្រូវបានឃាត់ខ្លួន។ ប៉ុន្តែ ទោះបីជាមានរបួសធ្ងន់ធ្ងរ និង រហូតដល់ការស្លាប់នៃអ្នកមិនមានពាក់ព័ន្ធមួយចំនួនក្តី ក៏មិនមាននគរបាលឬអាជ្ញាធរដទៃទៀតដែលទទួលខុសត្រូវលើការរក្សាសន្តិភាពក្នុងព្រឹត្តិការណ៍ទាំងនេះ ត្រូវបានចោទប្រកាន់ពីបទល្មើសអ្វីទាំងអស់។ កង្វះការគោរពវិធានច្បាប់ដ៏ច្បាស់ ដែលតម្រូវឲ្យមានការស៊ើបអង្កេតនិងការចោទប្រកាន់អ្នកដែលទទួលខុសត្រូវលើការប្រើកម្លាំងហួសហេតុប្រឆាំងនឹងអ្នកចូលរួម គឺជាកង្វល់ដ៏ធំមួយ។

ប៉ុន្តែ គេឃើញមានចំណុចគួរឲ្យសង្ឃឹមមួយ។ ចំពោះមុខមហាបាតុកម្មនយោបាយថ្មីៗក្នុងខែកក្កដា សីហា និង កញ្ញា ឆ្នាំ ២០១៣ កងកម្លាំងសន្តិសុខក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលហាក់បីដូចជា សុខចិត្តយោគយល់ការជួបជុំសាធារណៈ ដែលរិះគន់រាជរដ្ឋាភិបាល និង សមិទ្ធកម្មរបស់រាជរដ្ឋាភិបាល។

ជាសង្ខេប ថ្វីបើរាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ការគាំទ្រលិខិតូបករណ៍អន្តរជាតិដែលការពារសេរីភាពខាងការជួបប្រជុំក្តី ក៏បញ្ហាប្រឈមចំពោះការជួបប្រជុំដោយសន្តិវិធីសម្រាប់ប្រជាជនកម្ពុជានៅតែកើតមាន។

## វិធីសាស្ត្រ

ព័ត៌មានខាងលើ ត្រូវបានដកស្រង់ពីការសិក្សាឯកសារច្រើន ជាពិសេស *ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ឆ្នាំ២០០៩* ការវិភាគដែលបានបោះពុម្ពផ្សាយ និង ពីការសម្ភាសន៍ភាគីពាក់ព័ន្ធសំខាន់ៗបីរូប ដែលនៅក្នុងនោះ ពីរនាក់គឺជាមន្ត្រីសហជីព និងម្នាក់តំណាងឲ្យអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមួយ។ ព័ត៌មានដែលមានត្រូវបានសម្រិតសម្រាំង និងផ្ទៀងផ្ទាត់ជាមួយនឹងភស្តុតាងពីនេះពីនោះដែលបានមកពីការសន្ទនាក្រៅផ្លូវការជាមួយតួអង្គសង្គមស៊ីវិល។

[42] http://www.cambodiadaily.com/news/groups-want-independent-human-rights-body-48227/, accessed 2 December 2013

## សេចក្ដីសង្ខេបអំពីបញ្ហាប្រឈមសំខាន់ៗ

បញ្ហាប្រឈមសំខាន់ៗទាក់ទិននឹងការជួបជុំដោយសន្តិវិធីនៅកម្ពុជា រួមមាន៖

- ការបដិសេធដោយបំពានយ៉ាងច្បាស់ពីមន្ត្រីរដ្ឋាភិបាលមូលដ្ឋាននូវសំណើប្រជុំ/ធ្វើបាតុកម្ម
- ការភ័យខ្លាចសម្រាប់អ្នករៀបចំ និងអ្នកចូលរួម ប្រជុំ/ធ្វើបាតុកម្ម ក្នុងការស៊ើបអង្កេតពីអាជ្ញាកណ្ដាល ឬមានការដាក់ទណ្ឌកម្មពីអាជ្ញាធរ
- ការជ្រៀតជ្រែក ឬ ការរំខានការជួបប្រជុំដោយសន្តិវិធីដោយអាជ្ញាធរ
- កំណើនម្ដងម្កាលនៃអំពើហិង្សាលើបាតុកម្មដោយសន្តិវិធី
- កង្វះការគោរពនីតិរដ្ឋក្នុងកិច្ចដំណើរការស៊ើបអង្កេតលើនគរបាល ឬអាជ្ញាធរដទៃទៀតដែលជាប់ ពាក់ព័ន្ធក្នុងការប្រព្រឹត្តអំពើហិង្សាប្រឆាំងនឹងអ្នកចូលរួមក្នុងការជួបប្រជុំដោយសន្តិវិធី។

# ផ្នែកទី ៨: ទំនាក់ទំនងរវាង រាជរដ្ឋាភិបាល និង សង្គមស៊ីវិល

## ទស្សនៈរួម

ទំនាក់ទំនងរវាងរាជរដ្ឋាភិបាលនិងសង្គមស៊ីវិលនៅកម្ពុជា ជាទូទៅ មានលក្ខណៈមិនទុកចិត្តគ្នា ទោះបីជាវាមានលក្ខណៈខុសគ្នាច្រើនក្តី ដែលភាគច្រើនផ្អែកលើប្រភេទនៃការងារដែលធ្វើដោយអង្គការសង្គមស៊ីវិល និង កម្រិតនៃរាជរដ្ឋាភិបាលដែលសង្គមស៊ីវិលពាក់ព័ន្ធជាមួយ។ អង្គការសង្គមស៊ីវិលដែលចូលរួមក្នុងការផ្តល់សេវាកម្មតាមវិស័យនានា ដូចជាសុខភាព ការអភិវឌ្ឍកសិកម្ម ចម្លើយតបមនុស្សធម៌ និង ការអប់រំ ជាទូទៅ មានទំនាក់ទំនងល្អជាងជាមួយរាជរដ្ឋាភិបាល។ អង្គការដែលជំរុញប្រជាធិបតេយ្យ និង សិទ្ធិមនុស្ស ច្រើនជួបប្រទះឧបសគ្គច្រើនជាងក្នុងទំនាក់ទំនងរបស់ពួកគេជាមួយរាជរដ្ឋាភិបាល។ ទំនាក់ទំនងរវាងសង្គមស៊ីវិលនិងរាជរដ្ឋាភិបាល ច្រើនតែមានលក្ខណៈរឹងមាំជាង និង មានប្រសិទ្ធភាពជាង នៅថ្នាក់ខេត្ត ស្រុក និង ឃុំ ប៉ុន្តែ មានលក្ខណៈមិនល្អនៅកម្រិតជាតិ។ ឯកសារយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល មានសារចម្រុះអំពីតួនាទីនិងគុណតម្លៃនៃអង្គការសង្គមស៊ីវិល ក្នុងការអនុវត្តជាក់ស្តែង តួអង្គសង្គមស៊ីវិលមានការលំបាកក្នុងការស្វែងរកលទ្ធភាពដើម្បីធ្វើការរួមចំណែកប្រកបដោយអត្ថន័យដល់កិច្ចដំណើរការនៃគោលនយោបាយសាធារណៈនៅកម្ពុជា។

## របកគំហើញ

ពុំមានឧបសគ្គផ្លូវច្បាប់ចំពោះការផ្តល់ធាតុចូលរបស់សង្គមស៊ីវិលទៅក្នុងដំណើរការរៀបចំនយោបាយនិងបោះឆ្នោត ឬ ដំណើរការគោលនយោបាយសាធារណៈនៅកម្ពុជាទេ។ ទោះជាយ៉ាងនេះក្តី ក៏កាតព្វកិច្ចខាងស្មារតីដែលត្រូវបានដាក់លើអង្គការសង្គមស៊ីវិលមិនឲ្យប្រកាន់បក្សពួក កំពុងរារាំងពួកគេមិនឲ្យចូលរួមក្នុងសកម្មភាពនយោបាយ។

ជាទូទៅ តួអង្គសង្គមស៊ីវិលនៅកម្ពុជាចង់បង្កើនវិភាគទានរបស់ខ្លួនចំពោះកិច្ចដំណើរការគោលនយោបាយសាធារណៈទាក់ទិននឹងការអភិវឌ្ឍកម្ពុជា។ បច្ចុប្បន្ន យន្តការសំខាន់ៗសម្រាប់ការពិគ្រោះយោបល់ និង ធានាការទទួលធាតុចូលទៅក្នុងផែនការអភិវឌ្ឍន៍កម្ពុជា រួមមាន៖

- វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) ដែលត្រូវធ្វើរាល់ ១២ ខែម្តង។ ក្នុងកិច្ចប្រជុំទាំងនេះ អង្គការមិនមែនរដ្ឋាភិបាលមានឱកាសបង្ហាញរបាយការណ៍ពួកគេផ្ទាល់អំពីការអភិវឌ្ឍកម្ពុជា។ វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) មិនបានជួបប្រជុំក្នុងអំឡុងពេលបីឆ្នាំចុងក្រោយនេះទេ។
- ក្រុមការងារបច្ចេកទេស (TWGs) ចំនួន ១៩ ដែលជួបប្រជុំទៀងទាត់ ដែលនៅក្នុងនោះភាគច្រើន ប៉ុន្តែ មិនទាំងអស់ទេ រួមមានតំណាងពីអង្គការមិនមែនរដ្ឋាភិបាល ដែលជាធម្មតាត្រូវបានកម្រិតឲ្យមានតំណាងតែមួយនាក់។

- តាមរយៈក្រុមការងារបច្ចេកទេស អង្គការមិនមែនរដ្ឋាភិបាលអាចផ្តល់ធាតុចូលចំពោះគោលនយោបាយ ដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិជាដើម។
- អង្គការមិនមែនរដ្ឋាភិបាល ក៏អាចចូលរួមផងដែរជាអ្នកសង្កេតការណ៍ក្នុងកិច្ចដំណើរការនៃគណៈកម្មាធិការសម្របសម្រួលរាជរដ្ឋាភិបាល-ដៃគូអភិវឌ្ឍន៍ និង អាចផ្តល់មតិកែលម្អជូនរាជរដ្ឋាភិបាល និងម្ចាស់ជំនួយ ដោយរៀបចំឯកសារគោលជំហរនៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីសូចនាកររួមសម្រាប់តាមដាន។ គណៈកម្មាធិការសម្របសម្រួលរាជរដ្ឋាភិបាល-ដៃគូអភិវឌ្ឍន៍ត្រូវជួបប្រជុំម្តងរាល់ ១២ ទៅ ១៨ ខែ ហើយគណៈកម្មាធិការនេះបានជួបប្រជុំចុងក្រោយនៅខែកញ្ញា ឆ្នាំ២០១២។ គេឃើញមានករណីកើតឡើងដែលការគ្រោងប្រជុំត្រូវបានលុបចោលដោយរាជរដ្ឋាភិបាលកម្ពុជា ក្នុងករណីដែលមានការរិះគន់លើរាជរដ្ឋាភិបាលដោយសមាជិកសំខាន់ៗនៃគណៈកម្មាធិការ។

ក្នុងការអនុវត្តជាក់ស្តែង វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) ត្រូវបានគេតំកល់ទុក ដែលវេទិកាមួយនេះមានលក្ខណៈបើកទូលាយបំផុតចំពោះការផ្តល់ធាតុចូលរបស់សង្គមស៊ីវិល។ អង្គការមិនមែនរដ្ឋាភិបាលចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេស រាយការណ៍ថាពួកគេមិនត្រូវបានគេផ្តល់ពេលវេលា និងលទ្ធភាពគ្រប់គ្រាន់ដើម្បីនិយាយទេ។

> សំណួរលើកឡើងអំពីគុណភាព នៃភាពជាតំណាងរបស់អង្គការសង្គមស៊ីវិល នៅក្នុងក្រុមការងារបច្ចេកទេស និងការផ្តល់ពេលវេលាសម្រាប់ឲ្យតួអង្គសង្គមចូលរួម ក្នុងយន្តការសហប្រតិបត្តិការ។ លទ្ធភាពពិតប្រាកដដែលត្រូវបានផ្តល់ឲ្យអង្គការសង្គមស៊ីវិល គឺជាបញ្ហាមួយ។ ជូនកាល អង្គការសង្គមស៊ីវិលត្រូវបានគេមើលរំលង។ ចំណុចនេះចាំបាច់ត្រូវកែលម្អ។
>
> អ្នកផ្តល់បទសម្ភាសន៍អនាមិក

'យុទ្ធសាស្ត្រចតុកោណ' ថ្មីរបស់រាជរដ្ឋាភិបាលកម្ពុជាលើកឡើង នូវជ្រុងបួននៃអភិវឌ្ឍន៍: ស្ថេរភាពសង្គម សមាហរណកម្មតំបន់ឯនិងអន្តរជាតិ ភាពជាដៃគូជាមួយសហគមន៍អន្តរជាតិនិងផ្នែកឯកជនដើម្បីការអភិវឌ្ឍប្រទេស និងការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ច។ អភិបាលកិច្ចល្អគឺជាស្នូលនៃយុទ្ធសាស្ត្រថ្មីនេះ ប៉ុន្តែ សង្គមស៊ីវិលមិនត្រូវបានបង្ហាញលេចធ្លោនៅក្នុងយុទ្ធសាស្ត្រចតុកោណនេះទេ។

ជាការពន្យល់ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៣ (ឆ្នាំ ២០១៣) បង្ហាញយ៉ាងជាក់លាក់នូវការប្តេជ្ញារបស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះ៖

- ការរៀបចំនិងការអនុវត្ត "**យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និង ភាពជាដៃគូឆ្នាំ២០១៤-២០១៨**"។ គោលដៅចម្បងនៃយុទ្ធសាស្ត្រនេះ គឺសំដៅពង្រឹង**ភាពជាដៃគូយ៉ាងពេញលេញជាមួយភាគីពាក់ព័ន្ធទាំងអស់**ក្នុងបរិបទថ្មី ដែលនៅក្នុងនោះ ប្រទេសកម្ពុជាត្រូវដោះស្រាយបញ្ហាប្រឈមធំៗពីរ (១) ភាពចាំបាច់ត្រូវកំណត់ឡើងវិញនូវតួនាទីនៃហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ ដោយសារការធ្លាក់ចុះហិរញ្ញប្បទានជំនួយឥតសំណងពិភពលោក និង ការអភិវឌ្ឍក្នុងចំណាត់ការភាពជាដៃគូជាមួយដៃគូនីមួយៗ, និង (២) ការធ្លាក់ចុះរំពឹងនៅក្នុងហិរញ្ញប្បទានបែបសម្បទាននៅពេលដែលប្រទេសកម្ពុជាឈានដល់ឋានៈជាប្រទេសមានប្រាក់ចំណូលមធ្យមទាបនាអនាគតដ៏ខ្លី។
- ធ្វើការប្រជុំពិគ្រោះយោបល់ប្រចាំឆ្នាំរវាងរាជរដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាល ទន្ទឹមគ្នានឹងការជំរុញការអនុម័តច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល តាមរយៈការពិគ្រោះយោបល់ទូលាយជាមួយភាគីពាក់ព័ន្ធទាំងអស់ដើម្បីធានាឲ្យបាននូវប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាពនៃកិច្ចប្រតិបត្តិការរបស់ពួកគេ។
- បន្តពង្រឹង**វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន កិច្ចប្រជុំពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាល យន្តការពិគ្រោះយោបល់ទ្វេភាគី** សំដៅប្រែក្លាយវេទិកាទាំងអស់នេះទៅជា "**វេទិកាអភិវឌ្ឍន៍កម្ពុជា**" មួយ ដែលបំពេញមុខងារជាងវេទិកាឯកភាពមួយសម្រាប់ការសន្ទនារវាងរាជរដ្ឋាភិបាល និង ភាគីពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលទាំងអស់ រួមមាន ដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន និង អង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជាភាគីពាក់ព័ន្ធផ្សេងទៀត ដើម្បីពិភាក្សាបញ្ហាអភិវឌ្ឍន៍ក្នុងប្រទេស[43]។

ដូចដែលអាចឃើញច្បាស់ពីការដកស្រង់ខាងលើនៃយុទ្ធសាស្ត្រចតុកោណ សក្តានុពលតួនាទីរបស់សង្គមស៊ីវិលក្នុងការរួមចំណែកដល់ការអភិវឌ្ឍកម្ពុជាមិនត្រូវបានទទួលស្គាល់យ៉ាងពេញលេញទេ។ អ្នកផ្តល់បទសម្ភាសន៍មួយរូបពីអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមួយ បានបញ្ជាក់យ៉ាងខ្លាំងថាៈ"វាគឺជារឿងកម្រណាស់ដែលរដ្ឋាភិបាលជាតិមិនយកចិត្តទុកដាក់ចំពោះភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិលដូចជាករណីនៅកម្ពុជា"។

អាស្រ័យហេតុនេះ ការប្តេជ្ញាទាំងបីដែលបានលើកឡើងក្នុងយុទ្ធសាស្ត្រចតុកោណ (ខាងលើ) ត្រូវបានពិនិត្យមើលនៅទីនេះ។ ទីមួយ យុទ្ធសាស្ត្រភាពជាដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍ (DCPS) ឆ្នាំ ២០១៤-២០១៨ ត្រូវបានព្រាងរួចហើយ។ យុទ្ធសាស្ត្រនេះមិនបានលើកឡើងពីតួនាទីគន្លឹះរបស់សង្គម

---

[43] http://library.opendevelopmentcambodia.net:8080/newgenlibctxt/CatalogueRecords/SNEC-RECTANGULAR%20STRATEGY-PHASE%20III-ENGLISH(6SEPT2013)_Final.pdf, accessed 2 December 2013

ស៊ីវិលជាដៃគូអភិវឌ្ឍន៍មួយ អនុលោមតាមរបៀបវារៈក្រុងអាក្រាដើម្បីសកម្មភាព។ យុទ្ធសាស្ត្រភាពជាដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍ (DCPS) កំណត់ការងាររបស់អង្គការសង្គមស៊ីវិលត្រឹមតែជាការគាំទ្រដល់ការផ្តល់សេវាកម្មប៉ុណ្ណោះ។ តួនាទីទូលាយជាងនេះ របស់អង្គការសង្គមស៊ីវិល ក្នុងការជំរុញប្រជាធិបតេយ្យ ជាអ្នកឃ្លាំមើល ឬ ក្នុងការអប់រំប្រជាពលរដ្ឋអំពីសិទ្ធិពួកគេ មិនត្រូវបានទទួលស្គាល់ឡើយ។ ក្នុងលក្ខណៈវិជ្ជមានជាង "កម្មវិធីនយោបាយ" របស់រាជរដ្ឋាភិបាលសម្រាប់អាណត្តិទីប្រាំរបស់ខ្លួន ទទួលស្គាល់តួនាទីទូលាយសម្រាប់តួអង្គសង្គម និង ប្តេជ្ញាចំពោះ 'ការបង្កលក្ខណៈឲ្យពួកគេអាចចូលរួមក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ដែលជំរុញប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស និងការតាមដានការអនុវត្តគោលនយោបាយ'[44] (ទំព័រទី ១២)។

ទីពីរ និង ជាថ្មីម្តងទៀតក្នុងលក្ខណៈវិជ្ជមានជាង នាយករដ្ឋមន្ត្រី ហ៊ុន សែន បានអំពាវនាវឲ្យមានវេទិកាប្រចាំឆ្នាំមួយរវាងរាជរដ្ឋាភិបាល និងសង្គមស៊ីវិល។ កិច្ចប្រជុំមួយក្នុងលក្ខណៈបែបនេះ បានប្រព្រឹត្តទៅកាលពីខែ កុម្ភៈ ឆ្នាំ ២០១២ ហើយតួអង្គសង្គមស៊ីវិលមួយចំនួនសង្ឃឹមថាការសន្ទនានេះនឹងមានជាបន្តទៀត។ ក្រោយកិច្ចប្រជុំនោះ គោលការណ៍ណែនាំត្រូវបានចេញអំពីការធ្វើប្រជុំរបៀបនេះសម្រាប់ពេលក្រោយ ។ ប៉ុន្តែ ពុំមានការប្រជុំបែបនេះបានប្រព្រឹត្តទៅ និង ពុំមានសញ្ញាដែលថាតើការប្រជុំបែបនេះ នឹងត្រូវបានធ្វើនាអនាគត។

ទីបី បំណងចង់បង្កើតវេទិកាអភិវឌ្ឍន៍កម្ពុជាថ្មីមួយ ក៏ត្រូវបានដាក់បញ្ចូលផងដែរក្នុង 'កម្មវិធីនយោបាយ' របស់រាជរដ្ឋាភិបាល។ ការប្តេជ្ញានេះ ហាក់បីដូចជាផ្ទុយនឹងការប្តេជ្ញាទីពីរដែលបន្តការប្រជុំពិគ្រោះយោបល់ប្រចាំឆ្នាំជាមួយអង្គការសង្គមស៊ីវិល។ គេនៅត្រូវរង់ចាំមើលថាតើការប្តេជ្ញាទាំងនេះត្រូវបានអនុវត្តយ៉ាងដូចម្តេចដោយរាជរដ្ឋាភិបាលកម្ពុជា។

ថ្វីបើមិនត្រូវបានទទួលស្គាល់ក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៣ ក្តី ក៏អនុស្សារណៈនៃការយោគយល់កម្រិតខ្ពស់មួយរវាងអង្គការសង្គមស៊ីវិល និងរាជរដ្ឋាភិបាលកម្ពុជា ត្រូវបានស្នើឡើងផងដែរ។ ឯកសារទស្សនទានមួយ និង ឯកសារយោងលក្ខខ័ណ្ឌការងារអមមួយ ត្រូវបានផ្សព្វផ្សាយ ហើយការពិគ្រោះយោបល់ដំបូងមួយចំនួនបានប្រព្រឹត្តទៅទាក់ទិននឹងគំនិតផ្តួចផ្តើមនេះ។

ដូចដែលត្រូវបានបង្ហាញជាភស្តុតាងដោយពាក្យដកស្រង់ខាងក្រោម រដ្ឋាភិបាលថ្នាក់ក្រោមជាតិ ច្រើនមានលក្ខណៈប្រសើរក្នុងការពិគ្រោះយោបល់ និងរាប់បញ្ចូលសង្គមស៊ីវិលជាងរដ្ឋាភិបាលជាតិ។

> រដ្ឋាភិបាលមូលដ្ឋានជាទូទៅមានលក្ខណៈអាចទទួលយកបានក្នុងការពិគ្រោះជាមួយអង្គការសង្គមស៊ីវិលអំពីផែនការអភិវឌ្ឍន៍ឃុំ និង កម្មវិធីវិនិយោគឃុំ។
>
> អ្នកផ្តល់បទសម្ភាសន៍អនាមិក

---

[44] http://www.sithi.org/admin/upload/media/[2013-09-26]Political/2013_09_25_Political_Platform_Royal_Government_Cambodia_5th_English.pdf, accessed 2 December 2013

អ្នកផ្តល់បទសម្ភាសន៍ពីសង្គមស៊ីវិល ច្រើនរាយការណ៍អំពីទំនាក់ទំនងវិជ្ជមានជាង ជាមួយរដ្ឋាភិបាលថ្នាក់ក្រោម និងថ្នាក់មធ្យម។ ប្រការនេះ គឺស្របគ្នានឹងរបកគំហើញរបស់គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជាថា "ខណៈដែល ៧២% នៃអង្គការសង្គមស៊ីវិលដែលបានធ្វើអង្កេតបានកំណត់យ៉ាងហោចណាស់កម្រិតមួយនៃរាជរដ្ឋាភិបាលជាភាគីពាក់ព័ន្ធក្នុងកម្រិតមួយ រដ្ឋាភិបាលមូលដ្ឋានត្រូវបានគេយល់ថា ជាភាគីពាក់ព័ន្ធមួយសំខាន់ជាងរដ្ឋាភិបាលកណ្តាល (ដូចជាក្រសួងពាក់ព័ន្ធជាដើម)" (គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ឆ្នាំ២០១២ ទំព័រ ៤៨)។ ប្រការនេះបង្ហាញថា "ថ្វីបើអង្គការសង្គមស៊ីវិលធ្វើប្រតិបត្តិការក្នុងលក្ខណៈស្វ័យ័ត ពោលគឺមិនសម្របតាមកម្មវិធី និង អាទិភាពថ្នាក់ជាតិនៃរាជរដ្ឋាភិបាលកម្ពុជាក្តី ក៏ពួកគេពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយជួររដ្ឋាភិបាលដែលនៅកំរិតមូលដ្ឋានជាង លើការអនុវត្តកម្មវិធី និងទំនាក់ទំនងផ្សេងៗ លើផែនការមូលដ្ឋាន បរិបទ និង ថាមភាព" (គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ឆ្នាំ២០១២ ទំព័រ ៤៨)។

ក្នុងករណីជាច្រើន តួអង្គសង្គមស៊ីវិលក៏រាយការណ៍ផងដែរអំពីទំនាក់ទំនងជាវិជ្ជមានជាមួយក្រសួងពាក់ព័ន្ធដែលពួកគេពាក់ព័ន្ធជាមួយ ទោះបីជាទំនាក់ទំនងនេះមានលក្ខណៈខុសគ្នាសម្រាប់ក្រសួងផ្សេងៗគ្នាក្តី។ ក្រសួងពាក់ព័ន្ធមួយចំនួន ធ្វើការប្រជុំប្រចាំឆ្នាំជាមួយអង្គការមិនមែនរដ្ឋាភិបាលដែលពួកគេមានអនុស្សារណៈនៃការយោគយល់។ វេទិកាប្រចាំឆ្នាំនៃក្រសួងអប់រំជាមួយអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានវាយតម្លៃខ្ពស់។ ដូចគ្នានេះដែរ ក្រុមការងារភាពជាដៃគូក្នុងការងារវិមជ្ឈការនៃក្រសួងមហាផ្ទៃ ហាក់បីដូចជាមានប្រសិទ្ធភាព។

> ក្រសួងមហាផ្ទៃ កំពុងអនុវត្តបានល្អលើការងារនេះ។ រាល់ត្រីមាស ពួកគេមានកិច្ចប្រជុំមួយជាមួយអង្គការមិនមែនរដ្ឋាភិបាលដែលចូលរួមក្នុងការងារវិមជ្ឈការនិងវិសហមជ្ឈការ។ ក្រុមការងារនេះ មានឈ្មោះថាក្រុមការងារសម្រាប់ភាពជាដៃគូក្នុងវិមជ្ឈការ។ ក្រុមការងារនេះគឺជាវេទិកាល្អមួយ ហើយកំពុងកសាងទំនាក់ទំនង។
>
> អ្នកផ្តល់បទសម្ភាសន៍អនាមិក

ការពិគ្រោះយោបល់ដឹកនាំដោយរាជរដ្ឋាភិបាលជាមួយសង្គមស៊ីវិល ជូនកាល ពិតជាមានកើតឡើងមែន។ ឧទាហរណ៍ ការពិគ្រោះយោបល់មួយចំនួនត្រូវបានធ្វើ ដើម្បីពិភាក្សាសេចក្តីព្រាងច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាលនិងសមាគម។ តួអង្គសង្គមស៊ីវិលខ្លះត្អូញត្អែរថាការពិគ្រោះយោបល់មិនត្រូវបានប្រកាសទាន់ពេល និងមិនផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ការសន្ទនា ក្នុងលក្ខណៈស្ថាបនា។ ម្យ៉ាងទៀត ការពិគ្រោះយោបល់ច្រើនមានលក្ខណៈជាព្រឹត្តិការណ៍ដាច់ដោយឡែក និង មិនមែនជាផ្នែកមួយនៃការសន្ទនាដែលកំពុងដំណើរការ។ ព្រឹត្តិការណ៍បែបនេះ ត្រូវបានចាត់ទុកដោយអង្គការមួយចំនួនថាជាកិច្ចប្រឹងប្រែងដើម្បីលួងតួអង្គសង្គមស៊ីវិលតាមរយៈការចូលរួម 'ជានិមិត្តរូប'។ ឧទាហរណ៍ ព្រឹត្តិការណ៍ពិគ្រោះយោបល់មិនមែនសុទ្ធតែមានដាក់បញ្ចូលកម្មវិធីសំណួរនិងចម្លើយមួយទេ។

គេក៏ឃើញមានផងដែរនូវករណីធ្លាប់មានដែលបុគ្គលមួយចំនួនក្នុងរាជរដ្ឋាភិបាលពាក់ព័ន្ធក្នុងការជ្រើសរើសយកអង្គការមិនមែនរដ្ឋាភិបាលជាក់លាក់ឲ្យធ្វើជាតំណាងឲ្យសង្គមស៊ីវិលកម្ពុជាក្នុងការពិគ្រោះយោបល់ ជាពិសេសក្នុងវេទិកាអន្តរជាតិ ជំនួសការអនុញ្ញាតឲ្យអង្គការសង្គមស៊ីវិលចាត់តំណាងដោយខ្លួនឯង[45]។ ចំណុចនេះ ធ្វើឲ្យមានតំណាងសម្លេងសង្គមស៊ីវិលតែមួយផ្នែកប៉ុណ្ណោះពោលគឺ អង្គការសង្គមស៊ីវិលទាំងឡាយដែលឯកភាពជាមួយនឹងគោលការណ៍និងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។ វេទិកាប្រជាពលរដ្ឋអាស៊ាន ឆ្នាំ ២០១២ គឺជាករណីមួយ[46]។

នៅពេលសង្គមស៊ីវិលផ្តល់ធាតុចូលដល់កិច្ចដំណើរការគោលនយោបាយសាធារណៈជូនកាល ធាតុចូលទាំងនេះត្រូវបានគេមើលរំលង។

> ជាមួយសូចនាករតាមដានរួម តិចជាង ២០% នៃធាតុចូល របស់សង្គមស៊ីវិល ត្រូវបានពិចារណា។ រាជរដ្ឋាភិបាលហាក់បីដូចជាវិនិច្ឆ័យថា ធាតុចូលស្ទើរតែទាំងអស់របស់អង្គការសង្គមស៊ីវិលមិនមានលក្ខណៈសមស្រប។
>
> អ្នកផ្តល់បទសម្ភាសន៍អនាមិក

> ក្នុងករណីខ្លះ ពួកគេ (រាជរដ្ឋាភិបាល) បានអញ្ជើញខ្ញុំឲ្យចូលរួមប្រជុំ ប៉ុន្តែ មិនមែនដើម្បីពិភាក្សាទេ។ ពួកគេជេរប្រមាថខ្ញុំអស់ពេលមួយម៉ោង និង មិនបានអនុញ្ញាតឲ្យខ្ញុំនិយាយឬបំភ្លឺអ្វីឡើយ។
>
> អ្នកផ្តល់បទសម្ភាសន៍អនាមិក

អ្នកផ្តល់បទសម្ភាសន៍ម្នាក់ទៀត បានចែករំលែករឿងមួយមានលក្ខណៈវិជ្ជមានជាង:

> ច្បាប់ភូមិបាលគឺជាករណីល្អមួយដែលបង្ហាញថាយើងបានធ្វើការរួមគ្នា។ មតិកែលម្អត្រូវបានទទួលយកទៅពិចារណា។
>
> អ្នកផ្តល់បទសម្ភាសន៍អនាមិក

សមត្ថភាពរបស់តួអង្គសង្គមស៊ីវិលក្នុងការចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងកិច្ចដំណើរការគោលនយោបាយសាធារណៈជាតិ ហាក់បីដូចជាមានលក្ខណៈល្មម ថ្វីបើមានការមិនឯកភាពគ្នាលើចំណុចនេះក្តី។ អ្នកផ្តល់បទសម្ភាសន៍ខ្លះនិយាយថាមានសមត្ថភាពខ្ពស់ ហើយអ្នកផ្សេងទៀតនិយាយថាមានសមត្ថភាពទាប។

---

[45] http://www.opendevelopmentcambodia.net/news/ngo-representatives-chosen-months-ago-statement-claims/, accessed 2 December 2013
[46] http://www.cambodiadaily.com/archive/in-one-city-a-tale-of-two-peoples-forums-603/, accessed 2 December 2013

## វិធីសាស្ត្រ

ព័ត៌មានដែលបានពន្យល់ទីនេះត្រូវបានដកស្រង់ពីការសិក្សាឯកសារសំខាន់ៗ ការសម្ភាសន៍ជាមួយភាគីពាក់ព័ន្ធសំខាន់ៗប្រាំបីនាក់។ អ្នកផ្តល់បទសម្ភាសន៍ រួមមានម្នាក់មកពីគ្រឹះស្ថានសិក្សា ប្រាំនាក់មកពីអង្គការក្នុងស្រុក និង ពីរនាក់មកពីអង្គការអន្តរជាតិមួយ។ ព័ត៌មានដែលមានត្រូវបានសម្រិតសម្រាំងនិងផ្ទៀងផ្ទាត់ជាមួយនឹងភស្តុតាងពីនេះ ពីនោះ ដែលបានមកពីការសន្ទនាក្រៅផ្លូវការជាមួយតួអង្គសង្គមស៊ីវិល។

## សេចក្តីសង្ខេបអំពីបញ្ហាប្រឈមសំខាន់ៗ

បញ្ហាប្រឈមសំខាន់ៗសម្រាប់ទំនាក់ទំនងរវាងរាជរដ្ឋាភិបាល និងសង្គមស៊ីវិល រួមមានៈ

- កង្វះទំនុកចិត្ត ជាពិសេសរវាងរាជរដ្ឋាភិបាល និង អង្គការសង្គមស៊ីវិលទាំងឡាយដែលធ្វើសកម្មភាពលើការជំរុញលទ្ធិប្រជាធិបតេយ្យ និង សិទ្ធិមនុស្ស
- កង្វះការយល់ពីរបៀបធ្វើការងាររួមគ្នាក្នុងភាពជាដៃគូ ទាំងផ្នែក រាជរដ្ឋាភិបាល និង ផ្នែកសង្គមស៊ីវិល
- ការខកខានក្នុងការបញ្ជាក់តួនាទីច្បាស់លាស់ជូនសង្គមស៊ីវិលនៅក្នុងយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាលកម្ពុជា
- សារចម្រុះនៅក្នុងយុទ្ធសាស្ត្រនិងគោលនយោបាយផ្សេងៗរបស់រាជរដ្ឋាភិបាលអំពីតួនាទីរបស់សង្គមស៊ីវិល
- ឱកាសមិនគ្រប់គ្រាន់សម្រាប់ការសន្ទនាគ្នា និង សម្រាប់ឲ្យរាជរដ្ឋាភិបាលនិងសង្គមស៊ីវិលផ្តល់ធាតុចូល និងមតិកែលម្អប្រកបដោយអត្ថន័យជូនគ្នាទៅវិញទៅមក ជាពិសេសនៅកម្រិតជាតិ
- លំហ និងពេលវេលាមិនគ្រប់គ្រាន់ សម្រាប់ការរួមចំណែក របស់តួអង្គសង្គម ដល់ក្រុមការងារបច្ចេកទេស និង យន្តការពិគ្រោះយោបល់ស្រដៀងគ្នាផ្សេងទៀត
- កង្វះភាពច្បាស់លាស់អំពីវេទិកាគ្រោងប្រចាំឆ្នាំរាជរដ្ឋាភិបាល និង សង្គមស៊ីវិល
- សមត្ថភាពមានកម្រិតសម្រាប់កិច្ចសហប្រតិបត្តិការ ទាំងខាងរាជរដ្ឋាភិបាល និងទាំងខាងសង្គមស៊ីវិល
- កង្វះចំណាប់អារម្មណ៍ឬឆន្ទៈនយោបាយសម្រាប់កិច្ចសហប្រតិបត្តិការទាំងផ្នែករាជរដ្ឋាភិបាល និងផ្នែកសង្គមស៊ីវិល។

# ផ្នែកទី ៩: កិច្ចសហប្រតិបត្តិការ និង សម្ព័ន្ធភាពសង្គមស៊ីវិល

## ទស្សនៈរួម

សម្ព័ន្ធភាពនៃអង្គការសង្គមស៊ីវិល គឺជារឿងធម្មតានៅកម្ពុជា។ ប៉ុន្តែ ពុំមានការរាប់ចំនួនសម្ព័ន្ធភាពដើម្បីបញ្ជាក់ចំណុចនេះទេ។ កិច្ចសហប្រតិបត្តិការក្នុងចំណោមអង្គការសង្គមស៊ីវិលកំពុងកើនឡើង ប៉ុន្តែ ជាទូទៅ ជម្រៅនៃកិច្ចសហប្រតិបត្តិការគឺទាប។ ម្យ៉ាងទៀត កម្រិតនៃកិច្ចសហប្រតិបត្តិការមានលក្ខណៈខុសគ្នាច្រើនតាមវិស័យ ពោលគឺវិស័យខ្លះមានកម្រិតសហប្រតិបត្តិការខ្ពស់។ វិស័យផ្សេងទៀត សូម្បីតែវិស័យទាំងឡាយដែលចាត់ចែងសម្ព័ន្ធភាពចម្រុះ ហាក់បីដូចជាមានកិច្ចសហប្រតិបត្តិការទាប។ ជាទូទៅ កិច្ចសហប្រតិបត្តិការអន្តរវិស័យ គឺទាប។ ក្រុមសមាជិកភាពមានយន្តការតិចពេក សម្រាប់ធ្វើការវាយតម្លៃស្នាដៃអនុវត្តការងារ និង ឱកាសតិចតួចដើម្បីទទួល និងដោះស្រាយបណ្តឹងតវ៉ារបស់សមាជិក។ ពុំមានការត្រួតពិនិត្យរបស់រាជរដ្ឋាភិបាលលើភាពជាដៃគូនិងសម្ព័ន្ធភាពទេ ទោះបីជាសំណើច្បាប់ថ្មីស្តីពីអង្គការមិនមែនរដ្ឋាភិបាល និងសមាគមនឹងដាក់ឲ្យអនុវត្តនូវកិច្ចដំណើរការមួយសម្រាប់ចុះបញ្ជី និងត្រួតពិនិត្យសម្ព័ន្ធភាពក្តី។

## របកគំហើញ

ច្បាប់បច្ចុប្បន្នដែលមានឥទ្ធិពលលើសង្គមស៊ីវិលនៅកម្ពុជា និងជាពិសេស *ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧* មិនមានចែងអំពីបញ្ហានៃសម្ព័ន្ធភាព ឬកិច្ចព្រមព្រៀងសហប្រតិបត្តិការឡើយ។ ដោយសារចំណុចនេះ មានការយល់ជាទូទៅថាអង្គការសង្គមស៊ីវិលក្នុងស្រុកអាចចងសម្ព័ន្ធភាពស្របច្បាប់ជាមួយអង្គការសង្គមស៊ីវិលអន្តរជាតិ ឬអង្គការសង្គមស៊ីវិលអន្តរជាតិចងសម្ព័ន្ធជាមួយអង្គការសង្គមស៊ីវិលក្នុងស្រុក។ ពុំមានការត្រួតពិនិត្យរបស់រាជរដ្ឋាភិបាលលើភាពជាដៃគូ និង សម្ព័ន្ធភាពទេ។

សម្ព័ន្ធភាពនៃអង្គការសង្គមស៊ីវិល ត្រូវបានគេចាត់ទុកថាជារឿងធម្មតាណាស់នៅកម្ពុជា។ ប៉ុន្តែ គេមិនអាចកំណត់បរិមាណនៃវត្តមាននៃសម្ព័ន្ធភាព ឬ សមាគមនៃអង្គការមិនមែនរដ្ឋាភិបាលបានឡើយ។ ចំណុចនេះ គឺដោយសារការចុះបញ្ជីមិនត្រូវបានកំណត់អត្តសញ្ញាណដោយឡែកថាជាសម្ព័ន្ធភាព ឬ សមាគមឡើយ និង ពុំមានការរាប់ចំនួនអង្គការបែបនេះដោយឯករាជ្យ។ ម្យ៉ាងទៀត សម្ព័ន្ធភាពជាច្រើននៅតែមិនបានចុះបញ្ជី និង មានលក្ខណៈក្រៅប្រព័ន្ធ ដែលធ្វើការរួមគ្នាដោយមានការជួយគាំទ្រនៃលេខាធិការដ្ឋានមួយ (អង្គការមិនមែនរដ្ឋាភិបាលចុះបញ្ជីមួយ)។ ការខកខានមិនបានចុះបញ្ជីសម្ព័ន្ធភាពមិនត្រូវបានចាត់ទុកថាជាបញ្ហាទេ ដោយសារសមាជិកនៃសម្ព័ន្ធភាពសុទ្ធតែបានចុះបញ្ជីស្របច្បាប់រៀងៗខ្លួនរួច។

ការសិក្សាមួយចំនួនអំពី អង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា បានរកឃើញថាកិច្ចសហប្រតិបត្តិការ កំពុងកើនឡើង ប៉ុន្តែជាទូទៅ ជម្រៅនៃកិច្ចសហប្រតិបត្តិការ មានកម្រិតទាបៈ

មានការកសាងបណ្តាញក្នុងកម្រិតជាច្រើននៅក្នុងអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា និង ជាទូទៅក្នុងអង្គការសង្គមស៊ីវិល ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យភូមិសាស្ត្រ (បណ្តាញថ្នាក់មូលដ្ឋាន ខេត្ត ជាតិ) ឬ វិស័យនៃសកម្មភាព ជាមួយតួនាទីនិងគោលដៅផ្សេងៗគ្នាច្រើន គឺជាទម្រង់ទូទៅបំផុតនៃការផ្លាស់ប្តូរព័ត៌មាន និង ការសម្របសម្រួល ដែលឆ្លើយតបទៅនឹងតួនាទីកាន់តែមានលក្ខណៈទាមទារនៃការរៀនសូត្រ ឬ ការតស៊ូមតិ និង ការសន្ទនាគោលនយោបាយ។ ប្រសិនបើវិធីដែលនៅក្នុងនោះបណ្តាញទាំងនេះត្រូវបានរៀបចំមានលក្ខណៈអភិវឌ្ឍខ្លាំង ឫសគល់នៃបណ្តាញមានលក្ខណៈចង្អៀត (Merla ឆ្នាំ ២០១០, ទំព័រ ២៦)។ (សូមមើល គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ឆ្នាំ២០១២, Rasmussen ឆ្នាំ២០១០)។

កិច្ចសហប្រតិបត្តិការតិចតួចក្នុងសង្គមស៊ីវិល ក៏ប្រហែលជារួមចំណែកផងដែរដល់លទ្ធភាពថយចុះក្នុងការប្រាស្រ័យទាក់ទង ក្នុងសម្លេងតែមួយ និងរបៀបវារៈរួមមួយ ជាមួយរាជរដ្ឋាភិបាល ដែលធ្វើឲ្យទំនាក់ទំនងរវាងសង្គមស៊ីវិល និងរាជរដ្ឋាភិបាលមានលក្ខណៈកាន់តែស្មុគ្រស្មាញ និង រាយប៉ាយ។

ម្យ៉ាងទៀត ស្ថាប័នកំពូល ឬ ក្រុមសមាជិកភាព ត្រូវបានគេមើលឃើញថាមានយន្តការតិចតួច សម្រាប់ធ្វើការវាយតម្លៃលើស្នាដៃអនុវត្តការងាររបស់ពួកគេ ឬ ឱកាសទទួលនិងដោះស្រាយបណ្តឹងតវ៉ាពីសមាជិកប្រកបដោយតម្លាភាព (Merla ឆ្នាំ២០១០)។ តាមពិត ប្រការនេះមានន័យថាស្ថាប័នកំពូលក៏អនុវត្តគម្រូភាពជាតំណាង និង ការធ្វើសេចក្តីសម្រេចដូចគ្នា ដែលដោយសារមូលហេតុនេះ កិច្ចដំណើរការប្រជាធិបតេយ្យកម្មនៅកម្ពុជាបច្ចុប្បន្ន កំពុងត្រូវបានគេទិតៀន និង មានឱនភាពដូចគ្នានៅក្នុងអភិបាលកិច្ច។

ឧទាហរណ៍វិជ្ជមានមួយនៃកិច្ចសហប្រតិបត្តិការសង្គមស៊ីវិលនៅកម្ពុជា គឺការបង្កើត 'ប្រព័ន្ធគណនេយ្យភាពចំពោះគ្នា'។ ប្រព័ន្ធផ្តល់ស្វ័យវិញ្ញាបនបត្រនេះ ត្រូវបានដាក់ឲ្យអនុវត្តដោយគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ដែលជាស្ថាប័នកំពូលដ៏សំខាន់មួយនៅក្នុងវិស័យ។ ប្រព័ន្ធនេះ គឺផ្អែកលើក្រមសីលធម៌ និង ស្តង់ដារអប្បបរមាសម្រាប់អង្គការមិនមែនរដ្ឋាភិបាល ដែលត្រូវបានអភិវឌ្ឍតាមរយៈកិច្ចដំណើរការ ដោយមានការចូលរួមទូលាយមួយដែលដឹកនាំដោយក្រុមការងារមួយនៃតំណាងសហគមន៍ អង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា និង ដាក់បញ្ចូលមតិកែលម្អពីអ្នកចូលរួមទូលាយពីអង្គការមិនមែនរដ្ឋាភិបាល ក្រសួងរាជរដ្ឋាភិបាល និង ភាគីអភិវឌ្ឍន៍ផ្សេងទៀត។ ប្រព័ន្ធស្វ័យវិញ្ញាបនបត្រនេះ បានវិវត្តន៍សម្រាប់ការអនុវត្តតាំងពីឆ្នាំ ២០០៧ ប៉ុន្តែ មកដល់ពេលនេះមានអត្រាទទួលបានតិច។ គិតមកដល់ខែវិច្ឆិកា ឆ្នាំ២០១៣ អង្គការចំនួន ៣២ ត្រូវបានបញ្ជាក់ថាគោរពតាមក្រមសីលធម៌ និង ស្តង់ដារអប្បបរមា ហើយអង្គការចំនួន ១០៨ ទៀតកំពុងចូលរួមក្នុង

កិច្ចដំណើរការដើម្បីទទួលវិញ្ញាបនបត្រ[47]។ ការគាំទ្រមូលនិធិចំពោះគំនិតផ្តួចផ្តើមនេះ បានមកពី ទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិ (AusAID) អង្គការ Action Aid International អង្គការ Concern Worldwide និង ទីភ្នាក់ងារអេស្ប៉ាញសម្រាប់កិច្ចសហប្រតិបត្តិការនិងអភិវឌ្ឍន៍អន្តរជាតិ (AECID)។

យោងតាមអ្នកផ្តល់បទសម្ភាសន៍ កម្រិតនៃកិច្ចសហប្រតិបត្តិការ មានលក្ខណៈខុសគ្នាតាមវិស័យ។ កិច្ចសហប្រតិបត្តិការត្រូវបានលើកឡើងថាមានកម្រិតខ្ពស់បំផុតក្នុងវិស័យដីធ្លី អប់រំ សុខភាព និង ទឹកនិងអនាម័យ និង ក្នុងវិស័យកសិកម្ម និងបរិស្ថាន។

> វិស័យទឹកស្អាតនិងអនាម័យ (WATSAN) គឺជាគម្រោងមួយដែលមានការសម្របសម្រួលគ្នាប្រសើរបំផុត ហើយគម្រោងនេះត្រូវបានដឹកនាំដោយក្រសួងអភិវឌ្ឍន៍ជនបទ។ អស់រយៈ ១៨-២០ ឆ្នាំរួចមកហើយ ការប្រជុំទាំងនេះបានធ្វើឡើងរាល់ថ្ងៃអង្គារ នៃសប្តាហ៍ទីពីររៀងរាល់ខែ។ ចំណុចនេះគួរឲ្យចាប់អារម្មណ៍។
>
> អ្នកផ្តល់បទសម្ភាសន៍អនាមិក

អង្គការការពារសិទ្ធិមនុស្ស ជាទូទៅ ត្រូវបានចាត់ទុកថាមានការសម្របសម្រួលមិនខ្សោយ។ ដូចគ្នានេះដែរ វិស័យសិទ្ធិកុមារ/ប្រឆាំងនឹងការជួញដូរមានបណ្តាញច្រើន ដែលអ្នកផ្តល់បទសម្ភាសន៍ខ្លះយល់ថាមានលក្ខណៈច្របូកច្របល់។ វិស័យមេរោគអេដស៍/ជម្ងឺអេដស៍ និងវិស័យយេនឌ័រ ក៏មានបណ្តាញត្រួតស៊ីគ្នាមួយចំនួនដែរ ហើយអង្គការកសាងសន្តិភាពក៏មានការសម្របសម្រួលមិនល្អដូចគ្នាដែរ។

ជារួម កិច្ចសហប្រតិបត្តិការជុំវិញបញ្ហាបច្ចេកទេស ត្រូវបានចាត់ទុកថាមានលក្ខណៈងាយស្រួលជាង និង មានជោគជ័យជាងកិច្ចសហប្រតិបត្តិការអន្តរវិស័យ។ ការជួយគាំទ្រសកម្មភាពជាសមូហភាពនៅតាមតំបន់នានា ដែលនៅក្នុងនោះ អង្គការមួយមិនមានជំនាញបច្ចេកទេសជាក់លាក់ត្រូវបានគេយល់ថាមានលក្ខណៈលំបាកសម្រាប់អង្គការជាច្រើន។

សេចក្តីព្រាងច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាលនិងសមាគម ចែងពីការបង្កើតសម្ព័ន្ធភាពនៃអង្គការមិនមែនរដ្ឋាភិបាល។ ប៉ុន្តែ អ្នកផ្តល់បទសម្ភាសន៍មួយរូបបានកត់សម្គាល់ថាច្បាប់នេះ នៅពេលដាក់ឲ្យអនុវត្ត ទំនងជានឹងត្រូវបានបកស្រាយនិងអនុវត្ត ក្នុងលក្ខណៈមួយដែលអំណោយផលសម្រាប់អង្គការផ្តល់សេវាកម្មជាងអង្គការទាំងឡាយដែលប្រកាន់យកអភិក្រម ផ្អែកលើសិទ្ធិចំពោះការអភិវឌ្ឍ ដែលមានសង្គតិភាពជាមួយការអនុវត្តបច្ចុប្បន្នរបស់រាជរដ្ឋាភិបាលកម្ពុជា។ ចំណុចនេះអាចបង្កើតការបែងចែករវាងអង្គការសង្គមស៊ីវិលខុសៗគ្នា ដែលជាហេតុអាចប៉ះពាល់ដល់កិច្ចសហប្រតិបត្តិការក្នុងលក្ខណៈអវិជ្ជមាន។

---

[47] http://www.ccc-cambodia.org/ccc-program/voluntary-certification/applying-for-certification.html, accessed 20 November 2013

## វិធីសាស្ត្រ

ព័ត៌មានដែលបានពន្យល់នៅក្នុងជំពូកនេះ ត្រូវបានដកស្រង់ពីការសិក្សាឯកសារសំខាន់ៗ ការសម្ភាសន៍ជាមួយភាគីពាក់ព័ន្ធសំខាន់ៗដប់ពីរនាក់។ អ្នកផ្ដល់បទសម្ភាសន៍ រួមមានម្នាក់មកពីគ្រឹះស្ថានសិក្សា ប្រាំពីរនាក់មកពីអង្គការក្នុងស្រុក និងបួននាក់មកពីអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ។ ក្នុងចំណោមអង្គការក្នុងស្រុក អ្នកផ្ដល់បទសម្ភាសន៍ប្រាំនាក់មកពីអង្គការសមាជិកភាព និង/ឬ កំពុងផ្ដល់ការជួយគាំទ្រខាងលេខាធិការដ្ឋានជូនដល់សម្ព័ន្ធភាព និងបណ្ដាញនៃអង្គការមិនមែនរដ្ឋាភិបាល។ ព័ត៌មានដែលមានត្រូវបានសម្រិតសម្រាំង និងផ្ទៀងផ្ទាត់ជាមួយនឹងភស្តុតាងពីនេះពីនោះដែលបានមកពីការសន្ទនាក្រៅផ្លូវការជាមួយតួអង្គសង្គមស៊ីវិល។

## សេចក្ដីសង្ខេបអំពីបញ្ហាប្រឈមសំខាន់ៗ

បញ្ហាប្រឈមសំខាន់ៗទាក់ទិននឹងកិច្ចសប្រតិបត្តិការនិងសម្ព័ន្ធភាព សង្គមស៊ីវិល រួមមាន៖

- កង្វះទំនុកចិត្តក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាល
- កិច្ចសហប្រតិបត្តិការមានកម្រិត ដែលភាគច្រើនដោះស្រាយបញ្ហាបច្ចេកទេស
- យន្តការមិនគ្រប់គ្រាន់សម្រាប់ការវាយតម្លៃលើសមិទ្ធកម្មការងារនៃក្រុមសមាជិកភាព
- យន្តការមិនគ្រប់គ្រាន់សម្រាប់ទទួល និងដោះស្រាយបណ្ដឹងពីសមាជិក
- កំសោយកិច្ចសហប្រតិបត្តិការសម្រាប់អន្តរវិស័យ
- ការគិតលើការប្រកួតប្រជែងលើបញ្ហាមូលនិធិក្នុងអង្គការមិនមែនរដ្ឋាភិបាល។

# សេចក្តីសន្និដ្ឋាន

របាយការណ៍នេះ ចងក្រងជាឯកសារដែលមានបញ្ហាប្រឈម ចំណុចខ្សោយ និងបញ្ហាសំខាន់ៗ ក្នុងទិដ្ឋភាពចំនួនប្រាំពីរនៃបរិយាកាសអំណោយផលសម្រាប់តួអង្គសង្គមនៅកម្ពុជា ដោយផ្តោតជាក់ស្តែងលើបញ្ហាប្រឈមនៅក្នុងក្របខណ្ឌគតិយុត្តិ បទបញ្ញត្តិ និងគោលនយោបាយ សម្រាប់តួអង្គសង្គម។ ទិដ្ឋភាពនៃបរិយាកាសអំណោយផលមួយចំនួន មានលក្ខណៈរឹងមាំជាងទិដ្ឋភាពផ្សេងដែលនៅក្នុងនោះ លទ្ធភាពទទួលធនធានប្រហែលជាមានលក្ខណៈអំណោយផលបំផុត និងឱកាសសម្រាប់សេរីភាពបញ្ចេញមតិ និងក្នុងកម្រិតតិចជាងមួយ សេរីភាពខាងការជួបប្រជុំ មានលក្ខណៈអំណោយផលតិចជាងគេបំផុត។

បញ្ហាប្រឈមសំខាន់ៗក្នុងបរិយាកាសអំណោយផល ភាគច្រើនទាក់ទិននឹងបញ្ហានៃការបកស្រាយ ការអនុវត្ត ឬការប្រតិបត្តិច្បាប់។ បញ្ហាប្រឈមបន្ថែមគឺមានក្នុងក្របខ័ណ្ឌគតិយុត្តិ ហើយប្រហែលជាសំខាន់បំផុត ជាមួយនឹងបញ្ហាពាក់ព័ន្ធលើការយល់ ទំនុកចិត្ត និងកិច្ចសហប្រតិបត្តិការ។ ផែនការសកម្មភាពដោយឡែកមួយ រួមមានអនុសាសន៍អំពីរបៀបដែលបញ្ហាប្រឈមសំខាន់ៗអាចត្រូវបានដោះស្រាយ។ ប្រការសំខាន់បំផុតចំពោះការងារបន្ថែមក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនេះ គឺចាំបាច់ត្រូវជំរុញការយល់និងទំនុកចិត្តទៅវិញទៅមករវាងតួអង្គសង្គមស៊ីវិល និងរាជរដ្ឋាភិបាល។ ការសន្ទនាពិតប្រាកដគឺជាមូលដ្ឋានគ្រឹះសម្រាប់កសាងការយល់ដឹង និងទំនុកចិត្ត។ ការសន្ទនា ក្នុងន័យនេះ គឺជាការសន្ទនាមួយដែលមានគោលដៅច្បាស់លាស់និងប្រកបដោយចេតនា គឺជាលំហសមរម និងសមភាព ដែលនៅក្នុងនោះ អ្នកដែលមានគំនិតខុសគ្នាអាចស្តាប់ និងនិយាយរួមគ្នា។ ក្នុងការសន្ទនា អ្នកចូលរួមត្រូវបានគាំទ្រមិនឲ្យមានការភ័យខ្លាច បុរេនិច្ឆ័យ សេចក្តីត្រូវការសម្រាប់ទទួលជោគជ័យ និងចំណាយពេល ដើម្បីស្តាប់សម្លេង និងលទ្ធភាពដទៃ។ ម្យ៉ាងទៀត កិច្ចដំណើរការពហុភាគីពាក់ព័ន្ធ ដែលឱបក្រសោបតួអង្គសង្គមស៊ីវិល តួអង្គនយោបាយ តំណាងរាជរដ្ឋាភិបាល បុគ្គលផ្នែកឯកជន គឺមានលក្ខណៈសំខាន់ចាំបាច់នៅពេលកំណត់ការវាយតម្លៃ និងកែលម្អបរិយាកាសអំណោយផលសម្រាប់តួអង្គសង្គម។ ចំណុចសំខាន់ចំពោះការសន្ទនានេះ គឺការសន្មត់ថាការកែលម្អបរិយាកាសនេះ គឺជាការទទួលខុសត្រូវរួមរបស់តួអង្គរដ្ឋផង និងមិនមែនរដ្ឋផង ទោះបីជាមានបញ្ហាប្រឈម និងបញ្ហាទាំងឡាយដែលត្រូវបានពិពណ៌នាក្នុងឯកសារនេះក្តី ក៏គេឃើញមានចំណុចច្រើនដែលមានលក្ខណៈវិជ្ជមាន និងអាចពង្រឹងបាន។ ភាពជាដៃគូនិងកិច្ចសហការពិតប្រាកដ រវាងតួអង្គសង្គមស៊ីវិល និងតួអង្គរដ្ឋ គឺជាលក្ខខ័ណ្ឌមុនចាំបាច់មួយសម្រាប់ឲ្យសង្គមកាន់តែមានសន្តិភាព និងប្រជាធិបតេយ្យ រីកលូតលាស់នៅកម្ពុជា។

ជារួម លំហប្រជាធិបតេយ្យដែលមានសម្រាប់សង្គមស៊ីវិលនៅកម្ពុជា គឺមានលក្ខណៈតូច នឹងអាចកាន់តែរួញតូចថែមទៀតក្នុងបណ្តាឆ្នាំខាងមុខ។ ផ្ទុយទៅវិញ គេឃើញមានឱកាសមួយសម្រាប់ពង្រីកលំហដែលមានសម្រាប់តួអង្គសង្គម។ ដើម្បីពន្យល់:

ចំពោះលំហាថយចុះ ការចុះហត្ថលេខាសេចក្តីប្រកាសអាស៊ានស្តីពីសិទ្ធិមនុស្ស នៅរាជធានីភ្នំពេញ ក្នុងខែវិច្ឆិកា ឆ្នាំ២០១២ ទំនងគឺជាសញ្ញាណនៃអភិក្រមថ្មីរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះសិទ្ធិមនុស្ស។ ពាក្យពេចន៍មិនច្បាស់នៃសេចក្តីប្រកាសនេះ ផ្តល់លទ្ធភាពឲ្យរដ្ឋាភិបាលអាស៊ានអត់ឱនដល់ការបំពានធ្ងន់ធ្ងរលើសិទ្ធិមនុស្ស ដោយសំអាងលើមូលហេតុនៃ "លក្ខណៈពិសេសនៃប្រទេសជាតិ" ឬ "សារតាវប្បធម៌"។ ការរឹតត្បិតលើការអនុវត្តសិទ្ធិអាចកើតឡើងដើម្បីផលប្រយោជន៍នៃ "សន្តិសុខជាតិ" និង "សីលធម៌សាធារណៈ"។

ច្បាប់មួយស្តីពីអង្គការមិនមែនរដ្ឋាភិបាលនិងសមាគម ក៏ត្រូវបានស្នើឡើង។ សេចក្តីព្រាងទីបួននៃច្បាប់នេះ ត្រូវបានផ្សព្វផ្សាយក្នុងខែធ្នូ ឆ្នាំ ២០១១ ហើយរាជរដ្ឋាភិបាលកម្ពុជាបានលើកឡើងថាច្បាប់នេះនឹងត្រូវបានអនុវត្តក្នុងអាណត្តិទីប្រាំរបស់រាជរដ្ឋាភិបាល។ អង្គការសង្គមស៊ីវិលភាគច្រើនចាត់ទុកថាសំណើច្បាប់ថ្មីស្តីពីអង្គការមិនមែនរដ្ឋាភិបាលនិងសមាគម នឹងបង្កើនតួនាទីរបស់រាជរដ្ឋាភិបាលក្នុងការត្រួតពិនិត្យលើអង្គការសង្គមស៊ីវិល និងផ្តល់អំណាចដល់ស្ថាប័នរាជរដ្ឋាភិបាល ដើម្បីត្រួតត្រាដោយមិនចាំបាច់លើអង្គការសង្គមស៊ីវិល ដែលធ្វើអោយរួញលើលំហប្រជាធិបតេយ្យសម្រាប់សង្គមស៊ីវិល។

កង្វះប្រព័ន្ធតុលាការរឹងមាំ មានសមត្ថភាព និង ឯករាជ្យ គួបផ្សំនឹងការគោរពវិធានច្បាប់មិនគ្រប់គ្រាន់នៅកម្ពុជា ក៏គឺជាឧបសគ្គចម្បងផងដែរលើការងាររបស់តួអង្គសង្គមស៊ីវិល ជាពិសេស ជុំវិញកិច្ចប្រឹងប្រែងរបស់ពួកគេ ដើម្បីធានានូវសិទ្ធិនិងសេរីភាពជាមូលដ្ឋានសម្រាប់ប្រជាពលរដ្ឋកម្ពុជា។

ទោះបីជាមានសញ្ញាគួរឲ្យបារម្ភទាំងនេះក្តី ក៏គេឃើញមានសញ្ញាវិជ្ជមានខ្លះដែរ។ ការបោះឆ្នោតជាតិថ្មីៗនៅខែកក្កដា ឆ្នាំ២០១៣ អាចជួយជំរុញការពាក់ព័ន្ធក្នុងលក្ខណៈស្ថាបនាថែមទៀតរវាងរាជរដ្ឋាភិបាលនិងសង្គមស៊ីវិល ដូចដែលអ្នកផ្តល់បទសម្ភាសន៍មួយចំនួនបានព្យាករ។ ទោះបីជាផលប៉ះពាល់នៃការបោះឆ្នោតថ្មីៗលើអាកប្បកិរិយា របស់រាជរដ្ឋាភិបាលចំពោះសង្គមស៊ីវិលនៅមិនទាន់ត្រូវបានកំណត់យ៉ាងពេញលេញក្តី ក៏តួអង្គសង្គមស៊ីវិលមួយចំនួនមានសង្ឃឹមថាមហាបាតុកម្មសាធារណៈ ដែលរៀបចំដោយអង្គការសង្គមស៊ីវិលនឹងធ្វើឲ្យគណបក្សនយោបាយទាំងអស់កាន់តែគោរព វាយតម្លៃខ្ពស់ និងយោគយល់ដល់ទស្សនៈខុសគ្នា។ គេឃើញមានសង្ឃឹមថាអ្នកនយោបាយនិងមន្ត្រីរាជរដ្ឋាភិបាល នឹងចាត់ទុកថាសេរីភាពបញ្ចេញមតិ សេរីភាពក្នុងការនិយាយ និងសេរីភាពខាងការជួបប្រជុំ គឺជាសមាសភាគចាំបាច់នៃសង្គមប្រជាធិបតេយ្យល្អមួយ។ អាស្រ័យហេតុនេះ ពួកគេនឹងប្រាស្រ័យទាក់ទងក្នុងលក្ខណៈកាន់តែវិជ្ជមានជាមួយសង្គមស៊ីវិល ជារួម។ អ្នកផ្តល់បទសម្ភាសន៍ខ្លះបានលើកឡើងថាពួកគេបានមើលឃើញរួចហើយនូវការផ្លាស់ប្តូរជាវិជ្ជមានក្នុងរបៀប ដែលតួអង្គរាជរដ្ឋាភិបាលកំពុងពាក់ព័ន្ធជាមួយអង្គការសង្គមស៊ីវិល។ ប៉ុន្តែ ទិសដៅដែលប្រកាន់យកដោយរាជរដ្ឋាភិបាលដើម្បីកែលម្អ ឬ រឹតត្បិតបន្ថែមទៀតលើបរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិលនៅកម្ពុជា ត្រូវរង់ចាំមើលសិន៕

# ឧបសម្ព័ន្ធ ១: ការពិភាគបទសម្ភាសន៍

សូមអរគុណដែលចំណាយពេលវេលាដ៏មានតម្លៃក្នុងការជួយពន្យល់យើងខ្ញុំ ឲ្យយល់កាន់តែច្បាស់អំពីបរិយាកាសអំណោយផលសម្រាប់សង្គមស៊ីវិលក្នុងប្រទេសកម្ពុជា។

បទសម្ភាសនេះនឹងមានរយៈពេលមួយម៉ោង។ យើងកំពុងស្វែងយល់ពីវិស័យខុសៗគ្នាទាំងប្រាំពីរនៃបរិយាសកាសសង្គមស៊ីវិល ដូចជា ១. ការបង្កើតអង្គការសង្គមស៊ីវិល ២. ប្រតិបត្តិការ ៣. ការទទួលបានធនធាន ៤. ការបញ្ចេញមតិ ៥. ការជួបប្រជុំដោយសន្តិវិធី ៦. ទំនាក់ទំនងរវាងរដ្ឋាភិបាល និងសង្គមស៊ីវិល ៧. កិច្ចសហប្រតិបត្តិការ និងសម្ព័ន្ធរបស់អង្គការសង្គមស៊ីវិល។ ខ្ញុំគិតថា ប្រសិនបើខ្ញុំធ្វើបទសម្ភាសអំពីវិស័យទាំងប្រាំពីរ នឹងត្រូវចំណាយពេលយូរ ដូច្នេះ ខ្ញុំនឹងសម្ភាសន៍ទាក់ទងតែវិស័យមួយប៉ុណ្ណោះ (ប្រាប់ពីវិស័យដែលត្រូវសម្ភាសន៍)។ សូមប្រាប់ខ្ញុំ ប្រសិនបើអ្នកចង់ផ្តល់ជាមតិយោបល់លើវិស័យដទៃទៀត។

មុននឹងចាប់ផ្តើម សូមអនុញ្ញាតឲ្យខ្ញុំពន្យល់ប្រាប់អំពីការសម្ងាត់នៃកិច្ចសម្ភាសន៍ជាមុនសិន។ ខ្ញុំនឹងថតសំឡេងនិយាយរបស់អ្នកទុកឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ ខ្ញុំនឹងរក្សាទុកកំណត់ត្រា និងយកកំណត់ត្រាទាំងនេះមកប្រើប្រាស់នៅពេលបន្ទាប់។ កំណត់ត្រាទាំងនេះមិនអនុញ្ញាតឲ្យអ្នកណាមើលបានក្រៅពីក្រុមការងារស្រាវជ្រាវ។ តើអ្នកយល់យ៉ាងដូចម្តេចដែរ?

សេចក្តីសង្ខេបអំពីគំនិត និងការយល់ឃើញរបស់អ្នកផ្តល់បទសម្ភាសន៍នឹងត្រូវប្រើប្រាស់ក្នុងរបាយការណ៍។ នៅពេលខ្លះ យើងនឹងលើកយកពាក្យសម្តីដែលគួរឲ្យចាប់អារម្មណ៍របស់អ្នកផ្តល់សម្ភាសន៍មកនិយាយ។ ប្រសិនបើពាក្យសម្តីរបស់អ្នកត្រូវបានលើកយកមកនិយាយ យើងធានាថាយើងនឹងមិនបង្ហាញអត្តសញ្ញាណរបស់អ្នកឡើយ។ តើអ្នកយល់យ៉ាងដូចម្តេចដែរ?

ជាចុងក្រោយ យើងសូមបញ្ចូលឈ្មោះរបស់អ្នកទៅក្នុងឧបសម្ព័ន្ធសម្រាប់បញ្ជាក់ការចូលរួមរបស់អ្នកក្នុងបទសម្ភាសន៍។ តើពេញចិត្តឲ្យខ្ញុំចុះឈ្មោះរបស់អ្នកក្នុងនាមជាអ្នកផ្តល់សម្ភាសន៍ក្នុងឧបសម្ព័ន្ធនៃរបាយការណ៍ដែរឬទេ? (ថតសំឡេងនៃចម្លើយ ៖ ពេញចិត្ត/មិនពេញចិត្ត)

តើអ្នកមានចម្ងល់អ្វីមុននឹងចាប់ផ្តើមបទសម្ភាសន៍ដែរឬទេ?

## ការបង្កើតអង្គការសង្គមស៊ីវិល

ខ្ញុំមានសំណួរមួយចំនួនអំពីការបង្កើត និងចុះឈ្មោះអង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជា។

1. ខ្ញុំបានផ្ញើជូនអ្នកនូវព័ត៌មានមួយចំនួនដែលបានរៀបចំសម្រាប់កិច្ចសម្ភាសន៍នេះ។ តើអ្នកបានអានទំព័រនេះដែរឬទេ? តើអ្នកគិតថាខ្ញុំបានបញ្ចូលបញ្ហាបានគ្រប់គ្រាន់ដែរឬទេ? តើខ្ញុំអាចកែលម្អគុណភាពព័ត៌មាននេះយ៉ាងដូចម្តេច?
2. តើអ្នកមានភាពងាយស្រួលដែរឬទេក្នុងការចុះឈ្មោះអង្គការក្នុងបញ្ជី? ឧទាហរណ៍ តើអ្នកមានភាពងាយស្រួលក្នុងការទៅក្រសួងមហាផ្ទៃ ដើម្បីចុះឈ្មោះក្នុងបញ្ជីដែរឬទេ?
3. តើអ្នកជួបប្រទះឧបសគ្គ ឬ ការលំបាកអ្វីក្នុងការចុះឈ្មោះដែរឬទេ? ឧទាហរណ៍ ការចុះបញ្ជីមានភាពយឺតយ៉ាវ ឬមិនមានប្រសិទ្ធភាព មិនមានលទ្ធភាពទទួលបានមូលនិធិ ឬភាពលំបាកក្នុងទិញ/ជួលទ្រព្យសម្បត្តិ។
4. តើអ្នកចំណាយប្រាក់ប៉ុន្មានសម្រាប់ការចុះឈ្មោះអង្គការរបស់អ្នក? តើប្រាក់ទាំងនេះ ចំណាយលើអ្វីខ្លះ? តើចំណាយទាំងនេះជាចំណាយផ្លូវការ ឬ ក្រៅផ្លូវការ?
5. តើអំពើពុករលួយក្នុងដំណើរការចុះឈ្មោះមានត្រឹមកម្រិតណាដែរ?
6. តើអ្នកដឹងទេថា ការសម្រេចចិត្តលើការចុះឈ្មោះក្នុងបញ្ជីអាចប្តឹងតវ៉ាបាន? តើអ្នកធ្លាប់ដឹងពីការប្តឹងតវ៉ាលើការសម្រេចចិត្តលើការចុះឈ្មោះដែរឬទេ? តើមានអ្វីកើតឡើងខ្លះ?
7. តើអ្នកធ្លាប់បានធ្វើការចុះឈ្មោះសារថ្មីដែរឬទេ?
8. តាមទស្សនៈរបស់អ្នក តើស្ថាប័នរដ្ឋាភិបាល (ក្រសួងមហាផ្ទៃ) ដែលទទួលខុសត្រូវលើការចុះឈ្មោះអង្គការសង្គមស៊ីវិលមានមូលនិធិ និងបុគ្គលិកគ្រប់គ្រាន់សម្រាប់បំពេញតួនាទីនេះដែរឬទេ?
9. តើអ្នកបានដឹងថា មានអង្គការណាផ្សេងធ្វើការចុះឈ្មោះបានលឿន ឬ យឺតជាងអង្គការរបស់អ្នកដែរឬទេ? តើអ្នកគិតយ៉ាងដូចម្តេចដែរចំពោះបញ្ហានេះ?
10. តើអ្នកមានអ្វីជាមតិយោបល់បន្ថែមទៀតដែរឬទេ?

**សូមអរគុណ !**

## ប្រតិបត្តិការ

ខ្ញុំមានសំណួរមួយចំនួនអំពីប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជា។

1. ខ្ញុំបានផ្ញើជូនអ្នកនូវព័ត៌មានមួយចំនួនដែលបានរៀបចំសម្រាប់កិច្ចសម្ភាសន៍នេះ។ តើអ្នកបានអានទំព័រនេះដែរឬទេ? តើអ្នកគិតថាខ្ញុំបានបញ្ចូលបញ្ហាបានគ្រប់គ្រាន់ដែរឬទេ? តើខ្ញុំអាចកែលម្អគុណភាពព័តមាននេះយ៉ាងដូចម្តេច?

2. រាជរដ្ឋាភិបាលកម្ពុជាទាមទារឲ្យអង្គការសង្គមស៊ីវិលជូនដំណឹងអំពីការប្រជុំមួយចំនួនដល់រដ្ឋាភិបាល។ តើការប្រជុំអ្វីខ្លះដែលអ្នកជូនដំណឹងទៅកាន់រដ្ឋាភិបាល? តើអ្នកជូនដំណឹងគប់ការប្រជុំ ឬ តែការប្រជុំសំខាន់ៗប៉ុណ្ណោះ? ប្រសិនបើអ្នកជូនដំណឹងតែការប្រជុំសំខាន់ៗ តើអ្នកកំណត់ថាការប្រជុំបែបណាសំខាន់ដែលត្រូវជូនដំណឹង?
3. តើអ្នករាយការណ៍អំពីបញ្ជីឈ្មោះបេក្ខជននៃក្រុមប្រឹក្សាភិបាល ឬ លទ្ធផលនៃការជ្រើសរើសក្រុមប្រឹក្សាភិបាលជូនដល់រដ្ឋាភិបាលដែរឬទេ?
4. តើអ្នកដាក់របាយការណ៍ចុងក្រោយជូនរដ្ឋាភិបាលនៅពេលណា? តើរបាយការណ៍នោះជារបាយការណ៍ប្រភេទអ្វី? ឧទាហរណ៍ របាយការណ៍សកម្មភាព ឬហិរញ្ញវត្ថុ?
5. តើមានអ្វីកើតឡើងចំពោះអ្នក ប្រសិនបើអ្នកមិនបានបំពេញតាមកាតព្វកិច្ចផ្លូវច្បាប់ពាក់ព័ន្ធ? តើមានអ្វីកើតឡើងដែរឬទេ?
6. តើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ធ្លាប់ត្រូវបានរដ្ឋាភិបាលធ្វើសវនកម្ម ឬ ធ្វើអធិការកិច្ចដែរឬទេ? សូមប្រាប់ពីអ្វីដែលកើតឡើង។ (ឧទាហរណ៍ នៅពេលមានការធ្វើសវនកម្ម ឬ អធិការកិច្ច តើមាននរណាខ្លះចូលរួម តើមានអ្នកពិនិត្យតាមដានដែរឬទេ? តើគេធ្វើអធិការកិច្ចទៅលើអ្វីឲ្យជាក់លាក់?)
7. តើមានលក្ខខ័ណ្ឌផ្នែករដ្ឋបាលណាផ្សេងទៀតដែលប៉ះពាល់ដល់ប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជាដែរឬទេ?
8. តើអ្នកបានដឹងពីករណីណាមួយដែលរដ្ឋាភិបាលបញ្ឈប់ ឬ រំលាយអង្គការសង្គមស៊ីវិលមួយដោយស្របច្បាប់ដែរឬទេ? តើមានអ្វីកើតឡើង? តើអង្គការសង្គមស៊ីវិលនោះមានឱកាសប្ដឹងតវ៉ាដែរឬទេ? តើក្នុងភាពជាក់ស្ដែង រដ្ឋាភិបាលបានប្រើប្រាស់មូលដ្ឋានមិនស្របច្បាប់ ដើម្បីបញ្ឈប់ ឬ រំលាយអង្គការសង្គមស៊ីវិលដែរឬទេ? ក្នុងភាពជាក់ស្ដែង តើការបញ្ឈប់ ឬ រំលាយបែបនេះកើតឡើងយ៉ាងដូចម្ដេច បើយោងតាមច្បាប់ ឬ ក្នុងករណីណាផ្សេងទៀត?
9. តើអ្នកដឹងពីមូលដ្ឋានច្បាប់ណាដែលអង្គការសង្គមស៊ីវិលអាចរំលាយខ្លួនឯងដោយស្ម័គ្រចិត្តដែរឬទេ? សូមពន្យល់ប្រាប់ការយល់ដឹងរបស់អ្នក។
10. ជាទូទៅ តើអ្នកយល់ឃើញថា រដ្ឋាភិបាលគួរមានការត្រួតពិនិត្យលើអង្គការសង្គមស៊ីវិលត្រឹមកម្រិតណា? យកចិត្តទុកដាក់ខ្លាំង មធ្យម តិចតួច?
11. តាមរយៈបទពិសោធន៍របស់អ្នក តើអ្វីខ្លះជាឧបសគ្គផ្លូវច្បាប់ និងរដ្ឋបាលសំខាន់ៗចំពោះប្រតិបត្តិការប្រកបដោយផលិតភាពរបស់អង្គការសង្គមស៊ីវិល?
12. តើអ្នកបានដឹងពីករណី ឬ ហេតុការណ៍ណាមួយទាក់ទងនឹងការកៀបសង្កត់របស់រដ្ឋាភិបាលលើអង្គការសង្គមស៊ីវិល នៅពេលអង្គការមិនអនុវត្តតាមលក្ខខ័ណ្ឌរដ្ឋបាល និង/ឬ លក្ខខ័ណ្ឌច្បាប់ដែរឬទេ? (ឬតើករណីការកៀបសង្កត់របស់រដ្ឋាភិបាលលើអង្គការសង្គមស៊ីវិលគួរតែមានការយល់ដឹងបន្ថែម ពីព្រោះភាគច្រើនករណីនេះមិនពាក់ព័ន្ធនឹងលក្ខខ័ណ្ឌរដ្ឋបាល និងច្បាប់?)
13. តើអ្នកមានអ្វីជាមតិយោបល់បន្ថែមទៀតដែរឬទេ?

**សូមអរគុណ!**

## លទ្ធភាពទទួលបានធនធាន

ខ្ញុំមានសំណួរមួយចំនួន អំពីលទ្ធភាពរបស់អង្គការសង្គមស៊ីវិល ក្នុងការទទួលបានធនធាន ដូចជា មូលនិធិបរទេស មូលនិធិក្នុងស្រុក ជំនួយឥតសំណង អំណោយ ចំណូលរបស់អង្គការតាមរយៈ ការលក់ និងវត្ថុបណ្តុះបណ្តាល ។ល។

1. ខ្ញុំបានផ្ញើជូនអ្នកនូវព័ត៌មានមួយចំនួនដែលបានរៀបចំសម្រាប់កិច្ចសម្ភាសន៍នេះ។ តើអ្នកបាន អានទំព័រនេះដែរឬទេ? តើអ្នកគិតថាខ្ញុំបានបញ្ចូលបញ្ហាបានគ្រប់គ្រាន់ដែរឬទេ? តើខ្ញុំអាច កែលម្អគុណភាពព័តមាននេះយ៉ាងដូចម្តេច?
2. តើអ្វីខ្លះជាឧបសគ្គផ្លូវច្បាប់របស់អង្គការសង្គមស៊ីវិលក្នុងការទទួលបានធនធានពីប្រភព ហិរញ្ញប្បទាន?
3. តើអ្វីខ្លះជាឧបសគ្គរបស់អង្គការសង្គមស៊ីវិលក្រៅពីឧបសគ្គផ្លូវច្បាប់ និងឧបសគ្គពីរដ្ឋាភិបាល ក្នុងការទទួលបានធនធានពីប្រភពហិរញ្ញប្បទាន?
4. តើអ្នកដឹងថាច្បាប់ និង/ឬ បទប្បញ្ញត្តិអ្វីដែលមិនអនុញ្ញាតឲ្យអង្គការសង្គមស៊ីវិលបែងចែកប្រាក់ ចំណេញ ឬផលប្រយោជន៍ឯកជនទៅឲ្យមន្ត្រី ប្រធាន ឬអ្នកដឹងព័ត៌មានផ្ទៃក្នុងនៃអង្គការ? (ខ្ញុំ គិតថា ការហាមប្រាមនេះចែងក្នុងក្រមរដ្ឋប្បវេណី ប៉ុន្តែខ្ញុំមិនទាន់រកឃើញនៅឡើយ។)
5. ប្រសិនបើអង្គការ (សង្គមស៊ីវិល) របស់អ្នកត្រូវបានរំលាយ តើទ្រព្យសម្បត្តិរបស់អង្គការត្រូវ រៀបចំយ៉ាងដូចម្តេច? តើច្បាប់ និង/ឬ បទប្បញ្ញត្តិណាដែលចែងអំពីការបែងចែកទ្រព្យសម្បត្តិ បន្ទាប់ពីការរំលាយអង្គការ? (ក្រមរដ្ឋប្បវេណី) តើបទប្បញ្ញត្តិទាំងនេះមានឥទ្ធិពលដូចម្តេច ចំពោះអ្នក?
6. តើទំនុកចិត្តនៃលទ្ធភាពទទួលបានមូលនិធិស្របច្បាប់របស់អង្គការ (សង្គមស៊ីវិល) របស់អ្នក និងអង្គការដទៃទៀតមានកម្រិតណាដែរ? តើការអាចរកបានមូលនិធិស្របច្បាប់ទាំងនេះ ដោយសេរីមានកម្រិតណាដែរ?
7. តើនិរន្តរភាពហិរញ្ញវត្ថុរបស់អង្គការសង្គមស៊ីវិលពឹងផ្អែកលើការត្រួតពិនិត្យ និងឯកភាពពី រដ្ឋាភិបាលកម្រិតណាដែរ?
8. តើក្របខណ្ឌច្បាប់ និងគោលនយោបាយក្នុងប្រទេសកម្ពុជាផ្តល់ការគាំទ្រចំពោះការកៀរគរ ធនធានក្នុងស្រុកមានប្រសិទ្ធភាពកម្រិតណាដែរ?
9. តើរដ្ឋាភិបាល និងមូលនិធិរបស់អ្នកផ្តល់ជំនួយគាំទ្រគ្រប់កម្មវិធី និងសកម្មភាពរបស់អង្គការ សង្គមស៊ីវិល រួមទាំង ឧទាហរណ៍ នវានុវត្តន៍ ការបង្កើតគោលនយោបាយ និងការតស៊ូមតិដែរ ឬទេ? តើអង្គការរបស់អ្នកមានលទ្ធភាពទទួលបានមូលនិធិសម្រាប់ចំណាយរដ្ឋបាលសំខាន់ៗ ដែរឬទេ?
10. តើប្រភពមូលនិធិអ្វីដែលអង្គការសង្គមស៊ីវិលមានទំនុកចិត្តលើបំផុត?

11. តើអ្នកធ្លាប់បានដឹងពីការផ្លាស់ប្តូរថ្មីៗទាក់ទងនឹងបរិយាកាសហិរញ្ញប្បទានជាតិសម្រាប់អង្គការសង្គមស៊ីវិលដែរឬទេ?
12. តើអ្នកធ្លាប់បានទទួលជំនួយហិរញ្ញវត្ថុផ្ទាល់ពីរាជរដ្ឋាភិបាលកម្ពុជាដែរឬទេ? តាមការយល់ដឹងរបស់អ្នក តើការផ្តល់ហិរញ្ញប្បទានរបស់រដ្ឋាភិបាលធ្វើតាមទម្រង់បែបណា និងមានត្រឹមកម្រិតណា? ឧទាហរណ៍ កម្រិតជំនួយឥតសំណង ឬ ឧបត្ថម្ភធន? តើអ្នកដឹងអំពីគំរូកិច្ចសន្យារវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលដែរឬទេ?
13. តើអ្នកដឹងអំពីច្បាប់ វិធាន និងគោលនយោបាយសម្រាប់អង្គការសង្គមស៊ីវិលសុំជំនួយឥតសំណង និងឧបត្ថម្ភធនធានពីរដ្ឋាភិបាលដែរឬទេ? តើមានច្បាប់ វិធាន និងគោលនយោបាយមួយណា?
14. តើក្របខណ្ឌច្បាប់ក្នុងប្រទេសកម្ពុជាគាំទ្រដល់ហិរញ្ញប្បទានរបស់រដ្ឋាភិបាលសម្រាប់អង្គការសង្គមស៊ីវិលកម្រិតណាដែរ? តើមានឧបសគ្គផ្លូវច្បាប់ និងក្រៅផ្លូវច្បាប់អ្វីខ្លះដែលរារាំងដល់ការបង្កើនប្រសិទ្ធភាព ឬ តម្លាភាពបន្ថែមនៃកាជំនួយរបស់រដ្ឋាភិបាល?
15. តាមទស្សនៈអ្នក តើហិរញ្ញប្បទានរបស់រដ្ឋាភិបាលផ្តល់ឲ្យនៅពេលណា? តើហិរញ្ញប្បទាននេះអាចប៉ាន់ប្រមាណជាមុន មានតម្លាភាព ងាយស្រួលយល់ និងអព្យាក្រឹត្យដែរឬទេ?
16. តើជំនួយរបស់រដ្ឋាភិបាលសម្រាប់អង្គការសង្គមស៊ីវិលមានការកើនឡើង ឬ ធ្លាក់ចុះក្នុងរយៈពេលកន្លងមក? តើអ្នករំពឹងថាជំនួយនេះយ៉ាងដូចម្តេចដែរក្នុងពីរឆ្នាំបន្ទាប់ទៀត។
17. តើស្តង់ដារ/លក្ខខ័ណ្ឌទទួលបានប្រភពមូលនិធិពីបរទេស និងប្រភពមូលនិធិក្នុងតំបន់ ឬ ក្នុងស្រុកមានលក្ខណៈខុសគ្នាដែរឬទេ?
18. តើអង្គការសង្គមស៊ីវិលមានឧបសគ្គអ្វីខ្លះក្នុងការទទួលបាន និងការប្រើប្រាស់ធនធានបរទេស? ឧទាហរណ៍ តើមានលក្ខខ័ណ្ឌឲ្យធ្វើរបាយការណ៍បន្ថែមដែរឬទេ?
19. តើមានកិច្ចព្រមព្រៀងទ្វេភាគី ឬ ពហុភាគី ដែលប៉ះពាល់អ្នកផ្តល់ជំនួយបរទេសក្នុងការផ្តល់ជំនួយ និងបង្កើតភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិលដែរឬទេ? ប្រសិនបើមាន តើជាកិច្ចព្រមព្រៀងប្រភេទអ្វី? (ឧទាហរណ៍ សេចក្តីថ្លែងការណ៍អំពីការប្តេជ្ញាចិត្តរយៈពេលមធ្យមទៅរយៈពេលវែងលើទំនាក់ទំនង ក្របខណ្ឌហិរញ្ញប្បទាន ។ល។)
20. តើក្នុងភាពជាក់ស្តែងមានឧបសគ្គក្រៅផ្លូវច្បាប់អ្វីខ្លះក្នុងការទទួលបានមូលនិធិបរទេស?
21. តើលក្ខណៈទូទៅនៃអភិបាលកិច្ច និងនីតិរដ្ឋនៅកម្ពុជាប៉ះពាល់លើការចូលរួមវិភាគទានរបស់អ្នកផ្តល់ជំនួយដល់អង្គការសង្គមស៊ីវិលដែរឬទេ? ប្រសិនបើមាន តើមានការប៉ះពាល់ដូចម្តេច?

សំណួរបន្ទាប់ទៀតទាក់ទងនឹងជំនួយសប្បុរសធម៌ មានន័យថា អំណោយរបស់បុគ្គលឯកជន ឬក្រុមហ៊ុនជូនដល់អង្គការសង្គមស៊ីវិល។

22. តើមានច្បាប់ និង/ឬ បទប្បញ្ញត្តិអ្វីខ្លះ ដែលចែងជាក់លាក់ទាក់ទងនឹងជំនួយសប្បុរសធម៌?
23. តើអង្គការសង្គមស៊ីវិលអនុញ្ញាតឲ្យយកអំណោយ និងបរិច្ចាគពីក្រុមហ៊ុន និងបុគ្គលឯកជនដែរឬទេ?
24. តើក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិលើកទឹកចិត្តចំពោះការផ្តល់ជំនួយសប្បុរសធម៌ដែរឬទេ? ប្រសិនបើមាន ឬ គ្មាន តើការលើកទឹកចិត្តមានលក្ខណៈបែបណា?
25. តាមការយល់ឃើញរបស់អ្នក តើកត្តាអ្វីដែលលើកទឹកចិត្តដល់ការផ្តល់ជំនួយមនុស្សធម៌ក្នុងប្រទេសកម្ពុជា?
26. តើអង្គការសង្គមស៊ីវិលសាកល្បងកៀរគរមូលនិធិជាទៀងទាត់ពីប្រជាជន និងក្រុមហ៊ុនក្នុងស្រុកដែរឬទេ?
27. ជាចុងក្រោយ តើអង្គការសង្គមស៊ីវិលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការកៀរគរមូលនិធិដែរឬទេ? ឬសមត្ថភាពក្នុងការបង្កើនមូលនិធិដែរឬទេ?

**សូមអរគុណ!**

## ការបញ្ចេញមតិ

ខ្ញុំមានសំណួរមួយចំនួនអំពី សមត្ថភាពរបស់អង្គការសង្គមស៊ីវិលក្នុងការបញ្ចេញមតិ។

1. ខ្ញុំបានផ្ញើជូនអ្នកនូវព័ត៌មានមួយចំនួនដែលបានរៀបចំសម្រាប់កិច្ចសម្ភាសន៍នេះ។ តើអ្នកបានអានទំព័រនេះដែរឬទេ? តើអ្នកគិតថាខ្ញុំបានបញ្ចូលបញ្ហាបានគ្រប់គ្រាន់ដែរឬទេ? តើខ្ញុំអាចកែលម្អគុណភាពព័តមាននេះយ៉ាងដូចម្តេច?
2. តើមានច្បាប់អ្វីដែលចែងពីសិទ្ធិរបស់អង្គការសង្គមស៊ីវិលក្នុងការបញ្ចេញមតិដោយសេរី?
3. តើអ្នកដឹងថាសន្ធិសញ្ញាអន្តរជាតិមួយណាចែងពីសិទ្ធិរបស់អង្គការសង្គមស៊ីវិលក្នុងការបញ្ចេញមតិជាសាធារណៈដែលត្រូវបានប្រទេសកម្ពុជាផ្តល់សច្ចាប័ន? តើអ្នកដឹងថា សន្ធិសញ្ញាទទួលបានសច្ចាប័នមួយណាដែលមានការរឹតត្បិតសិទ្ធិក្នុងការប្រើប្រាស់អ៊ីនធឺណេត?
4. តើច្បាប់ និង/ឬ បទប្បញ្ញត្តិអ្វីខ្លះក្នុងប្រទេសកម្ពុជាដែលរឹតត្បិតសិទ្ធិក្នុងការនិយាយ? តើការរឹតត្បិតទាំងនោះមានអ្វីខ្លះ? (ឧទាហរណ៍ ការរឹតត្បិតលើសន្តិសុខជាតិ ការបរិហារកេរ្តិ៍ ការញុះញង់ ការប្រើពាក្យសម្តីអាសអាភាស ការនិយាយប៉ះពាល់ដល់ព្រះមហាក្សត្រ ។ល។)?
5. តើមានការរឹតត្បិតលើពេលវេលា ទីកន្លែង និងវិធីក្នុងការបញ្ចេញមតិរបស់យើងដែរឬទេ? តើការរឹតត្បិតទាំងនោះមានអ្វីខ្លះ?
6. តើមានឧបសគ្គផ្លូវច្បាប់អ្វីខ្លះដែលរារាំងដល់សិទ្ធិរបស់អង្គការសង្គមស៊ីវិលក្នុងបញ្ចេញមតិជាសាធារណៈ ជាពិសេស មតិទាក់ទងនឹងបញ្ហាសំខាន់នៃគោលនយោបាយរដ្ឋាភិបាល?
7. តើមានសេចក្តីព្រាងច្បាប់ ឬ បទប្បញ្ញត្តិណាខ្លះ (ប្រសិនបើត្រូវបានអនុម័ត) ដែលនឹងរឹតត្បិតឬផ្តល់ភាពងាយស្រួលដល់អង្គការសង្គមស៊ីវិលក្នុងការផ្តល់សេរីភាពបញ្ចេញមតិ? ប្រសិនបើមាន តើអ្នកអាចរៀបរាប់សង្ខេបពីអ្វីដែលយល់អំពីបទប្បញ្ញត្តិសំខាន់ៗនៃច្បាប់ថ្មីនេះ និងពន្យល់ប្រាប់ថាតើច្បាប់ថ្មីនេះកំពុងស្ថិតក្នុងដំណាក់កាលណានៃដំណើរការផ្លូវច្បាប់?
8. តើមានឧបសគ្គក្រៅផ្លូវច្បាប់ណាខ្លះដែលរារាំងសិទ្ធិអង្គការសង្គមស៊ីវិលក្នុងការបញ្ចេញមតិជាសាធារណៈ?
9. តើមានការអនុញ្ញាតឲ្យរិះគន់ជាសាធារណៈអំពីគោលនយោបាយ និងការអនុវត្តរបស់រដ្ឋាភិបាលដែរឬទេ? តើរដ្ឋាភិបាលមានប្រតិកម្មចំពោះការរិះគន់ដូចម្តេចខ្លះនាពេលកន្លងមក?
10. តើបុគ្គល និងអង្គការសង្គមស៊ីវិល យល់ដឹងពីសិទ្ធិរបស់ខ្លួនទាក់ទងនឹងការបញ្ចេញមតិដែរឬទេ? តើវប្បធម៌នយោបាយក្នុងប្រទេសកម្ពុជាគាំទ្រលើសិទ្ធិទាំងនេះដោយបើកចំហដែរឬទេ? ឬ សិទ្ធិទាំងនេះត្រូវបានរឹតត្បិតយ៉ាងខ្លាំងទោះបីជាមានការការពារផ្លូវច្បាប់ក៏ដោយ?
11. តើអ្នកមានអ្វីជាមតិយោបល់បន្ថែមទៀតដែរឬទេ?

**សូមអរគុណ!**

## ការជួបប្រជុំដោយសន្តិវិធី

ឥឡូវ ខ្ញុំមានសំណួរមួយចំនួនអំពីសង្គមស៊ីវិល និងសិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី។

1. ខ្ញុំបានផ្ញើជូនអ្នកនូវព័ត៌មានមួយចំនួនដែលបានរៀបចំសម្រាប់កិច្ចសម្ភាសន៍នេះ។ តើអ្នកបានអានទំព័រនេះដែរឬទេ? តើអ្នកគិតថាខ្ញុំបានបញ្ចូលបញ្ហាបានគ្រប់គ្រាន់ដែរឬទេ? តើខ្ញុំអាចកែលម្អគុណភាពព័តមាននេះយ៉ាងដូចម្តេច?
2. ក្រៅពីច្បាប់ស្តីពីការជួបប្រជុំដោយសន្តិវិធី តើមានច្បាប់អ្វីផ្សេងទៀតដែលចែងពីសិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី រួមទាំង បទប្បញ្ញត្តិក្នុងស្រុក និងសន្ធិសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នដែរឬទេ?
3. តាមការយល់ឃើញរបស់អ្នក តើមានការដាក់កម្រិតលើអ្នកដែលធ្វើការប្រជុំគ្នាដែរឬទេ? តើក្រុមដែលមានគោលនយោបាយ ឬ ទិសដៅជាក់លាក់ត្រូវបានហាមឃាត់មិនឲ្យប្រជុំគ្នាដែរឬទេ?
4. តើមានការដាក់កម្រិតលើទីន្លែង ពេលវេលា និងវិធីដែលបុគ្គល ឬ ក្រុមដែលធ្វើការប្រជុំគ្នាកូដកម្ម ការតវ៉ាប្រឆាំង ឬការបញ្ចេញមតិជាសាធារណៈ (និងដោយអហិង្សា) ដែរឬទេ?
5. តើការដោះស្រាយចំពោះបាតុករមានការរំលោភបំពាន ឬ អំពើហិង្សាដូចម្តេចដែរទាំងនៅក្នុងច្បាប់ និងភាពជាក់ស្តែង? តើអ្នកអាចផ្តល់ជាឧទាហរណ៍មួយចំនួនបានដែរឬទេ?
6. តើមានសេចក្តីព្រាងច្បាប់ ឬ បទប្បញ្ញត្តិដែល (ប្រសិនបើអនុម័ត) នឹងរឹតត្បិត ឬ ផ្តល់ភាពងាយស្រួលក្នុងការទទួលបានសិទ្ធិធ្វើការជួបប្រជុំដោយសន្តិវិធីដែរឬទេ? ប្រសិនបើមាន តើអ្នកអាចរៀបរាប់សង្ខេបពីអ្វីដែលអ្នកយល់អំពីសេចក្តីព្រាងច្បាប់នោះដែរឬទេ? តើសេចក្តីព្រាងនេះត្រូវការរយៈពេលប៉ុន្មាន ដើម្បីអនុម័តក្លាយជាច្បាប់?
7. តើកន្លងមកធ្លាប់មានអំពើហិង្សា ឬការរំលោភបំពានពីរដ្ឋាភិបាលលើបាតុករ សកម្មជន និង/ឬ បាតុករអហិង្សាដែរឬទេ? តើអ្នកអាចផ្តល់ឧទាហរណ៍មួយចំនួនបានដែរឬទេ?
8. ក្នុងភាពជាក់ស្តែង តើមានការអត់ធ្មត់ចំពោះក្រុមប្រជុំគ្នាធ្វើការរិះគន់រដ្ឋាភិបាលតាមរយៈការតវ៉ាប្រឆាំង កូដកម្ម ឬតាមរូបភាពជាបាតុកម្មអហិង្សាដែរឬទេ?
9. តើអ្នកមានអ្វីជាមតិយោបល់បន្ថែមទៀតដែរឬទេ?

**សូមអរគុណ!**

## ទំនាក់ទំនងរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល

ខ្ញុំមានសំណួរមួយចំនួនអំពីទំនាក់ទំនងរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជា។

1. ខ្ញុំបានផ្ញើជូនអ្នកនូវព័ត៌មានមួយចំនួនដែលបានរៀបចំសម្រាប់កិច្ចសម្ភាសន៍នេះ។ តើអ្នកបានអានទំព័រនេះដែរឬទេ? តើអ្នកគិតថាខ្ញុំបានបញ្ចូលបញ្ហាបានគ្រប់គ្រាន់ដែរឬទេ? តើខ្ញុំអាចកែលម្អគុណភាពព័តមាននេះយ៉ាងដូចម្តេច?
2. តើអង្គការសង្គមស៊ីវិលមានសិទ្ធិចូលរួមក្នុងដំណើរការ (បោះឆ្នោត) នយោបាយដែរឬទេ? ឧទាហរណ៍ តើអង្គការសង្គមស៊ីវិលអាចជ្រើសតាំងបេក្ខជន សម្រាប់បម្រើការងារក្នុងការិយាល័យសាធារណៈដែរឬទេ? តើអង្គការសង្គមស៊ីវិលមានអាចគាំទ្រ និងប្រឆាំងចំពោះគណបក្សនយោបាយដែរឬទេ? តើអង្គការសង្គមស៊ីវិលអាចកៀរគរមូលនិធិសម្រាប់គណបក្ស/បេក្ខជននយោបាយដែរឬទេ? ប្រសិនបើអាច តើស្ថិតក្រោមលក្ខខ័ណ្ឌណា?
3. តើអង្គការសង្គមស៊ីវិលមានសិទ្ធិចូលរួមក្នុងសកម្មភាពនយោបាយសាធារណៈដែរឬទេ? តើអង្គការសង្គមស៊ីវិលមានសិទ្ធិតស៊ូមតិ ធ្វើយុទ្ធនាការ និងបញ្ចុះបញ្ចូលក្នុងការតាក់តែងច្បាប់ដែរឬទេ? ប្រសិនបើមាន តើស្ថិតក្រោមលក្ខខ័ណ្ឌណា?
4. តើមានកិច្ចព្រមព្រៀងពិសេស ឬយន្តការស្រដៀងគ្នាណាខ្លះ ដែលលើកកម្ពស់កិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលដែរឬទេ? ដូចជាក្រុមការងារបច្ចេកទេស ការិយាល័យទំនាក់ទំនង គណៈកម្មាធិការ ។ល។
5. តើមានសេចក្តីព្រាងច្បាប់ ឬ បទប្បញ្ញត្តិដែល (ប្រសិនបើអនុម័ត) នឹងប៉ះពាល់ដល់ទំនាក់ទំនងរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលដែរឬទេ? តើអ្នកអាចប្រាប់ខ្ញុំអំពីសេចក្តីព្រាងទាំងនេះបានដែរឬទេ? តើអ្នកគិតថាសេចក្តីព្រាងទាំងនេះត្រូវការរយៈពេលប៉ុន្មាន ដើម្បីអនុម័តក្លាយជាច្បាប់?
6. ជាទូទៅ តើអ្នកយល់ថាទំនាក់ទំនងរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលមានលក្ខណៈដូចម្តេចដែរ? ជាទំនាក់ទំនងល្អឬមានវិវាទ ឬជាទំនាក់ទំនងស្ថិតក្នុងចន្លោះចំណុចទាំងពីរនេះ?
7. តើអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាលមានទំនាក់ទំនងជាមួយគ្នាទៀងទាត់ដែរឬទេ? តើកិច្ចសន្ទនារវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលមានគុណភាពដូចម្តេចដែរ?
8. តើមតិយោបល់របស់អង្គការសង្គមស៊ីវិលត្រូវបានយកចិត្តទុកដាក់ដែរឬទេ នៅពេលធ្វើសេចក្តីព្រាងច្បាប់ ឬយ៉ាងណា?
9. តើមានការប្រឹក្សាទាន់ពេលវេលាជាមួយអង្គការសង្គមស៊ីវិល ដែលអាចជួយអង្គការសង្គមស៊ីវិលឲ្យមានឥទ្ធិពលលើការសម្រេចចិត្តរបស់រដ្ឋាភិបាលដែរឬទេ?
10. នៅពេលរដ្ឋាភិបាលកំណត់អាទិភាព និងរៀបចំយុទ្ធសាស្ត្រ ផែនការ ។ល។ តើជាទូទៅមានតម្លាភាព និងគណនេយ្យភាពដែរឬទេ?

11. តើអង្គការសង្គមស៊ីវិលមានឱកាសមិនឯកភាព ឬ តវ៉ាលើការសម្រេចចិត្តមួយចំនួនរបស់រដ្ឋាភិបាលនៅថ្នាក់ជាតិ ឬខេត្តដែរឬទេ? តើអង្គការសង្គមស៊ីវិលមានវិធីសាស្ត្រដែលអាចទុកចិត្តបាន ឆ្លាតវៃ និងមានប្រសិទ្ធភាពក្នុងការប្រាប់ពីក្តីកង្វល់របស់ខ្លួន ដែរឬទេ? ក្នុងភាពជាក់ស្តែង តើអង្គការសង្គមស៊ីវិលពិតជាអាចមិនឯកភាព ឬ តវ៉ាដោយជោគជ័យ លើការសម្រេចចិត្តរបស់រដ្ឋាភិបាល ដើម្បីទទួលបានលទ្ធផលយុត្តិធម៌ដែរឬទេ?
12. តើរដ្ឋាភិបាលចាត់ទុកអង្គការសង្គមស៊ីវិលជាដៃគូ និងសម្ព័ន្ធមិត្តក្នុងការងារ ឬជាការគំរាមកំហែង? ឬចាត់ទុកទាំងពីរតែម្តង?
13. តើអង្គការសង្គមស៊ីវិលពិតជាអាចចូលរួមក្នុងគ្រប់គំនិតផ្តួចផ្តើម និងសកម្មភាពនយោបាយសាធារណៈបានដែរឬទេ?
14. តើមានការផ្លាស់ប្តូរសំខាន់ៗក្នុងទំនាក់ទំនងរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជាក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះដែរឬទេ? ប្រសិនបើមាន សូមរៀបរាប់អំពីការផ្លាស់ប្តូរទាំងនេះ?
15. តើព្រឹត្តិការណ៍ពិភពលោកក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះបានប៉ះពាល់ដល់ទំនាក់ទំនងរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលដែរឬទេ? (ឧទាហរណ៍ ប្រសិទ្ធភាពជំនួយ ឬ កិច្ចពិភាក្សាវែកញែកអំពីប្រសិទ្ធភាពនៃការអភិវឌ្ឍ។ល។)
16. តើអ្នកគិតថាអ្វីដែលគួរតែមាន ដើម្បីធ្វើឲ្យទំនាក់ទំនងល្អ និងមានប្រសិទ្ធភាពរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល?
17. តើអ្នកមានអ្វីជាមតិយោបល់បន្ថែមទៀតដែរឬទេ?

**សូមអរគុណ!**

## កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលរបស់អង្គការសង្គមស៊ីវិល

ខ្ញុំមានសំណួរមួយចំនួនអំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសង្គមស៊ីវិល។

1. ខ្ញុំបានផ្ញើជូនអ្នកនូវព័ត៌មានមួយចំនួនដែលបានរៀបចំសម្រាប់កិច្ចសម្ភាសន៍នេះ។ តើអ្នកបានអានទំព័រនេះដែរឬទេ? តើអ្នកគិតថាខ្ញុំបានបញ្ចូលបញ្ហាបានគ្រប់គ្រាន់ដែរឬទេ? តើខ្ញុំអាចកែលម្អគុណភាពព័តមាននេះយ៉ាងដូចម្ដេច?
2. តើច្បាប់ដែលគ្រប់គ្រងលើប្រតិបត្តិការ របស់អង្គការសង្គមស៊ីវិល (ក្រមរដ្ឋប្បវេណី) និងគ្រប់គ្រងលើសម្ព័ន្ធអង្គការសង្គមស៊ីវិលមានភាពស្របគ្នាដែរឬទេ? តើច្បាប់នេះអនុញ្ញាតឲ្យអង្គការសង្គមស៊ីវិលបង្កើតជាក្រុមដែរឬទេ? តើច្បាប់នេះលើកទឹកចិត្ត ឬរារាំងអង្គការសង្គមស៊ីវិលក្នុងការបង្កើតជាក្រុមដែរឬទេ?
3. តើអង្គការសង្គមស៊ីវិលក្នុងស្រុកមានសិទ្ធិស្របច្បាប់ក្នុងការបង្កើតជាភាពដៃគូជាមួយអង្គការអន្តរជាតិមិនមែនរដ្ឋាភិបាល ហើយអង្គការអន្តរជាតិមិនមែនរដ្ឋាភិបាលមានសិទ្ធិស្របច្បាប់ក្នុងការបង្កើត ភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិលក្នុងស្រុកដែរឬទេ? តើអ្នកត្រូវរាយការណ៍អ្វីខ្លះជូនដល់រដ្ឋាភិបាល នៅពេលអ្នកចូលរួមជាដៃគូបែបនេះ? តើត្រូវរាយការណ៍ទាំងអស់ឬយ៉ាងណា?
4. តើសម្ព័ន្ធ បណ្ដាញ ឬក្រុមដែលមានលក្ខណៈស្រដៀងគ្នានៃអង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជាមានលក្ខណៈទូទៅតែមួយដែរឬទេ? តើជាទូទៅ អង្គការសង្គមស៊ីវិលសហការគ្នាលើបញ្ហារួមដែរឬទេ?
5. តើទំនាក់ទំនងរវាងអង្គការសង្គមស៊ីវិលមានលក្ខណៈដូចម្ដេចដែរ? តើអង្គការសង្គមស៊ីវិលអាចនិងមានបំណងសហការជាមួយគ្នាដែរឬទេ? តើវិស័យណាខ្លះដែលអង្គការសង្គមស៊ីវិលមានកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពជាងក្នុងវិស័យផ្សេងទៀត? តើវិស័យណាខ្លះដែលអង្គការសង្គមស៊ីវិលមានកិច្ចសហប្រតិបត្តិការល្អបំផុតជាមួយគ្នា? តើវិស័យណាដែលត្រូវការលើកកម្ពស់កិច្ចសហប្រតិបត្តិខ្លាំងបំផុត?
6. តើមានសេចក្ដីព្រាងច្បាប់ ឬបទប្បញ្ញត្តិដែល (ប្រសិនបើអនុម័ត) រឹតត្បិត ឬផ្ដល់ភាពងាយស្រួលដល់ក្រុមអង្គការសង្គមស៊ីវិលដែរឬទេ? តើអ្នកអាចប្រាប់ខ្ញុំអំពីសេចក្ដីព្រាងទាំងនេះបានដែរឬទេ? តើសេចក្ដីព្រាងនេះត្រូវការរយៈពេលប៉ុន្មាន ដើម្បីអនុម័តក្លាយជាច្បាប់?
7. តើអ្នកមានអ្វីជាមតិយោបល់បន្ថែមទៀតដែរឬទេ?

*សូមអរគុណច្រើនដែលចំណាយពេលវេលាដ៏មានតម្លៃចូលរួមផ្ដល់បទសម្ភាសន៍។*

## ឧបសម្ព័ន្ធ ២: អ្នកផ្តល់ព័ត៌មានសំខាន់ៗ

លោក ឈិត សំអាត នាយកប្រតិបត្តិ អង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា

លោក សៀង សារឿន នាយកប្រតិបត្តិ អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា

កញ្ញា ទុយ មុនីរ៉េត អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា

លោកស្រី Haidy Ear-Dupuy អតីតប្រធានគណៈកម្មាធិការប្រតិបត្តិ នៃអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា

លោកបណ្ឌិត គឹម សេតារា ផ្នែកបណ្ឌិតសភា

លោកបណ្ឌិត កែម ឡី អ្នកស្រាវជ្រាវឯករាជ្យ

លោកស្រី Caroline McCausland នាយិកាប្រចាំប្រទេស អង្គការអាក់សិនអេតកម្ពុជា

លោកស្រី រស់ សុភាព នាយិកាប្រតិបត្តិ អង្គការយេនឌ័រ និងការអភិវឌ្ឍដើម្បីកម្ពុជា (GADC)

តំណាង អង្គការភាពជាដៃគូអប់រំនៃអង្គការមិនមែនរដ្ឋាភិបាល (NEP)

តំណាងអង្គការសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (NGOCRC)

តំណាងអង្គការលីកាដូ (LICADHO)

លោកស្រី Stav Zotalis នាយិកាប្រចាំប្រទេស អង្គការ Care Cambodia

លោកស្រី Thida Khus នាយិកាប្រតិបត្តិ អង្គការ SILAKA

លោក អៀង វុទ្ធី នាយកប្រតិបត្តិ អង្គការសមធម៌កម្ពុជា

លោកបណ្ឌិត សាម អ៊ីន អង្គការជីវិតថ្លៃថ្នូរ

លោក អ៊ី សារុំ នាយកប្រតិបត្តិ អង្គការសមាគមធាងត្នោត

លោក ជាង សុខា នាយកប្រតិបត្តិ កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន

លោក កុយ នាម មន្ត្រីកម្មវិធីជាន់ខ្ពស់ ច្បាប់ និងសិទ្ធិមនុស្ស - មូលនិធិអាស៊ី (Asia Foundation)

លោក អាត់ ធន់ ប្រធាន សម្ព័ន្ធពលករកម្ពុជា

លោក វន់ ពៅ ប្រធាន សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ

លោកស្រី ដាំ ចន្ទី នាយិកា សមាគមខ្មែររលើ

លោក យ៉េង វីរៈ នាយកប្រតិបត្តិ មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍

លោកស្រី ប្រាក់ សុខានី នាយិកាប្រតិបត្តិ អង្គការភាពជាដៃគូសង្គមស៊ីវិលកម្ពុជា

លោកស្រី ជា ស៊ុនដាណែត នាយិកាប្រតិបត្តិ មជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា

# ឧបសម្ព័ន្ធ ៣: សន្ទានុក្រមនៃអង្គការសង្គមស៊ីវិលនៅកម្ពុជា

ដកស្រង់ចេញពី: http://www.ccc-cambodia.org/aboutus/faq.html

### អ្វីទៅជាអង្គការសង្គមស៊ីវិល (CSO)?

មាននិយមន័យបែបទ្រឹស្តីជាច្រើន ប៉ុន្តែតាមការអនុវត្តន៍ជាក់ស្តែង អង្គការសង្គមស៊ីវិល គឺជាអង្គការដែលកើតឡើងហួសពីដែនរបស់រដ្ឋ (ស្ថាប័នរាជរដ្ឋាភិបាល) ឯកជន (បណ្តាញគ្រួសារ) និងទីផ្សារ (អង្គភាពរកប្រាក់ចំណេញ) ហើយដែលមានរចនាសម្ព័ន្ធផ្លូវការ និងភ្ជាប់នឹងរបៀបវារៈ មិនរកប្រាក់ចំណេញ ដោយជាទូទៅ អតិរេកហិរញ្ញវត្ថុ ត្រូវវិនិយោគត្រលប់មកអង្គការវិញ ដើម្បីធ្វើឲ្យគោលដៅមានការរីកចម្រើនទៅមុខ។ ត្រូវចាត់ទុកថា ជាអង្គការសង្គមស៊ីវិល អង្គការនោះ *ត្រូវតែ អាចប្រតិបត្តិ ស្វ័យអភិបាលកិច្ចឯករាជ្យ។* ជាទូទៅ ពាក្យអង្គការសង្គមស៊ីវិល ត្រូវបានចាត់ទុកថា ជាពាក្យរួមដែលរាប់បញ្ចូលទាំងអង្គការមិនមែនរដ្ឋាភិបាល(NGOs)។
*[CCC 2012, CSO Contributions to the Development of Cambodia 2011]*

អង្គការសង្គមស៊ីវិល រួមមានទម្រង់ផ្សេងៗដូចជា: ការអភិវឌ្ឍផ្លូវការ អង្គការសិទ្ធិមនុស្ស និងបរិស្ថាន ក្រុមសហគមន៍ អង្គការស្ត្រី អង្គការទាក់ទងនឹងជំនឿ សមាគមវិជ្ជាជីវៈ សហជីព ក្រុមជួយខ្លួនឯង ចលនាសង្គម ក្រុមតស៊ូមតិ និងសម្ព័ន្ធ និងក្នុងចំណោមក្រុមផ្សេងៗទៀត។ គឺជាពាក្យទូទៅ ដែលសំដៅទៅលើអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក សមាគម និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ចំណែកអង្គការនៅតាមសហគមន៍ ត្រូវបានកំណត់អត្តសញ្ញាណដោយឡែកពីនេះ។
*[Open Forum on CSO Development Effectiveness, 2011]*

### អ្វីទៅជាអង្គការមិនមែនរដ្ឋាភិបាល (NGO) ?

អង្គការមិនមែនរដ្ឋាភិបាល និងជួនកាលហៅថា អង្គការមិនរកប្រាក់ចំណេញ ដែលបង្កើតឡើង សម្រាប់គោលបំណងជាក់លាក់ណាមួយ - ជាញឹកញាប់មាន គោលដៅផ្នែកសង្គម ដូចជាការកាត់បន្ថយភាពក្រីក្រ កិច្ចការពារ ឬលើកកម្ពស់សិទ្ធិរបស់ជនក្រីក្រ ការពារបរិស្ថាន ឬធ្វើការអភិវឌ្ឍន៍សហគមន៍។ អង្គការនេះ មិនមែនជារបស់រដ្ឋ ឬរាជរដ្ឋាភិបាលទេ ទោះបីអង្គការនេះ អាចសហការជាមួយរាជរដ្ឋាភិបាល (ជួនកាលយ៉ាងជិតស្និទ្ធ និង/ឬរយៈពេលវែង) ប្រសិនបើពួកគេ មានគោលបំណងនិងគោលដៅរួមគ្នា។
*[CCC 2012, CSO Contributions to the Development of Cambodia 2011]*

ពាក្យថាអង្គការមិនមែន រដ្ឋាភិបាលសំដៅទាំងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាលបរទេស។ *[3rd Draft of LANGO, 2011]*

### អ្វីទៅជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក (LNGO)?

ប្រភេទនៃអង្គការមិនមែនរដ្ឋាភិបាលនេះ ត្រូវបានបង្កើតឡើង និងមានប្រតិបត្តិការតែនៅក្នុងប្រទេសណាមួយប៉ុណ្ណោះ។ អង្គការនេះ អាចស្ថិតនៅថ្នាក់ជាតិ ដោយមានតំណាងនៅក្នុងខេត្ត/ស្រុក (ជួនកាលហៅថា អង្គការមិនមែនរដ្ឋាភិបាលថ្នាក់ជាតិ) ឬអាចជាអង្គការ ដែលមានមូលដ្ឋាននៅក្នុងតំបន់/ស្រុក ដោយផ្តោតលើតែតំបន់ណាមួយ។ នៅក្នុងបរិបទនៅកម្ពុជា អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក គឺជាអង្គការមិនមែនរដ្ឋាភិបាលដែលមានប្រតិបត្តិការតែនៅក្នុងប្រទេសកម្ពុជាដឹកនាំដោយជនជាតិកម្ពុជានិងបានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ(MOI)។
*[CCC 2012, CSO Contributions to the Development of Cambodia 2011]*

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក គឺសំដៅដល់ក្រុមសញ្ជាតិខ្មែរ ដែលបានព្រមព្រៀងគ្នាបង្កើតអង្គការ ដើម្បីបម្រើផលប្រយោជន៍សាធារណៈ ដោយមិនរកប្រាក់កម្រៃសម្រាប់សមាជិក។
*[3rd Draft of LANGO, 2011]*

### អ្វីទៅជាសមាគម?

សមាគមគឺជាអង្គការដែលត្រូវបានបង្កើតឡើង ភាគច្រើន ដោយមនុស្សមួយក្រុម ដើម្បីបម្រើ ឬបំពេញសេចក្តីត្រូវការបន្ថែមទៀតរបស់ក្រុមខ្លួន។ ជាធម្មតា សមាគម មានសមាជិកស្ម័គ្រចិត្ត ដែលចូលរួមក្នុងសមាគមជាផ្លូវការ ដើម្បីចែករំលែកនូវសេវាកម្ម ធនធាន បទពិសោធន៍ ឬសមត្ថភាព ធ្វើការចរចាក្នុងនាមអង្គភាពតែមួយ។ ដូចគ្នានឹងអង្គការមិនមែនរដ្ឋាភិបាល សមាគមគឺជាស្ថាប័នមិនរកប្រាក់ចំណេញ ទោះបីជាសមាជិករបស់ខ្លួន អាចចូលរួមក្នុងសកម្មភាពរកប្រាក់កម្រៃក៏ដោយ។
*[CCC 2012, CSO Contributions to the Development of Cambodia 2011; 3rd Draft of LANGO, 2011]*

សមាគមគឺសំដៅដល់ក្រុមដែល បានព្រមព្រៀងធ្វើការរួមគ្នា ដើម្បីការពារផលប្រយោជន៍សមាជិក ឬ/និងផលប្រយោជន៍សាធារណៈ មិនរកប្រាក់កម្រៃ សម្រាប់ចែកចាយសមាជិករបស់ខ្លួន។
*[3rd Draft of LANGO, 2011]*

### អ្វីទៅជាអង្គការនៅតាមសហគមន៍ (CBO)?

អង្គការនៅតាមសហគមន៍ ជាទូទៅបង្កើតឡើងដោយក្រុម ឬសហគមន៍ណាមួយ (សហគមន៍តាមតំបន់ ឬ "សហគមន៍មានផលប្រយោជន៍") ដើម្បីធ្វើឲ្យរីកចម្រើនដល់ផលប្រយោជន៍រួមជាក់លាក់ណាមួយ ជាទូទៅមានលក្ខណៈជាទ្រង់ទ្រាយតូច។ ជាធម្មតា អង្គការនៅតាមសហគមន៍ មានសមាជិកដែលទទួលផលប្រយោជន៍ដោយផ្ទាល់ ហើយជាទូទៅ ប្រតិបត្តិដោយប្រមូលផ្តុំ និងតំណាងឲ្យសហគមន៍ ជាមួយរាជរដ្ឋាភិបាល (មូលដ្ឋាន និង/ឬ ថ្នាក់ជាតិ) ដៃគូផ្តល់ជំនួយ/អភិវឌ្ឍន៍ ក្រុមហ៊ុនឯកជន ឬអង្គភាពផ្សេងទៀត ទាក់ទងនឹង បញ្ហាសង្គម វប្បធម៌ សេដ្ឋកិច្ច សាសនា ឬបរិស្ថាន។ អង្គការនៅតាមសហគមន៍ជាច្រើន មិនបានជ្រើសរើសបុគ្គលិកទទួលបានបៀវត្សរ៍នោះទេ ហើយបំពេញការងារដោយស្ម័គ្រចិត្ត ដែលអាចមានសណ្ឋានផ្សេងគ្នា ពីអង្គការមិនមែនរដ្ឋាភិបាល។

### អ្វីទៅជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ (INGO)?

អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ គឺជាអង្គការមិនមែនរដ្ឋាភិបាលដែលមានប្រតិបត្តិការនៅក្នុងប្រទេសលើសពីមួយ ទោះជាតាមរយៈប្រតិបត្តិការពហុអន្តរជាតិ ការចុះបញ្ជីនៅបរទេស ឬគ្រាន់តែមានស្ថាបនិកជាជនបរទេស ស្ថិតនៅក្នុងប្រទេសដែលមានមូលដ្ឋានប្រតិបត្តិការនោះ។ ដូច្នេះ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមួយចំនួន មានប្រតិបត្តិការដូចអង្គការក្នុងស្រុកដែរ។ នៅក្នុងបរិបទកម្ពុជា អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ គឺជាអង្គការដែលបំពេញតាមលក្ខណៈវិនិច្ឆ័យទាំងនេះមានប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា។

*[CCC 2012, CSO Contributions to the Development of Cambodia 2011]*

អង្គការមិនមែនរដ្ឋាភិបាលបរទេសសំដៅដល់ក្រុមជនជាតិបរទេស បានបង្កើតតាមច្បាប់បរទេស ដើម្បីបម្រើសកម្មភាពសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជា ធ្វើសកម្មភាពមិនរកប្រាក់កម្រៃសម្រាប់ចែកចាយសមាជិករបស់ខ្លួន។ *[3rd Draft of LANGO, 2011]*

### អ្វីទៅជាសម្ព័ន្ធ(អង្គការ ឬសមាគម)?

សម្ព័ន្ធសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសំដៅដល់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកស្របច្បាប់រួបរួមគ្នាដើម្បីគោលបំណងរួម ប្រតិបត្តិការដើម្បីបម្រើប្រយោជន៍សាធារណៈដោយមិនរកប្រាក់កម្រៃ សម្រាប់ចែកចាយសមាជិករបស់ខ្លួន៕

# ឯកសារយោង

សូមបញ្ជាក់ថា ជាទូទៅគេហទំព័រដែលបានពិគ្រោះសម្រាប់ការសិក្សាស្រាវជ្រាវនេះ ត្រូវបានយោងនៅក្នុង footnotes ។


Bañez-Ockelford, J 2011, 'Cambodia (country chapter)', in T Chong & S Elies (eds), *An ASEAN Community For All: Exploring the scope for civil society engagement*, Friedrich-Ebert-Stiftung, Singapore.

*Civil Code of Cambodia* 2007, http://www.sithi.org/admin/upload/law/Civil%20Code%20English%202008.pdf.

*Compilation of reports submitted by civil society organizations to the United National Human Rights Council during the 18th session of the Universal Periodic Review of the Kingdom of Cambodia* 2013, Cambodian Human Rights Action Committee, Phnom Penh.

Cooperation Committee for Cambodia 2012, *CSO Contributions to the Development of Cambodia, 2011*, Cooperation Committee for Cambodia, Phnom Penh.

---- 2013, *CSO Contributions to the Development of Cambodia 2012: Opportunities and challenges* Cooperation Committee for Cambodia, Phnom Penh.

Cord Cambodia 2011, *Busan and Beyond: Accountability and an enabling environment for civil society in Cambodia*, Cooperation Committee for Cambodia, NGO Forum on Cambodia and Medicam Phnom Penh, Cambodia.

Merla, C 2010, *Strengthening Democracy and Electoral Processes in Cambodia: Civil Society Empowerment and Democratic Governance in Cambodia*, UNDP, Phnom Penh, Cambodia.

Observatory for the Protection of Human Rights Defenders 2010, *Cambodia: Freedoms of Expression, Association and Assembly: A shrinking space*, International Federation for Human Rights, http://www.fidh.org/IMG/pdf/OBS_CAMBODGE_final_ENG.pdf.

Rasmussen, K 2010, *NGO Contributions to Cambodia's Development 2004-2009* Cooperation Committee for Cambodia Phnom Penh.

Suárez, D & Marshall, JH 2012, 'Capacity in the NGO Sector: Results from a National Survey in Cambodia', *VOLUNTAS: International Journal of Voluntary and Nonprofit Organizations*, pp. 1-25.

**ទស្សនវិស័យ**:

សង្គមស៊ីវិលមួយដែលមានកិច្ចសហការដ៏រឹងមាំ និង មានសមត្ថភាពឆ្លើយតបទៅនឹងបញ្ហានៃការអភិវឌ្ឍនៅកម្ពុជា។

**បេសកកម្ម**:

ក្នុងឋានៈជាសមាគមដែលមានវិជ្ជាជីវៈមួយនៃ អង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ផ្តល់សេវាកម្មប្រកបដោយគុណភាពខ្ពស់ជូនដល់សង្គមស៊ីវិល និង បង្កលក្ខណៈឱ្យមានឥទ្ធិពលដល់ដៃគូអភិវឌ្ឍនៃប្រទេសកម្ពុជា ជាមួយនឹងសំលេងរួមគ្នារបស់យើង។

**គុណតម្លៃ**:

- ☆ សុចរិតភាព
- ☆ កិច្ចសហប្រតិបត្តិការ
- ☆ ភាពឆ្លើយតប
- ☆ គុណភាព

ការបោះពុម្ពនេះអាចធ្វើទៅបានដោយមានការឧបត្ថម្ភពីម្ចាស់ជំនួយដូចខាងក្រោម :

ផ្ទះលេខ ៩-១១, ផ្លូវលេខ ៤៧៦, ទួលទំពូងទី១, ខណ្ឌចំការមន
ប្រអប់សំបុត្រ ៨៨៥, ភ្នំពេញ កម្ពុជា
ទូរស័ព្ទ +855 (0)23 214 152
ទូរសារ +855 (0)23 216 009
info@ccc-cambodia.org
www.ccc-cambodia.org
www.facebook.com/CCCsince1990
www.youtube.com/CCCambodia